# សិក្សាព្រះសូត្រ

## ភាគទី១



[illegible]

[illegible]

[illegible] ឃុត សាខឿ

# ពាក្យប្រារព្ធ

សៀវភៅ **សិក្សាព្រះសូត្រ** នេះ គ្រាន់តែជាជំនួយឱ្យមានចំណូលចិត្តក្នុងការអានព្រះត្រៃបិដក ដោយខ្ញុំព្រះករុណា ខ្ញុំបាទស្រង់ឈ្មោះតាមលំដាប់នៃព្រះសូត្រ ប្រារព្ធទីចារិក និងការគង់ប្រថាប់នៅនៃព្រះដ៏មានព្រះភាគ ព្រមដោយភិក្ខុសង្ឃ ហើយមានសេចក្ដីនៃព្រះធម៌ខ្លះ អត្ថន័យក្នុងព្រះអដ្ឋកថាខ្លះ គ្រាន់បានជាទីជ្រះថ្លាក្នុងការអាន ឬការស្ដាប់ ចម្រើននូវពុទ្ធានុស្សតិជាដើម ។

ម្យ៉ាងទៀត ជាការរំលឹកព្រះធម៌ប្រចាំឆ្នាំសិក្សាក្នុងវស្សានៃពុទ្ធសករាជ ២៥៥៧ នៅសាលារៀនសតិប្បដ្ឋានខេត្តបាត់ដំបងផង ដើម្បីបានជាសៀវភៅធម្មទានសម្រាប់ចែកនៅពេលបុណ្យកឋិនទានប្រចាំឆ្នាំផង សង្ឃឹមថា ពុទ្ធបរិស័ទនឹងបានប្រយោជន៍ពីការអាន ឬស្ដាប់សេចក្ដីនៃព្រះធម៌នៅក្នុងសៀវភៅនេះ ហើយឈានទៅរកការអាន ឬស្ដាប់ព្រះត្រៃបិដកជាមិនខាន ។

នៅក្នុងព្រះអដ្ឋកថា ឧទានសូត្រ សំយុត្តនិកាយ ខន្ធវារវគ្គ បានសម្ដែងអំពីឧបនិស្ស័យនៃមគ្គផលថា **ឋានសីលូបនិស្សយោ ហិ តយោ មគ្គេ ច ផលានិ ច បាបេន្តិ ភាវនូបនិស្សយោ**

អរហត្តំ ធាបេតិ ពិតណាស់ ទានូបនិស្ស័យនិងសីលូបនិស្ស័យ រមែងញ៉ាំងសត្វឱ្យសម្រេចនូវមគ្គ ៣ និង ផល ៣ (ចំណែក ) ភាវនូបនិស្ស័យ ឱ្យសម្រេចនូវព្រះអរហត្ត ។

កាលបើពុទ្ធបរិស័ទ មានឧបនិស្ស័យនៃមគ្គផលហើយ បាន ប្រារព្ធព្យាយាមនៅក្នុងព្រះពុទ្ធសាសនា អប់រំចម្រើនសតិប្បដ្ឋាន នឹងបានជាបុគ្គលមានភ័ព្វ សម្រេចមគ្គផលពុំខាន ។

សូមឱ្យពុទ្ធបរិស័ទ មានទាន សីល ភាវនា ជាឧបនិស្ស័យ បានគ្រប់គ្រាន់ក្នុងការសម្រេចមគ្គផល និង កុំគប្បីមានសេចក្តី អន្តរាយ ឬគ្រឿងរារាំងអ្វីណាមួយឡើយ ។

**បិនទគ្គសិក្សានៅចាត់ជំបទត្តូខទស្សា ព.ស.២៥៥៧**

**ខ្ញុំព្រះករុណា ខ្ញុំបាទ ប៊ុត សាវង្ស**

# មាតិកា

| ឈ្មោះអត្ថបទ | ទំព័រ |
| --- | --- |

I- ព្រះសុត្តន្តបិដកខ្មែរលេខ ១៤

- ពាក្យគួរយល់ដឹង ................................ ១

១- ព្រហ្មជាលសូត្រ ................................២

២- សាមញ្ញផលសូត្រ ............................. ៧

៣- អម្ពដ្ឋសូត្រ ...................................... ១២

៤- សោណទណ្ឌសូត្រ ............................ ១៦

II- ព្រះសុត្តន្តបិដកខ្មែរលេខ ១៥

- ពាក្យគួរយល់ដឹង .............................. ២១

១- កូដទន្តសូត្រ .................................... ២២

២- មហាលិសូត្រ .................................. ២៨

៣- ជាលិយសូត្រ .................................. ៣២

៤- មហាសីហនាទសូត្រ ......................... ៣៤

៥- បោដ្ឋបាទសូត្រ ............................. ៤០

៦- សុភសូត្រ ......................................៤៨

៧- កេវដ្តសូត្រ ................................... ៥៣

៨- លោហិច្ចសូត្រ ................................. ៥៨

៩- តេវិជ្ជសូត្រ ................................... ៦៣

III- ព្រះសុត្តន្តបិដកខ្មែរលេខ ១៦

- ពាក្យគួរយល់ដឹង ................................ ៧១

១- មហាបទានសូត្រ .............................. ៧២

២- មហានិទានសូត្រ ............................. ៧៨

៣- មហាបរិនិព្វានសូត្រ ......................... ៨២

IV- ព្រះសុត្តន្តបិដកខ្មែរលេខ ១៧

- ពាក្យគួរយល់ដឹង ................................ ៩៥

១- មហាសុទស្សនសូត្រ ........................... ៩៦

២- ជនវសភសូត្រ .................................. ៩៩

៣- មហាគោវិន្ទសូត្រ ............................. ១០៤

៤- មហាសមយសូត្រ ............................. ១១២

៥- សក្កបញ្ហសូត្រ ................................ ១១៧

៦- មហាសតិប្បដ្ឋានសូត្រ ....................... ១២៥

៧- បាយាសិរាជញ្ញសូត្រ ......................... ១២៩

# ព្រះសុត្តន្តបិដកខ្មែរលេខ ១៤

## ទីឃនិកាយ សីលក្ខន្ធវគ្គ មាន ៤ ព្រះសូត្រ គឺ

១- ព្រហ្មជាលសូត្រ ២- សាមញ្ញផលសូត្រ

៣- អម្ពដ្ឋសូត្រ ៤- សោណទណ្ឌសូត្រ ។

## ពាក្យគួរយល់ដឹង

≈≈≈≈≈≈≈≈≈≈≈≈≈≈

**ទីឃនិកាយ** ជាទីប្រជុំនិងជាទីអាស្រ័យនៅនៃព្រះសូត្រទាំងឡាយដែលមានខ្នាតវែង ។ បិដកខ្មែរយើង ចាប់ពីលេខ ១៤ ដល់លេខ ១៩ ចែកទៅជាបីវគ្គ គឺ សីលក្ខន្ធវគ្គ ១, មហាវគ្គ ១ និង បាដិកវគ្គ ១ រួមព្រះសូត្រក្នុងទីឃនិកាយទាំងអស់មាន ៣៤ ព្រះសូត្រ គឺក្នុងសីលក្ខន្ធវគ្គ បិដកលេខ ១៤ និង ១៥ មាន ១៣ ព្រះសូត្រ ក្នុងមហាវគ្គ បិដកលេខ ១៦ និង ១៧ មាន ១០ ព្រះ-សូត្រ ក្នុងបាដិកវគ្គ បិដកលេខ ១៨ និង ១៩ មាន ១១ ព្រះសូត្រ។

# ១~ ព្រហ្មជាលសូត្រ

ព្រះដ៏មានព្រះភាគ ជាមួយនឹងភិក្ខុសង្ឃ ៥០០ អង្គ គង់នៅក្នុងព្រះរាជដំណាក់ ក្នុងសួនឈ្មោះអម្ពលដ្ឋិកា នៅរវាងក្រុងរាជគ្រឹះនិងស្រុកនាឡន្ទា ។

ក្នុងកាលនោះ សុប្បិយបរិព្វាជក តិះដៀលព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ឯចំណែកព្រហ្មទត្តមាណពដែលជាកូនសិស្សរបស់សុប្បិយបរិព្វាជកនោះឯង បែរទៅជាពោលសរសើរព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃទៅវិញ ដែលធ្វើឱ្យអ្នកទាំងពីរជាគ្រូនិងសិស្សពោលពាក្យជាសឹកសត្រូវនឹងគ្នា ។

ព្រះដ៏មានព្រះភាគ ទ្រង់ទូន្មានភិក្ខុទាំងឡាយអំពីរឿងអ្នកដទៃតិះដៀលនិងពោលសរសើរព្រះរតនត្រ័យ រួចហើយព្រះអង្គទ្រង់ត្រាស់អំពីបុថុជ្ជន កាលបើពោលសរសើរគុណរបស់តថាគតតែងសរសើរដោយគុណជាតិណា គុណជាតិនោះមានប្រមាណតិច មានប្រមាណស្តួចស្តើង បានត្រឹមតែសីលប៉ុណ្ណោះ ។

ជាបន្ត ព្រះអង្គទ្រង់ត្រាស់អំពីពួកសីល គឺ ចូឡសីល មជ្ឈិមសីល និងមហាសីល ដែលធ្វើឱ្យព្រះសូត្រនេះសង្គ្រោះក្នុង

សីលក្ខន្ធវគ្គហ្នឹងឯង ។ ជាបន្តទៀត ព្រះសុគតជាសាស្តា ទ្រង់ត្រាស់ទិដ្ឋិ ៦២ ដើម្បីសម្តែងនូវភាពនៃសព្វញ្ញុតញ្ញាណ ជាព្រះគុណដ៏ក្រៃលែងរបស់ព្រះអង្គ រួចហើយព្រះអង្គទ្រង់ប្រកាសនូវសុញ្ញតា ព្រោះថាទិដ្ឋិទាំងអស់សុទ្ធតែអាស្រ័យផស្សៈជាបច្ច័យទើបកើតឡើងបាន ។

ក្នុងព្រះសូត្រនេះ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់វដ្តកថា ដោយព្រះអង្គទ្រង់លើកយកទិដ្ឋិជាប្រធាន និងព្រោះដោយការជាប់ជំពាក់ចិត្តក្នុងវេទនា ទើបព្រះអង្គទ្រង់ត្រាស់បដិច្ចសមុប្បាទ-ធម៌ដែលមានវេទនាជាមូល គឺនៅទំព័រ ១០៩ មានជាដើមថា តណ្ហារបស់សមណព្រាហ្មណ៍ទាំងនោះ កើតមានព្រោះវេទនាជាបច្ច័យ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់វិវដ្តកថា ដោយលើកយកភិក្ខុដែលជាអ្នកប្រកបដោយសេចក្តីព្យាយាម មកជាទីតាំង ព្រះ-អង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុដឹងច្បាស់នូវការកើតឡើង (សមុទយៈ), ការរលត់ (អត្ថង្គមៈ), ការត្រេកអរ (អស្សាទៈ), ទោស (អាទីនវៈ)និងការរលាស់ចោល (និស្សរណៈ) នូវអាយតនៈដែលជាទីកើតនៃផស្សៈទាំង ៦ តាមសេចក្តីពិត ក្នុងកាលណា ក្នុងកាលនោះ ភិក្ខុនេះរមែងដឹងច្បាស់នូវធម៌ដ៏លើសលប់ ជាងសមណព្រាហ្មណ៍ទាំងអស់នោះ ។ អដ្ឋកថា សម្តែងថា ភិក្ខុនេះ

រមែងដឹងនូវទិដ្ឋិ និងធម៌ដ៏ក្រៃលែងជាងទិដ្ឋិ គឺ សីល សមាធិ បញ្ញា វិមុត្តិ រហូតដល់ព្រះអរហត្ត ឯភិក្ខុអ្នកដឹងនោះទៅតាមលំដាប់ គឺព្រះខីណាស្រព ព្រះអនាគាមី ព្រះសកទាគាមី ព្រះសោតាបន្ន ភិក្ខុជាពហុស្សូតទ្រទ្រង់គន្ថធុរៈ និងភិក្ខុប្រារព្ធវិបស្សនា ។

ព្រះធម៌ទេសនា ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ដល់ធម៌កំពូលគឺព្រះអរហត្តក្នុងវិវដ្តកថា ជាចុងក្រោយព្រះអង្គត្រាស់អំពីបុគ្គលដែលមានទិដ្ឋិទាំងអស់មិនផុតពីសំណាញ់ គឺព្រះធម៌ទេសនារបស់ព្រះអង្គនេះឡើយ ដូចត្រីនៅក្នុងសំណាញ់ព្រាន ពោលគឺម៉ឺនលោកធាតុដូចទីដែលមានទឹកតិច បុគ្គលដែលមានទិដ្ឋិទាំងអស់ដូចត្រីនៅក្នុងសំណាញ់ ព្រះធម៌ទេសនាដូចជាសំណាញ់ ព្រះ-ពុទ្ធអង្គទ្រង់ដូចជាអ្នកបង់សំណាញ់ ។ ព្រះសម្មាសម្ពុទ្ធត្រាស់បញ្ចប់ព្រះធម៌ទេសនាដោយអនុបាទិសេសនិព្វានធាតុ រួចហើយព្រះអង្គទ្រង់ប្រកាសឈ្មោះនៃធម្មបរិយាយ ៥ យ៉ាងគឺ

១_ **អត្ថជាលៈ** បែងចែកនូវប្រយោជន៍

២_ **ធម្មជាលៈ** បែបផែនច្រើនក្នុងការសម្ដែងធម៌

៣_ **ព្រហ្មជាលៈ** សំណាញ់ព្រហ្មគឺសព្វញ្ញុតញ្ញាណ

៤_ **ទិដ្ឋិជាលៈ** បែងចែកទិដ្ឋិ ៦២

**៥~ អនុត្តរសង្គាមវិជយៈ** អ្នកណាៗ ស្តាប់ធម្មបរិយាយនេះហើយ អាចនឹងញាំញីបាននូវទេវបុត្តមារ ខន្ធមារ មច្ចុមារ និងកិលេសមារ ដូច្នោះ ទើបធម្មបរិយាយនេះឈ្មោះថា ពិជ័យ-សង្គ្រាមដ៏ប្រសើរខ្ពង់ខ្ពស់បំផុត ។

ភិក្ខុទាំងនោះ បានស្តាប់នូវព្រហ្មជាលសូត្រនេះហើយ ក៏មានចិត្តអណ្តែតឡើងដោយបីតិ បង្អោនទៅរកព្រះដ៏មានព្រះ-ភាគ ដែលព្រះអង្គទ្រង់ប្រកាសនូវព្រះសព្វញ្ញុតញ្ញាណ ដ៏សែនជ្រៅក្រៃលែង កម្ចាត់នូវមហាអន្ធការគឺទិដ្ឋិ ដូចព្រះអាទិត្យកម្ចាត់នូវភាពងងឹតដូច្នោះឯង ។

កាលដែលព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សម្តែងនូវវេយ្យាករណ៍ គឺព្រះសូត្រមិនមានគាថានេះចប់ហើយ លោកធាតុគឺចក្កវាឡទាំងមួយម៉ឺន ក៏កម្រើកញាប់ញ័រ ។ ផែនដីកម្រើកញាប់ញ័រដោយការសម្តែងព្រះសូត្រនេះ ក្នុងពេលសង្គាយនាទាំង ៣ លើកផង ក្នុងពេលព្រះមហិន្ទត្ថេរសម្តែងក្នុងជាតិវ័ននៅតម្ពបណ្ណិទ្វីបផង ក្នុងពេលព្រះបិណ្ឌបាតិយត្ថេរបោសលានព្រះ-ចេតិយ នាវត្តកល្យាណី ហើយគង់នៅទីលានព្រះចេតិយនោះ មានបីតិដោយពុទ្ធានុស្សតិ ហើយសូត្រនូវព្រះសូត្រនេះផង និងក្នុងពេលព្រះថេរៈច្រើនអង្គគង់នៅអម្ពលដ្ឋិកៈ នាទិសខាងកើត

លោហប្រាសាទ សូត្រនូវព្រហ្មជាលសូត្រនេះឯងផង ។

ដោយអានុភាពនៃព្រះសូត្រដ៏ប្រសើរណា ដែលព្រះ-សយម្ភូទ្រង់បានសម្ដែងហើយ ផែនដីក៏បានញាប់ញ័រច្រើនដង យ៉ាងនេះ សូមបណ្ឌិតទាំងឡាយសិក្សាដោយគោរព នូវសេចក្ដីនៃព្រះធម៌ក្នុងព្រះសូត្រនោះ ដែលមានឈ្មោះថា ព្រហ្មជាលសូត្រ ក្នុងសាសនានេះ ហើយបដិបត្តិដោយឧបាយដែលនាំឱ្យកើតបញ្ញាចុះ ។

## សំណាញ់ព្រះញាណ

ព្រហ្មជាលៈសំណាញ់ព្រះញាណ ព្រះពុទ្ធទ្រង់មានមហាតេជះ
មារបរាជ័យព្រះពុទ្ធទ្រង់ឈ្នះ ព្រហ្មក្រាបសំពះអារាធនាធម៌ ។
ទិដ្ឋិទាំងអស់អាស្រ័យផស្សៈ បញ្ញាប្រចក្សអស់ការញាប់ញ័រ
អស់ការយល់ខុសឃើញសច្ចធម៌ ព្រះសូត្របវរសំណាញ់ព្រះញាណ ។

**សូមអនុមោទនា !**

# ២. សាមញ្ញផលសូត្រ

ព្រះដ៏មានព្រះភាគទ្រង់គង់នៅក្នុងវត្តអម្ពវន័ ជាវត្តដែលពេទ្យជីវកកោមារភច្ច វេរចម្ការស្វាយថ្វាយសង្ឃ ព្រមដោយសេនាសនៈផ្សេងៗ នៅជិតភ្នំគិជ្ឈកូដជាប់នឹងក្រុងរាជគ្រឹះ ក្នុងកាលនោះ ព្រះអង្គទ្រង់គង់នៅជាមួយនឹងភិក្ខុសង្ឃ ១២៥០ អង្គ។

ពេទ្យជីវកកោមារភច្ច នៅពេលថ្វាយសំពត់សាច់ល្អពីរផ្ទាំងដល់ព្រះដ៏មានព្រះភាគ នៅនាព្រះគន្ធកុដិលើភ្នំគិជ្ឈកូដ បានស្តាប់ព្រះធម៌ទេសនា សម្រេចសោតាបត្តិផលហើយ ទើបសាងវិហារថ្វាយដល់ព្រះដ៏មានព្រះភាគ ក្នុងចម្ការស្វាយរបស់គាត់ ។ ពេទ្យជីវកៈ បានរៀបចំក្នុងវត្តនោះ ដោយទីកន្លែងសម្រាប់ពេលថ្ងៃសម្រាប់ពេលយប់ រោងសម្រាក កុដិ និងសាលាជាដើម ហើយឱ្យសាងព្រះគន្ធកុដិដែលសមគួរដល់ព្រះដ៏មានព្រះភាគ និងឱ្យសាងកំពែងមានពណ៌ដូចជាសំពត់ក្រហម កម្ពស់ ១៨ ហត្ថព័ទ្ធជុំវិញចម្ការស្វាយ ថ្វាយចង្ហាន់ព្រមទាំងមើលថែភិក្ខុសង្ឃ មានព្រះសម្មាសម្ពុទ្ធជាព្រះប្រធាន ។

ពេទ្យជីវកៈនេះឯងដែលបានយាងព្រះបាទអជាតសត្តុ ឱ្យ

មកគាល់ព្រះដ៏មានព្រះភាគ ដើម្បីទូលសួរបញ្ហាអំពីផលនៃសមណប្បដិបត្តិដែលត្រូវឃើញច្បាស់ក្នុងបច្ចុប្បន្ន ។

ព្រះបាទអជាតសត្តុ មានព្រះហឫទ័យចង់គាល់ព្រះដ៏មានព្រះភាគ ប៉ុន្តែមិនអាចចូលគាល់ព្រះដ៏មានព្រះភាគដោយព្រះអង្គឯងបាន ទើបព្រះអង្គធ្វើនូវនិមិត្តដើម្បីឱ្យពេទ្យជីវកៈយាងព្រះអង្គទៅ ។ ហេតុអ្វីទើបស្តេចមិនហ៊ានចូលគាល់ព្រះដ៏មានព្រះភាគដោយព្រះអង្គឯង ព្រោះព្រះអង្គមានកំហុសច្រើន ។ ព្រះបាទអជាតសត្តុ បានធ្វើឃាតព្រះបិតារបស់ព្រះអង្គដែលជាឧបដ្ឋាកនៃព្រះដ៏មានព្រះភាគ ទាំងដែលព្រះបិតាជាអរិយសាវក័ ម្យ៉ាងទៀតភិក្ខុទេវទត្តបានអាស្រ័យនឹងព្រះបាទអជាតសត្តុនោះឯង ហើយធ្វើនូវកំហុសធំៗចំពោះព្រះដ៏មានព្រះភាគ ។

ព្រះរាជាអាស្រ័យពេទ្យជីវកៈ បានចូលគាល់ព្រះដ៏មានព្រះភាគ ស្តេចបានទតឃើញព្រះភិក្ខុសង្ឃ ១២៥០ អង្គ គង់នៅដោយសេចក្តីស្ងប់ស្ងាត់ ទ្រង់បានបន្លឺនូវឧទានវាចាដ៏ថ្លាស្អាតដូចជាអន្លង់ទឹកថ្លាថា ឥឡូវនេះ ភិក្ខុសង្ឃប្រកបដោយសេចក្តីស្ងប់រំងាប់ណា សូមឱ្យឧទយភទ្ទកុមារ ជាកូនរបស់យើង ប្រកបដោយសេចក្តីស្ងប់រំងាប់នេះឯង ។ ព្រះរាជាបានសូមឱកាសព្រះដ៏មានព្រះភាគសួរនូវបញ្ហា ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា

បពិត្រមហារាជ បើទ្រង់ប្រាថ្នានឹងសួរនូវប្រស្នាណា សូមទ្រង់សួរមកចុះ ។

សព្វញ្ញូបវារណា មិនទូទៅដល់ព្រះបច្ចេកពុទ្ធ ព្រះអគ្គ-សាវ័កនិងមហាសាវ័កទាំងឡាយឡើយ ព្រះដ៏មានព្រះភាគទ្រង់មាននូវសព្វញ្ញុតញ្ញាណ បានប្រទានឱកាសឱ្យអ្នកណាៗទាំងអស់ដែលមានបំណងសាកសួរ ដោយមិនមានពាក្យថា បើតថាគតដឹងតថាគតនឹងឆ្លើយ ដូច្នេះឡើយ ។

ព្រះរាជា ទ្រង់បានទូលសួរព្រះដ៏មានព្រះភាគអំពីផលនៃសមណប្បដិបត្តិដែលត្រូវឃើញច្បាស់ក្នុងបច្ចុប្បន្ន កាលដែលព្រះ-ដ៏មានព្រះភាគទ្រង់វិសជ្ជនាចប់ហើយ ព្រះរាជាបានពោលសរសើរព្រះធម៌ទេសនាដ៏ក្រៃលែង ហើយបានសូមដល់ព្រះពុទ្ធ ព្រះធម៌ព្រះសង្ឃ ជាទីពឹងទីរលឹក ព្រមទាំងបានសូមខមាទោសដោយពាក្យថា បពិត្រព្រះអង្គដ៏ចម្រើន ទោសកំហុសប្រព្រឹត្តកន្លងនូវខ្ញុំ-ព្រះអង្គ តាមដែលខ្ញុំព្រះអង្គជាមនុស្សល្ងង់ខ្លៅ ជាមនុស្សវង្វេងជាមនុស្សមិនឈ្លាសវៃ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គណាបានផ្តាច់បង់នូវព្រះជន្មាយុនៃព្រះបិតាដែលប្រកបដោយធម៌ ជាព្រះធម្មរាជ ព្រោះតែឥស្សរិយយស (គឺប្រាថ្នាចង់ធ្វើស្តេចខ្លួនឯង) បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះដ៏មានព្រះភាគ អត់នូវទោស

កំហុស តាមទោសកំហុសរបស់ខ្ញុំព្រះអង្គនោះ ដើម្បីនឹងសង្រួមតទៅ ។ កាលដែលព្រះបរមសាស្តា ទ្រង់អត់ទោសឱ្យហើយ ព្រះរាជាក៏បានថ្វាយបង្គំលាព្រះដ៏មានព្រះភាគ ធ្វើប្រទក្សិណ រួចស្តេចយាងចេញទៅ ។

កាលដែលស្តេចយាងចេញទៅមិនយូរប៉ុន្មាន ព្រះដ៏មាន-ព្រះភាគទ្រង់ត្រាស់ចំពោះភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ព្រះរាជាអង្គនេះ ជីករំលើងគុណធម៌របស់ខ្លួនចេញអស់ហើយ ម្នាលភិក្ខុទាំងឡាយ ព្រះរាជាអង្គនេះ ផ្តាច់បង់គុណធម៌របស់ខ្លួនចេញអស់ហើយ ម្នាលភិក្ខុទាំងឡាយ ប្រសិនបើព្រះរាជាអង្គនេះមិនបានផ្តាច់បង់ព្រះជន្មាយុនៃព្រះបិតាដែលប្រកបដោយធម៌ ជាព្រះធម្មរាជទេ ធម្មចក្ខុគឺសោតាបត្តិមគ្គ ដែលប្រាសចាកធូលី ប្រាសចាកមន្ទិល នឹងកើតឡើងដល់ព្រះរាជា លើអាសនៈនេះមិនខានឡើយ ។

ព្រះបាទអជាតសត្តុ បានស្តាប់ព្រះសូត្រនេះហើយ ទ្រង់បានអានិសង្សច្រើនណាស់ ព្រោះថា ចាប់តាំងអំពីធ្វើឃាតព្រះ-បិតារួចមក ទ្រង់មិនដែលផ្ទំលក់ឡើយ ទាំងយប់ទាំងថ្ងៃ តែដល់ពេលបានគាល់ព្រះបរមសាស្តា និងបានស្តាប់ព្រះធម៌ទេសនាដ៏ពីរោះមានឱជានេះហើយ ទើបទ្រង់បានផ្ទំលក់ ហើយព្រះរាជា

បានធ្វើសក្ការៈដ៏ក្រៃលែងចំពោះព្រះរតនត្រ័យ គឺមិនមានបុថុជ្ជនណាដែលប្រកបដោយសទ្ធាស្មើនឹងព្រះរាជាអង្គនេះឡើយ ក្នុងអនាគតនឹងបានជាព្រះបច្ចេកពុទ្ធ ព្រះនាមថា **ជីវិតវិសេស** ។

## ជីវកម្ពវ័ន

ជីវកម្ពវ័នបន្ទន់ចិត្តនឹក រលឹកឃើញបុណ្យគុណអ្នកកសាង
សម្រេចសោតាមបាសំណាង ស្ថិតស្ថាងដោយទាននិព្វានសុខា ។
ជីវកម្ពវ័នបន្ទន់ចិត្តនឹក រលឹកឃើញសង្ឃជុំអង្គសាស្តា
ព្រះពុទ្ធទ្រង់ត្រាស់ឆ្លើយដោះប្រស្នា បញ្ហាអង្គក្សត្រកាត់បង់សង្ស័យ ។
សាមញ្ញផលផ្តល់ជាឱវាទ អ្នកបួសស្អាងស្អាតឃ្លាតចាកភពត្រៃ
មានផលសុខស្ងប់ប្រសព្វរាល់ថ្ងៃ សមណៈល្អក្រៃដោយត្រៃសិក្ខា ។
សាមញ្ញផលផ្តល់ជាឱវាទ អ្នកបួសស្អាងស្អាតមានបាទសីលា
ចូលកាន់មាគ៌ាមជ្ឈិមាយាត្រា សមណៈថ្លៃថ្លាទេវតាបូជា ។

**សូមអនុមោទនា !**

# ៣. អម្ពដ្ឋសូត្រ

ព្រះដ៏មានព្រះភាគ ទ្រង់ពុទ្ធដំណើរព្រមដោយភិក្ខុសង្ឃ ៥០០ អង្គ ទៅដល់ស្រុកព្រាហ្មណ៍ឈ្មោះឥច្ឆានង្គលៈនៃដែនកោ-សល ព្រះអង្គនិងភិក្ខុសង្ឃបានគង់នៅក្នុងទីនោះ ។

បោក្ខរសាតិព្រាហ្មណ៍ បានចូលក្នុងសំណាញ់ញាណនៃព្រះអង្គរួចស្រេចហើយ គឺនៅពេលដែលព្រះដ៏មានព្រះភាគទ្រង់ផ្សាយព្រះញាណទៅក្នុងម៉ឺនលោកធាតុ តាមពុទ្ធកិច្ចក្នុងបច្ឆិម-យាមនៃរាត្រី ។ ព្រាហ្មណ៍នេះ កាលពីសាសនានៃព្រះសម្មាសម្ពុទ្ធកស្សបទសពល បានរៀនចប់ត្រៃវេទ បានថ្វាយទានដល់ព្រះ-សម្មាសម្ពុទ្ធហើយស្តាប់ព្រះធម៌ទេសនា អស់ជីវិតទៅកើតក្នុងទេវលោក ដោយការរង្កៀសចំពោះការតាំងនៅក្នុងគភ៌មាតា បុណ្យបានរៀបចំឱ្យកើតក្នុងផ្កាឈូក នាដែនដីនៃព្រៃហិមពាន្ត ត្រូវបានតាបសនាំយកមកចិញ្ចឹម ហើយបង្ហាត់បង្រៀនចប់គម្ពីរត្រៃ-វេទ ជាបណ្ឌិតដ៏ឈ្លាសវៃ ជាកំពូលព្រាហ្មណ៍ក្នុងជម្ពូទ្វីប ។ ប្រជាជនទាំងឡាយហៅព្រាហ្មណ៍ថា បោក្ខរសាតិ ព្រោះហេតុដែលព្រាហ្មណ៍បដិសន្ធិក្នុងផ្កាឈូក ។ ព្រាហ្មណ៍បានសម្តែង

សិល្បៈដល់ព្រះបាទកោសល ព្រះរាជាជ្រះថ្លាហើយ ក៏បានព្រះ-រាជទានមហានគរឈ្មោះឧក្កដ្ឋៈ ឱ្យជារង្វាន់ដ៏ប្រសើរដល់បោក្ខរ-សាតិព្រាហ្មណ៍នោះឯង ។

បោក្ខរសាតិព្រាហ្មណ៍ បានជ្រាបថាព្រះដ៏មានព្រះភាគទ្រង់គង់នៅឥច្ឆានង្គលៈ ដោយព្រាហ្មណ៍ធ្លាប់បានឮព្រះកិត្តិសព្ទគឺពាក្យសរសើរដ៏ក្រៃលែង ចំពោះព្រះគុណនៃព្រះដ៏មានព្រះភាគទើបព្រាហ្មណ៍ចាត់ចែងឱ្យកូនសិស្ស ឈ្មោះអម្ពដ្ឋៈ ព្រមដោយមាណពច្រើននាក់ មកកាន់សម្នាក់ព្រះដ៏មានព្រះភាគដើម្បីពិនិត្យមើលមហាបុរិសលក្ខណៈ ៣២ ប្រការ ។ អម្ពដ្ឋៈរៀនចេះចប់ត្រៃវេទដូចជាគ្រូដែរ ប៉ុន្តែចរិតមិនថ្លៃថ្នូរ ទាំងខ្វះឧបនិស្ស័យមិនបានសូម្បីដល់ព្រះរតនត្រៃជាទីពឹងទីរលឹកផង គេពោលពាក្យឆ្លើយឆ្លងនឹងព្រះដ៏មានព្រះភាគ ដោយពាក្យមិនសុភាពរាបសាមានប្រការផ្សេងៗ ។ ព្រះដ៏មានព្រះភាគ បានទូន្មានអម្ពដ្ឋៈ ធ្វើឱ្យអម្ពដ្ឋៈហើបមាត់ក្អេងក្អាងមិនរួច គេបាននាំពាក្យទាំងឡាយទៅប្រាប់បោក្ខរសាតិព្រាហ្មណ៍ជាគ្រូ ដែលធ្វើឱ្យគ្រូស្ដីបន្ទោសឱ្យដោយពាក្យខ្លាំងៗ ថែមទាំងធាក់មួយជើងធ្វើឱ្យអម្ពដ្ឋៈជាសិស្សដួលទៅនឹងដីទៀតផង រឿងនេះ ដោយសារព្រាហ្មណ៍ខឹងថា មិនសមសិស្សរបស់ខ្លួនទៅឆ្លើយឆ្លងនូវពាក្យមិនសុភាពរាបសាជាមួយ

នឹងព្រះដ៏មានព្រះភាគឡើយ ព្រាហ្មណ៍ចង់មកសូមខមាទោសភ្លាមៗ តែដោយកាលមិនសមគួរ ។

ស្អែកឡើង ពេលព្រឹកព្រលឹម ទើបបោក្ខរសាតិព្រាហ្មណ៍បានមកគាល់ព្រះដ៏មានព្រះភាគ ពោលពាក្យសំណេះសំណាលហើយបានទូលព្រះដ៏មានព្រះភាគថា បពិត្រព្រះគោតមដ៏ចម្រើនអម្ពដ្ឋមាណពជាមនុស្សល្ងង់ សូមព្រះគោតមដ៏ចម្រើនអត់ទោសដល់អម្ពដ្ឋមាណពផងចុះ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថាម្នាលព្រាហ្មណ៍ សូមឱ្យអម្ពដ្ឋមាណពមានសេចក្តីសុខចុះ ។ ព្រាហ្មណ៍បានពិនិត្យឃើញមហាបុរិសលក្ខណៈ ៣២ ប្រការនៃព្រះដ៏មានព្រះភាគ ហើយបានអារាធនាយាងព្រះអង្គព្រមដោយភិក្ខុសង្ឃ ទទួលចង្ហាន់ក្នុងថ្ងៃហ្នឹងឯង ។ ព្រាហ្មណ៍ថ្វាយចង្ហាន់ហើយស្តាប់ព្រះធម៌ទេសនា បានតាំងនៅក្នុងសោតាបត្តិផលសរសើរព្រះធម៌ដ៏ក្រៃលែង ទាំងបានប្រកាសថា បពិត្រព្រះ-គោតមដ៏ចម្រើន ខ្ញុំព្រះអង្គព្រមទាំងបុត្រភរិយា ទាំងបរិស័ទ ទាំងអមាត្យ សូមដល់នូវព្រះគោតមដ៏ចម្រើនផង នូវព្រះធម៌ផង នូវព្រះសង្ឃផង ជាសរណៈ សូមព្រះគោតមដ៏ចម្រើនចាំទុកនូវខ្ញុំ-ព្រះអង្គ ថាជាឧបាសកអ្នកដល់នូវព្រះរតនត្រ័យ ជាសរណៈស្មើដោយជីវិត តាំងពីថ្ងៃនេះជាដើមរៀងទៅ ម្យ៉ាងទៀត បើព្រះ-

គោតមដ៏ចម្រើន ស្តេចចូលទៅរកត្រកូលឧបាសកឯទៀត ក្នុងឧក្កដ្ឋនគរយ៉ាងណា សូមព្រះគោតមដ៏ចម្រើន ចូលមករកត្រកូលបោក្ខរសាតិ ក៏យ៉ាងនោះដែរ ដូច្នេះនឹងបានពួកមនុស្សកំលោះក្រមុំណាក្នុងត្រកូលនោះៗ ក្រាបថ្វាយបង្គំ ក្រោកទទួល ឬថ្វាយអាសនៈ ឬក៏ថ្វាយទឹក ហើយមានចិត្តជ្រះថ្លាចំពោះព្រះគោតមដ៏-ចម្រើន ដោយកិច្ចមានការក្រាបថ្វាយបង្គំជាដើមនោះ នឹងប្រព្រឹត្តទៅជាប្រយោជន៍ ប្រកបដោយសេចក្តីសុខដល់ពួកជនកំលោះក្រមុំទាំងនោះ អស់កាលជាអង្វែង ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលព្រាហ្មណ៍ ពាក្យដែលអ្នកពោលមកនេះ ពីរោះហើយ ។

**សូមអនុមោទនា !**

# ៤. សោណទណ្ឌសូត្រ

ព្រះដ៏មានព្រះភាគ ទ្រង់ពុទ្ធដំណើរទៅកាន់ចារិក ក្នុងអង្គជនបទ ព្រមដោយភិក្ខុសង្ឃ ៥០០ អង្គ ។ ព្រះសុគតសាស្ដាទ្រង់គង់នៅមាត់ស្រះបោក្ខរណី ឈ្មោះគគ្គរា ជិតក្រុងចម្ប៉ា ក្នុងនគរដែលសម្បូណ៌ទៅដោយដើមចម្ប៉ា មានផ្កាឈើ ៥ ពណ៌ ។

សោណទណ្ឌព្រាហ្មណ៍ ជាព្រាហ្មណ៍ល្បីល្បាញដោយមន្តដោយសិស្សនិងដោយទ្រព្យជាដើម មានសភាពដូចជាបោក្ខរសាតិព្រាហ្មណ៍ដែរ គ្រាន់តែសោណទណ្ឌព្រាហ្មណ៍អាស្រ័យនៅក្រុងចម្ប៉ា ជាព្រះរាជទ្រព្យដែលព្រះបាទពិម្ពិសារទ្រង់ប្រទានជារាជរង្វាន់ដ៏ប្រសើរ ឯចំណែកបោក្ខរសាតិព្រាហ្មណ៍ ទទួលរាជរង្វាន់ដ៏ប្រសើរអំពីព្រះបាទបសេនទិកោសល ម្យ៉ាងទៀតសោណទណ្ឌព្រាហ្មណ៍នេះ ចូលក្នុងសំណាញ់ព្រះញាណនៃព្រះពុទ្ធអង្គ មានឧបនិស្ស័យត្រឹមតែដល់ព្រះត្រៃសរណគមន៍និងថ្វាយទានជាដើមប៉ុណ្ណោះ មិនបានសម្រេចដល់សោតាបត្តិផលដូចបោក្ខរសាតិព្រាហ្មណ៍ឡើយ ។

កាលដែលសោណទណ្ឌព្រាហ្មណ៍ មានបំណងមកគាល់

ព្រះដ៏មានព្រះភាគ សិស្សទាំងឡាយរាប់រយនាក់របស់គាត់ បាន ពោលឃាត់ថា « លោកអាចារ្យមិនត្រូវទៅរកព្រះគោតមទេ ត្រូវតែព្រះគោតមមករកលោកអាចារ្យវិញទើបគួរ » ពួកសិស្សទាំង-នោះ បានពោលសរសើរសោណទណ្ឌព្រាហ្មណ៍ដោយអាការ ១២ យ៉ាង មានឧភតោសុជាតជាដើម ។

សោណទណ្ឌព្រាហ្មណ៍ បានទម្លាយវាទៈរបស់កូនសិស្សទាំងនោះ ដោយការពោលសរសើរព្រះពុទ្ធអង្គ ២៩ ប្រការ គឺ

១- ឧភតោសុជាត ទ្រង់មានជាតិដ៏ល្អទាំងពីរចំណែក

២- ទ្រង់លះបង់ពពួកញាតិ ១ សែន ៦ ម៉ឺនអង្គ មកបួស

៣- ទ្រង់លះបង់កំណប់ទ្រព្យទាំង ៤ ជាដើម មកបួស

៤- ទ្រង់តាំងនៅក្នុងបឋមវ័យ លះបង់រាជសម្បត្តិមកបួស

៥- ទ្រង់ត្រូវគេហួងហែងមិនឱ្យបួស នៅតែយាងមកបួស

៦- ទ្រង់មានរូបសម្បត្តិ និងព្រះឆវីដ៏ល្អក្រៃលែង

៧- ទ្រង់មាននូវកុសលសីល ជាសីលដ៏ប្រសើរ

៨- ទ្រង់មានព្រះវាចាសុភាព និងមានពាក្យពីរោះ

៩- ទ្រង់ជាអាចារ្យធំ ជាងអាចារ្យនៃជនជាច្រើន

១០- ទ្រង់អស់កាមរាគៈហើយ មិនមានស្រើបស្រាល

១១- ទ្រង់ជាកម្មវាទី ធ្វើនូវលោកុត្តរធម៌ឱ្យជាប្រធាន

១២- ទ្រង់ចេញចាកត្រកូលក្សត្រិយ៍មកទ្រង់ព្រះផ្នួស
១៣- ទ្រង់ចេញចាកត្រកូលដ៏ស្តុកស្តម្ភមកទ្រង់ព្រះផ្នួស
១៤- ទ្រង់មានពួកមនុស្សក្នុងដែនដទៃមកសួរប្រស្នា
១៥- ទ្រង់មានពួកទេវតាយកជាសរណៈស្មើដោយជីវិត
១៦- ទ្រង់មានពុទ្ធគុណទាំង ១០ ល្បីសុសសាយ
១៧- ទ្រង់ប្រកបដោយមហាបុរិសលក្ខណៈ ៣២ ប្រការ
១៨- ទ្រង់មានព្រះវាចារាក់ទាក់ ព្រះភក្ត្រស្វាគមន៍
១៩- ទ្រង់មានបរិស័ទបួនពួក ធ្វើសក្ការៈ គោរពបូជា
២០- ទ្រង់មានមនុស្សនិងទេវតាដ៏ច្រើនជ្រះថ្លា
២១- ទ្រង់គង់នៅទីណា ពួកមនុស្សមិនបៀតបៀនគ្នា
២២- ទ្រង់ប្រសើរជាងពួកតិរ្ថិយដោយវិជ្ជានិងចរណៈ
២៣- ទ្រង់ជាសរណៈស្មើដោយជីវិតនៃព្រះបាទពិម្ពិសារ
២៤- ទ្រង់ជាសរណៈស្មើដោយជីវិតនៃព្រះបាទបសេនទិ
២៥- ទ្រង់ជាសរណៈស្មើដោយជីវិតនៃបោក្ខរសាតិ
២៦- ទ្រង់ត្រូវបានព្រះបាទពិម្ពិសារ ធ្វើសក្ការបូជា
២៧- ទ្រង់ត្រូវបានព្រះបាទបសេនទិ ធ្វើសក្ការបូជា
២៨- ទ្រង់ត្រូវបានបោក្ខរសាតិព្រាហ្មណ៍ធ្វើសក្ការបូជា
២៩- ទ្រង់ជាភ្ញៀវដែលពួកយើងត្រូវធ្វើសក្ការបូជា ។

ព្រោះហេតុនោះ ព្រះសមណគោតមដ៏ចម្រើននោះ មិនគួរចូលមកជួបនឹងយើងទេ តាមដែលពិតនោះ យើងទេតើ ដែលគួរចូលទៅគាល់ព្រះសមណគោតមដ៏ចម្រើននោះវិញ ។ យើងរៀបរាប់គុណរបស់ព្រះគោតមដ៏ចម្រើនបានតែប៉ុណ្ណេះ ឯព្រះគោតមដ៏ចម្រើននោះ មិនមែនមានគុណត្រឹមតែប៉ុណ្ណេះទេ ព្រោះថាព្រះគោតមដ៏ចម្រើននោះ មានគុណប្រមាណពុំបាន ។ អ្នកទាំងឡាយ យកយើងទៅប្រៀបធៀបជាមួយនឹងព្រះសមណគោតមដ៏ចម្រើននោះ ដូចយកគ្រាប់ស្ពៃទៅប្រៀបធៀបជាមួយនឹងភ្នំសុនេរុ ឬយកស្នាមជើងគោទៅប្រៀបធៀបជាមួយនឹងមហាសមុទ្រ ពុំនោះសោត ដូចយកតំណក់ទឹកសន្សើមទៅប្រៀបធៀបជាមួយនឹងទឹកក្នុងស្រះធំទាំង ៧ ស្រះ ដូច្នោះឯង ។

កាលដែលសោណទណ្ឌព្រាហ្មណ៍ ពោលយ៉ាងនេះហើយ ពួកព្រាហ្មណ៍ជាសិស្សទាំងនោះ បាននិយាយថា អម្បាលយ៉ាងសោណទណ្ឌដ៏ចម្រើន ម្តេចគង់ពោលសរសើរគុណព្រះសមណគោតមទៅហើយ ព្រោះហេតុនោះ បើទុកជាព្រះសមណគោតមដ៏ចម្រើននោះ គង់នៅទីឆ្ងាយមួយរយយោជន៍អំពីទីនេះក្តី កុលបុត្រដែលមានសទ្ធា គួរណាស់តែរកស្បៀងយកទៅ ដើម្បីនឹងចូលគាល់ព្រះអង្គឱ្យខាងតែបាន ។

ក្រោយពីបទសន្ទនា រវាងព្រះដ៏មានព្រះភាគនិងសោណទណ្ឌព្រាហ្មណ៍មក បញ្ហានៅត្រង់សីលជម្រះបញ្ញា ឯបញ្ញាជម្រះសីល ។ សោណទណ្ឌព្រាហ្មណ៍ គាត់ដឹងត្រឹមតែសីល ៥ ប៉ុណ្ណោះ ហើយបញ្ញត្តការចេះដឹងក្នុងត្រៃវេទថាជាបញ្ញា ព្រោះហេតុដូច្នោះ ទើបព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សម្តែងសីលនិងបញ្ញាដូចក្នុងសាមញ្ញផលសូត្រ ។ ព្រះអដ្ឋកថា ពន្យល់អំពីសីលជម្រះបញ្ញា នៅត្រង់ថា សីលល្អរបស់ភិក្ខុបុថុជ្ជនបួសពី ៦០ ទៅ ៨០ វស្សា ដល់ពេលជិតនឹងធ្វើកាលកិរិយា បានប្រហារកិលេសសម្រេចព្រះអរហត្ត នេះឈ្មោះថា ជម្រះបញ្ញាដោយសីល ដូចព្រះមហាសដ្ឋិវស្សត្ថេរជាដើម ។ ឯចំណែកបុគ្គលជម្រះសីលដោយបញ្ញា ដូចសន្តតិមហាមាត្យជាដើម គឺមិនបានសង្រួមក្នុងសីលឡើយ តែព្រោះហេតុដែលខ្លួនជាបុគ្គលត្រាស់ដឹងបានដោយឆាប់ ក្នុងគាថាបួនបាទ ក៏បានជម្រះសីលដោយបញ្ញា សម្រេចព្រះអរហត្តព្រមដោយបដិសម្ភិទា ។

ព្រះធម៌ទេសនារបស់ព្រះដ៏មានព្រះភាគ ជាប្រយោជន៍ដល់សោណទណ្ឌព្រាហ្មណ៍បានឧបនិស្ស័យ សម្រេចដល់ព្រះនិព្វានក្នុងកាលតទៅ ។ **សូមអនុមោទនា !**

# ព្រះសុត្តន្តបិដកខ្មែរលេខ ១៥

## ទីឃនិកាយ សីលក្ខន្ធវគ្គ មាន ៩ ព្រះសូត្រ គឺ

១- កូដទន្តសូត្រ
២- មហាលិសូត្រ
៣- ជាលិយសូត្រ
៤- មហាសីហនាទសូត្រ
៥- បោដ្ឋបាទសូត្រ
៦- សុភសូត្រ
៧- កេវដ្តសូត្រ
៨- លោហិច្ចសូត្រ
៩- តេវិជ្ជសូត្រ ។

## ពាក្យគួរយល់ដឹង

≈≈≈≈≈≈≈≈≈≈≈≈≈≈≈

**សីលក្ខន្ធវគ្គ** មាន ១៣ សូត្រ ព្រះអង្គទ្រង់ត្រាស់សម្ដែង អំពី ចូឡសីល មជ្ឈិមសីល និងមហាសីល ។

# ១~ កូដទន្តសូត្រ

ព្រះដ៏មានព្រះភាគ មួយអន្លើដោយភិក្ខុសង្ឃ ៥០០ អង្គ ទ្រង់គង់ប្រថាប់នៅក្នុងឧទ្យានឈ្មោះអម្ពលដ្ឋិកា ជិតខានុមត្តគ្រាម ក្នុងដែនមគធៈ ។ ក្នុងកាលនោះ កូដទន្តព្រាហ្មណ៍ ជាអ្នកគ្រប់គ្រងខានុមត្តគ្រាម ដែលព្រះបាទពិម្ពិសារទ្រង់ព្រះរាជទានជាអំណោយដ៏ប្រសើរ។ ព្រាហ្មណ៍នោះ ចូលក្នុងសំណាញ់ញាណ មានឧបនិស្ស័យនៃសោតាបត្តិផល ព្រះដ៏មានព្រះភាគ ទ្រង់យាងមកដើម្បីជាប្រយោជន៍ដល់ព្រាហ្មណ៍ ដោយព្រះហឫទ័យអនុគ្រោះចំពោះសត្វលោក ។ ព្រាហ្មណ៍កំពុងតែចាត់ចែងមហាយញ្ញ ដែលជាការបូជាដ៏ធំតាមសេចក្ដីល្ងង់ខ្លៅ គឺត្រូវសម្លាប់គោឈ្មោល ៧០០, កូនគោឈ្មោល ៧០០, កូនគោញី ៧០០, ពពែ ៧០០, កែះ ៧០០ ។ល។ ប៉ុន្តែសំណាងល្អ មិនទាន់បានសម្លាប់ គ្រាន់តែចងទុកនឹងបង្គោលហើយប៉ុណ្ណោះ ក៏បានជ្រាបដំណឹងថាព្រះដ៏មានព្រះភាគស្ដេចយាងមក គង់ប្រថាប់នៅទីជិត ទាំងពួកព្រាហ្មណ៍ដទៃ គហបតីអ្នកស្រុកខានុមត្តៈ ជាពួក ជាក្រុម ជាគណៈ ចូលសំដៅទៅកាន់អម្ពលដ្ឋិកាឧទ្យាន ។ ព្រាហ្មណ៍

បានស្តាប់ឮព្រះកិត្តិសព្ទសរសើរព្រះដ៏មានព្រះភាគ ក៏មានសេចក្តីត្រិះរិះដូច្នេះថា យើងបម្រុងនឹងបូជានូវមហាយញ្ញ ប៉ុន្តែយើងមិនបានដឹងនូវយញ្ញសម្បទា ៣ ប្រការ ដែលមានបរិក្ខារ ១៦ ឡើយ បើដូច្នេះ មានតែយើងចូលទៅសួរព្រះគោតម ចំពោះសេចក្តីនេះ ។

កូដទន្តព្រាហ្មណ៍ មានសិស្សឃាត់មិនឱ្យទៅគាល់ព្រះ-សម្មាសម្ពុទ្ធ ប៉ុន្តែព្រាហ្មណ៍ក៏បានពោលសរសើរព្រះដ៏មានព្រះ-ភាគ ២៩ ប្រការដូចសោណទណ្ឌព្រាហ្មណ៍ដែរ ។ កាលដែលបានចូលគាល់ព្រះសម្ពុទ្ធបរមគ្រូ ព្រាហ្មណ៍ក៏បានទូលសួរនូវសំណួរដូចដែលបានគិតទុកហើយ ។ ព្រះដ៏មានព្រះភាគ ទ្រង់លើកយកអតីតជាតិរបស់ព្រះអង្គជាព្រាហ្មណ៍បុរោហិត ជាមួយនឹងព្រះ-បាទមហាវិជិតរាជ មកប្រកាសសម្តែងនៅក្នុងព្រះសូត្រនេះ ហើយព្រះអង្គទ្រង់សរុបឡើងវិញថា ម្នាលព្រាហ្មណ៍ ជនទាំងបួនពួកមានគំនិតយល់ត្រូវគ្នា ១, ព្រះបាទមហាវិជិតរាជ ប្រកបដោយអង្គប្រាំបីប្រការ ១, ព្រាហ្មណ៍បុរោហិត (គឺព្រះបរមពោធិសត្វ ) ប្រកបដោយអង្គបួនប្រការ ១, រួមបានជាយញ្ញវិធីបីយ៉ាង នេះហៅថា យញ្ញសម្បទា ៣ យ៉ាង មានបរិក្ខារ ១៦ ដោយប្រការដូច្នេះឯង ។

ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សម្ដែងនូវការបរិច្ចាគទានដ៏យ៉ាងគគ្រឹកគគ្រេង ដែលព្រះបាទមហាវិជិតរាជមានព្រះបរម-ពោធិសត្វជាទីប្រឹក្សា បានបំពេញហើយ ហៅថាយញ្ញសម្បទា មិនមែនជាការសម្លាប់សត្វបូជាទេវតាជាដើមនោះទេ ។

ព្រាហ្មណ៍ទាំងឡាយ បានស្ដាប់អំពីយញ្ញសម្បទា ៣ ប្រការហើយ ក៏មានចិត្តត្រេកអរ ពោលសរសើរយញ្ញថា អើហ្ន៎ ! យញ្ញ-សម្បទា ។ ចំណែកកូដទន្តព្រាហ្មណ៍ពោលថា បើបុគ្គលណាមិនត្រេកអររីករាយនឹងសុភាសិតរបស់ព្រះសមណគោតម ដោយពាក្យជាសុភាសិតទេ ក្បាលរបស់បុគ្គលនោះនឹងបែកមិនខានឡើយ ។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលព្រាហ្មណ៍ តថាគតដឹងច្បាស់ថា បុគ្គលបូជាដោយខ្លួនឯងក្ដី ឱ្យគេបូជាក្ដី នូវយញ្ញមានសភាពយ៉ាងនេះ លុះទម្លាយរាងកាយបន្ទាប់អំពីសេចក្ដីស្លាប់ នឹងបានចូលទៅកាន់លោក គឺមនុស្សសុគតិនិងឋានសួគ៌ ម្នាលព្រាហ្មណ៍ សម័យនោះ តថាគតជាព្រាហ្មណ៍បុរោហិត ជាអ្នកណែនាំឱ្យព្រះបាទមហាវិជិតរាជបូជាយញ្ញ ។

កាលដែលកូដទន្តព្រាហ្មណ៍ ទូលសួរតៗទៅទៀតនូវយញ្ញដទៃដែលមានសេចក្ដីត្រូវការដោយវត្ថុតិច មានគ្រឿងប្រុងប្រៀបតិច តែមានផលច្រើន មានអានិសង្សច្រើនជាងយញ្ញសម្បទា ៣

ប្រការដែលមានបរិក្ខារ ១៦ នោះ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់តាមលំដាប់លំដោយគឺ

- និច្ចភត្តទាន គឺយញ្ញដែលប្រព្រឹត្តទៅតាមលំដាប់ត្រកូលណា ដែលគេឱ្យចំពោះពួកបព្វជិតអ្នកមានសីល ។

- វិហារទានចំពោះសង្ឃដែលនិមន្តមកអំពីទិសទាំង ៤ ។

- ចិត្តជ្រះថ្លា ដល់នូវព្រះពុទ្ធជាសរណៈ ដល់នូវព្រះធម៌ ជាសរណៈ ដល់នូវព្រះសង្ឃជាសរណៈ ។ ការដល់សរណៈនេះ ហៅថាយញ្ញ ព្រោះទាក់ទងនឹងការបរិច្ចាគជីវិតដល់ព្រះរតនត្រ័យ ។

- ចិត្តជ្រះថ្លា សមាទាននូវសិក្ខាបទទាំងឡាយ ៥ ។ សីល ៥ នេះ ហៅថាយញ្ញ ព្រោះត្រូវសមាទានដោយគិតថា យើងត្រូវលះបង់ការជាប់ជំពាក់នឹងខ្លួនឯង ព្រមទាំងការជាប់ជំពាក់ក្នុងជីវិតហើយរក្សាឱ្យបានល្អ ។ បណ្តាសីលនិងសរណគមន៍នោះ គឺសរណគមន៍ប្រាកដជាធំជាងសីល ៥ ប៉ុន្តែសីល ៥ នេះ ដែលព្រះអង្គត្រាស់ថាមានផលច្រើនជាង ព្រោះដោយអំណាចនៃសីលដែលបុគ្គលតាំងនៅក្នុងត្រៃសរណគមន៍ ហើយរក្សា ។

- សីលក្ខន្ធរបស់បព្វជិតរហូតដល់ឈានសមាបត្តិ ។ ឈាននោះឯង ឈ្មោះថាយញ្ញ ព្រោះលះបង់បាននូវធម៌ដែលជាសត្រូវមាននីវរណៈជាដើម ។

- វិបស្សនាញាណមានផលច្រើន ព្រោះមិនមានសុខខាងដើមណា ឱ្យដូចជាសុខដែលកើតអំពីវិបស្សនាឡើយ ។ វិបស្សនាហៅថាយញ្ញ ព្រោះលះបង់បាននូវកិលេសដែលជាសត្រូវនឹងវិបស្សនានោះឯង ។

- អាសវក្ខយញ្ញាណ ជាបន្តបន្ទាប់ក្នុងវិជ្ជា ៨ ។ ដែលឈ្មោះថាយញ្ញ មិនមានយញ្ញណាដែលប្រសើរជាងព្រះអរហត្តមគ្គនេះឡើយ ព្រោះធ្វើអាសវៈទាំងពួងឱ្យអស់ទៅ ។ មានផលច្រើនព្រោះបានញ៉ាំងសុខយ៉ាងប្រណីតក្រៃលែងឱ្យសម្រេចបាន ដូច្នោះហើយ ទើបព្រះដ៏មានព្រះភាគ ទ្រង់សម្តែងព្រះធម៌ទេសនាប្រកាសព្រះអរហត្តជាទីបំផុត គឺមិនមានយញ្ញសម្បទាឯទៀតលើសលប់ថ្លៃថ្លាជាងយញ្ញសម្បទានេះទេ ។

កូដទន្តព្រាហ្មណ៍ ជ្រះថ្លាហើយសរសើរព្រះធម៌ទេសនាប្រកាសខ្លួនសូមដល់ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជាសរណៈស្មើដោយជីវិត ។ ព្រាហ្មណ៍បានចាត់ឱ្យគេទៅដោះលែងសត្វទាំង-ឡាយ ឱ្យសត្វដ៏ច្រើននោះបាននូវជីវិត ទំពាស៊ីស្មៅស្រស់ផង ផឹកទឹកត្រជាក់ផង ឱ្យខ្យល់ត្រជាក់ស្រួលបក់មកត្រូវសត្វទាំងនោះផង ។ ដរាបណា ព្រាហ្មណ៍មិនទាន់បានទទួលដំណឹងថា សត្វទាំងឡាយត្រូវបានដោះលែងហើយ ដរាបនោះ ព្រះដ៏មានព្រះ-

ភាគ ទ្រង់មិនទាន់សម្តែងព្រះធម៌បន្តទៀតឡើយ ព្រោះក្នុងចិត្តរបស់ព្រាហ្មណ៍នៅមានភាពក្រវាយក្រវល់ លុះដល់ពេលបានឮថា សត្វទាំងនោះត្រូវបានពួកយើងខ្ញុំដោះលែងអស់ហើយ ដូច្នេះវារៈចិត្តរបស់ព្រាហ្មណ៍ក៏បានស្រស់ថ្លា ស្ងប់ការខ្វាយខ្វល់ ។ ព្រះដ៏មានព្រះភាគទ្រង់ជ្រាបថា ព្រាហ្មណ៍មានចិត្តថ្លាស្អាតហើយស្រួលបួលហើយ ទើបព្រះអង្គត្រាស់សម្តែងអនុបុព្វីកថា ។ កូដ-ទន្តព្រាហ្មណ៍ មានចិត្តស្រួល ទន់ ប្រាសចាកនីវរណៈ និងមានចិត្តអណ្តែតឡើងប្រកបដោយសេចក្តីជ្រះថ្លា អាស្រ័យការបានស្តាប់អនុបុព្វីកថា កាលនោះ ព្រះដ៏មានព្រះភាគទ្រង់ប្រកាសសម្តែងចតុរារិយសច្ច ព្រាហ្មណ៍ក៏បានតាំងនៅក្នុងសោតាបត្តិផល ហើយអារាធនាព្រះពុទ្ធអង្គព្រមទាំងភិក្ខុសង្ឃ ទទួលចង្ហាន់ក្នុងថ្ងៃស្អែក។ ព្រះដ៏មានព្រះភាគ ទ្រង់ទទួលដោយតុណ្ហីភាព ។

**សូមអនុមោទនា !**

# ២. មហាលិសូត្រ

ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅកូដាគារសាលានាមហាវន័ជិតក្រុងវេសាលី ។ ក្នុងកាលនោះ មានព្រាហ្មណទូតមកពីដែនកោសលផង មកពីដែនមគធៈផង បំណងនឹងគាល់ព្រះអង្គ មិនត្រឹមតែប៉ុណ្ណោះ មានក្សត្រិយ៍លិច្ឆវីព្រះនាមមហាលិ ព្រមដោយបរិស័ទយ៉ាងច្រើន ក៏យាងមកដើម្បីនឹងគាល់ព្រះដ៏មានព្រះភាគដែរ ។ ព្រះនាគិតត្ថេរ បានពោលថា កាលនេះ មិនមែនជាកាលគួរនឹងគាល់ព្រះដ៏មានព្រះភាគទេ ព្រោះព្រះដ៏មានព្រះភាគកំពុងតែសម្រាកព្រះអង្គ ។ អ្នកទាំងអស់នោះ តាំងចិត្តនៅចាំគាល់ព្រះពុទ្ធអង្គ ក្រោមម្លប់ឈើផង ម្លប់កូដាគារសាលាផង ។ កូដា-គារសាលា ជាប្រាសាទមានកំពូលខ្ពស់ដូចវិមានទេវតា បណ្តោយវែងពីជើងទៅត្បូង បែរមុខទៅទិសបូព៌ា ចំវេលានោះ ជាពេលរសៀល ម្លប់ប្រាសាទគួរឱ្យមនោរម្យដល់បរិស័ទដែលនៅចាំគាល់ព្រះពុទ្ធអង្គដ៏ប្រសើរ ។ ថ្ងៃនោះក៏ជាថ្ងៃឧបោសថ មហាលិ ជាក្សត្រិយ៍លិច្ឆវីបានសមាទានឧបោសថរួចហើយ គង់នៅពោលសរសើរគុណព្រះរតនត្រ័យ ជាមួយនឹងពួកលិច្ឆវិបរិស័ទ ។

គ្រានោះឯង សាមណេរព្រះនាមសីហៈ បានចូលទៅរកព្រះនាគិតត្ថេរ សូមឱ្យប្រជុំជនទាំងនេះ បានគាល់ព្រះដ៏មានព្រះភាគ ។ ព្រះថេរៈបានពោលថា ម្នាលសីហៈ បើដូច្នោះ អ្នកចូរក្រាបបង្គំទូលព្រះដ៏មានព្រះភាគដោយខ្លួនឯងចុះ ។ ព្រះនាគិតត្ថេរ កាលនោះលោកជាពុទ្ធុបដ្ឋាក ហើយលោកត្រូវជាអ៊ំនិងជាព្រះឧបជ្ឈាយ៍របស់សាមណេរសីហៈ តែព្រះថេរៈលោកមិនសូវរហ័សរហួនទេ ដោយសារខ្លួនលោកធាត់ ម្ល៉ោះហើយកិច្ចវត្តថ្វាយចំពោះព្រះដ៏មានព្រះភាគផ្សេងៗ គឺនៅលើសាមណេរសីហៈគ្រប់វេលា ។ សាមណេរសីហៈបួសពីព្រះជន្ម ៧ ឆ្នាំ ប្រឹងប្រែងព្យាយាមក្នុងព្រះសាសនា ។ គួរឱ្យជ្រះថ្លាណាស់ ព្រោះថាសាមណេរសីហៈជាបុគ្គលស្និទ្ធស្នាល និងជាទីប្រោសប្រាណនៃព្រះទសពល កាលដែលបានចូលទៅគាល់ និងទូលព្រះដ៏មានព្រះភាគអំពីបរិស័ទនៅអង្គុយពេញក្នុងវត្ត រង់ចាំគាល់ព្រះអង្គហើយ ទើបព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលសីហៈ បើដូច្នោះអ្នកចូរក្រាលអាសនៈត្រង់ម្លប់ខាងមុខវិហារចុះ ។ ព្រះករុណាព្រះអង្គ ។

លំដាប់នោះ ព្រះដ៏មានព្រះភាគ ទ្រង់មានព្រះពុទ្ធរស្មី ៦ ប្រការ ចាំងចេញទៅតាមទ្វារនិងបង្អួច ព្រះអង្គយាងចេញពីកូដា-

គារសាលា ដូចព្រះចន្ទពេញវង់ចេញពីពពកដូច្នោះឯង ទ្រង់គង់ប្រថាប់លើបវរពុទ្ធាសនៈ ដែលសាមណេរសីហៈក្រាលថ្វាយក្នុងម្លប់ប្រាសាទ បែរព្រះភក្ត្រឆ្ពោះបរិស័ទដែលឋិតនៅនាទិសបូព៌ា ។ កូដាគារ ហៅថា សាលាក៏បាន វិហារក៏បាន ប្រាសាទក៏បាន ។

ក្នុងកិច្ចសន្ទនារវាងមហាលិក្សត្រិយ៍លិច្ឆវី ជាមួយនឹងព្រះដ៏មានព្រះភាគ គឺមហាលិទូលសួរអំពី សុនក្ខត្តលិច្ឆវិបុត្រ បានទិព្វចក្ខុ តែមិនបានទិព្វសោត ។ សុនក្ខត្តលិច្ឆវិបុត្រនេះ ជាភិក្ខុធ្លាប់បានបម្រើព្រះដ៏មានព្រះភាគដោយកិច្ចវត្តផ្សេងៗ អស់ ៣ ឆ្នាំដែរ ប៉ុន្តែដោយបាបកម្មក្នុងអតីតកាល លោកធ្លាប់ទះផ្ចប់ត្រចៀកភិក្ខុអ្នកមានសីលមួយអង្គឱ្យថ្លង់ ទើបលោកមិនអាចសម្រេចបាននូវទិព្វសោតដូច្នេះ ។

មហាលិ បានក្រាបទូលសួរអំពីភិក្ខុប្រព្រឹត្តព្រហ្មចរិយធម៌ក្នុងសម្នាក់ព្រះដ៏មានព្រះភាគ ព្រោះហេតុដើម្បីធ្វើឱ្យជាក់ច្បាស់នូវសមាធិភាវនានេះឬ ? មហាលិ សំដៅយកសមាធិដែលអប់រំទាំងពីរចំណែក គឺដើម្បីទិព្វចក្ខុ និងដើម្បីទិព្វសោត ។

ព្រោះសមាធិភាវនាទាំងនោះ ជារបស់ក្រៅសាសនា មិនប្រព្រឹត្តទៅជាខាងក្នុង ដោយហេតុនោះ ទើបព្រះដ៏មានព្រះភាគទ្រង់បដិសេធសមាធិភាវនាទាំងនោះ ។ កាលដែលព្រះអង្គទ្រង់

ប្រកាសអំពីប្រយោជន៍ដែលភិក្ខុប្រព្រឹត្តព្រហ្មចរិយធម៌ ទើបត្រាស់ថា **ន ខោ មហាលិ** ជាដើម ។ ព្រះដ៏មានព្រះភាគ ទ្រង់ប្រកាសអំពីភិក្ខុប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសាសនានេះ ដើម្បីកំណត់ដឹងនូវទុក្ខ សម្រេចបានជាព្រះសោតាបន្ន ព្រះសកទាគាមី ព្រះអនាគាមី និងព្រះអរហន្ត នេះជាព្រហ្មចរិយធម៌ដ៏ប្រសើរលើសលប់ជាងសមាធិភាវនានោះៗ ។ កាលដែលព្រះដ៏មានព្រះភាគ ទ្រង់វិសជ្ជនានូវបញ្ហាមគ្គប្បដិបទា សម្រាប់ធ្វើឱ្យជាក់ច្បាស់នូវធម៌ដ៏ប្រសើររបស់ភិក្ខុក្នុងសាសនានេះ ទើបព្រះអង្គត្រាស់អរិយមគ្គប្រកបដោយអង្គ ៨ ប្រការ ដែលជាធម៌សម្រាប់ធ្វើឱ្យជាក់ច្បាស់នូវសោតាបត្តិផលជាដើម ។

ព្រោះហេតុក្សត្រិយ៍លិច្ឆវីអង្គនេះ មានសេចក្តីប្រកាន់ថារូបជាតួខ្លួន ទើបចិត្តមិនបង្អោនទៅក្នុងព្រះធម៌ទេសនា ។ ដោយព្រះហឫទ័យអនុគ្រោះ ព្រះដ៏មានព្រះភាគទ្រង់លើកយកព្រះធម៌ទេសនា កាលពីព្រះអង្គទ្រង់គង់នៅឃោសិតារាមជិតក្រុងកោសម្ពី ក្នុងជាលិយសូត្រ ជាព្រះសូត្របន្តទៅនេះឯង ទើបធ្វើឱ្យមហាលិស្តេចលិច្ឆវីត្រេកអររីករាយនឹងភាសិតព្រះដ៏មានព្រះភាគ ។

**សូមអនុមោទនា !**

# ៣. ជាលិយសូត្រ

ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងឃោសិតារាម ជិតក្រុងកោសម្ពី ។ គ្រានោះ មានបព្វជិតអ្នកបួសក្រៅព្រះពុទ្ធសាសនា ២ រូប គឺមណ្ឌិយបរិព្វាជក ១, ជាលិយៈជាសិស្សនៃទារុបត្តិកបរិព្វាជក ១, នាំគ្នាចូលគាល់ព្រះដ៏មានព្រះភាគ ទូលសួរព្រះអង្គថា អាវុសោ គោតមដ៏ចម្រើន ជីវៈនោះគឺសរីរៈនោះឬ ? ឬថា ជីវៈដទៃសរីរៈដោយខ្លួនទេ ?

បរិព្វាជកទាំងពីររូបនេះ ដោយមានបំណងលើកវាទៈជាមួយនឹងព្រះដ៏មានព្រះភាគ ទើបបានជាទូលសួរនូវប្រស្នាដូច្នេះ ។ បរិព្វាជកគិតថា បើព្រះសមណគោតមត្រាស់ថា ជីវៈនោះគឺសរីរៈនោះ យើងនឹងលើកវាទៈនោះ របស់ព្រះសមណគោតមនោះថា អាវុសោគោតមដ៏ចម្រើន តាមលទ្ធិរបស់អាវុសោគោតម គឺសត្វក្នុងលោកនេះនឹងដាច់សូន្យ ព្រោះហេតុនោះ វាទៈរបស់អាវុសោគោតមរមែងជាឧច្ឆេទវាទ ប៉ុន្តែបើព្រះគោតមត្រាស់ថា ជីវៈដទៃសរីរៈដោយខ្លួនទេ យើងនឹងលើកវាទៈនោះ របស់ព្រះសមណគោតមនោះថា អាវុសោគោតមដ៏ចម្រើនក្នុងវាទៈរបស់អាវុសោ-

គោតម គឺរូបរមែងរលត់សូន្យ ឯចំណែកសត្វមិនសូន្យទេ ព្រោះហេតុនោះ វាទះរបស់អារុំសោគោតមរមែងជាសស្សតវាទ ។

ព្រះដ៏មានព្រះភាគ ទ្រង់ជ្រាបថា អ្នកទាំងពីរនេះសួរប្រស្នាដើម្បីប្រយោជន៍ដល់ការលើកវាទះ ព្រះអង្គពុំបានដោះស្រាយប្រស្នានោះឡើយ ទ្រង់បានត្រាស់សម្តែងព្រះធម៌អំពីផ្លូវកណ្តាលគឺសីល សមាធិ និងបញ្ញា តាមលំដាប់លំដោយ ដូចក្នុងសាមញ្ញផលសូត្រ ចាប់តាំងអំពីពាក្យថា ព្រះតថាគតកើតឡើងក្នុងលោកនេះជាព្រះអរហន្តសម្មាសម្ពុទ្ធ ដូច្នេះជាដើម ។ បុគ្គលដែលតាំងនៅក្នុងបដិបទាជាផ្លូវកណ្តាល រមែងរួចពីការយល់ខុសថា ជីវះនោះគឺសរីរះនោះ ជីវះដទៃសរីរះដោយខ្លួន ព្រោះថាសង្ខារលោក មានតែរូបធម៌និងនាមធម៌កើតឡើងអាស្រ័យដោយបច្ច័យតែប៉ុណ្ណោះ មិនមានជីវះដែលជាអត្តានោះទេ ។

ព្រះដ៏មានព្រះភាគ បានត្រាស់សម្តែងនូវព្រះសូត្រនេះចប់ហើយ បព្វជិតទាំងពីររូបនេះ ក៏មានចិត្តរីករាយ ត្រេកអរចំពោះភាសិត របស់ព្រះដ៏មានព្រះភាគ ។ នៅក្នុងមហាលិសូត្រព្រះបរមសាស្តាទ្រង់បានលើកយកព្រះសូត្រនេះ សម្តែងប្រោសមហាលិដែលជាក្សត្រិយ៍លិច្ឆវី ឱ្យត្រេកអរក្នុងការស្តាប់ព្រះធម៌ ។

**សូមអនុមោទនា !**

# ៤. មហាសីហនាទសូត្រ

ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងព្រៃឈ្មោះកណ្ណកថលៈ ជាទីឱ្យអភ័យដល់ម្រឹគ ជិតក្រុងឧជុញ្ញា។ គ្រានោះ អចេលកស្សបៈ បានចូលគាល់ព្រះដ៏មានព្រះភាគ ហើយបានទូលសួរព្រះពុទ្ធអង្គ អំពីពាក្យដែលបានឮមកថា ព្រះសមណគោតមរមែងតិះដៀលនូវតបៈទាំងពួង ។ អចេលកស្សបៈនេះ មានឧបនិស្ស័យត្រូវបាន សម្រេចព្រះអរហត្តក្នុងផ្នួស ព្រោះបានស្តាប់មហាសីហនាទសូត្រ នេះឯង គ្រាន់តែថា ពេលដែលមិនទាន់ស្ដាប់យល់ព្រះធម៌ ក៏ប្រព្រឹត្តទៅតាមទិដ្ឋិ ជាអ្នកបួសស្រោតមួយរូប ។

មហាសីហនាទ ដែលព្រះដ៏មានព្រះភាគទ្រង់បន្លឺនៅក្នុងព្រះសូត្រនេះ មាន ១១០ មានមហាសីហនាទ ១០ ជាប្រធាន គឺ

១- តថាគតឃើញអ្នកបំពេញតបៈខ្លះ កើតក្នុងអបាយភូមិ

២- តថាគតឃើញអ្នកបំពេញតបៈខ្លះ កើតក្នុងសុគតិភព

៣- តថាគតប្រសើរបំផុត ក្នុងការលះអកុសលធម៌

៤- តថាគតប្រសើរបំផុត ក្នុងការសមាទានកុសលធម៌

៥- សង្ឃសាវ័កប្រសើរបំផុត ក្នុងការលះអកុសលធម៌

៦- សង្ឃសាវ័កប្រសើរបំផុត ក្នុងការសមាទានកុសលធម៌

៧- មិនមានអ្នកណាដូចតថាគត ដោយសីល

៨- មិនមានអ្នកណាដូចតថាគត ដោយវីរិយៈ

៩- មិនមានអ្នកណាដូចតថាគត ដោយបញ្ញា

១០- មិនមានអ្នកណាដូចតថាគត ដោយវិមុត្តិ ។

មហាសីហនាទបន្តមកទៀត គឺយកមហាសីហនាទ ១០ ដែលជាប្រធាន មកធ្វើឱ្យបាន ១០ ដង ត្រូវជាមហាសីហនាទ ១០០ ដូចជាការដែលព្រះអង្គទ្រង់បន្លឺមហាសីហនាទ ១០ ដែលជាប្រធាននោះ គឺបន្លឺកណ្ដាលបរិស័ទ ដូច្នេះជាដើម ។ មហាសីហ-នាទ ១០០ គឺ

១- តថាគតនៅកណ្ដាលបរិស័ទ បន្លឺសីហនាទ ១០

២- តថាគតជាបុគ្គលអង់អាច បន្លឺសីហនាទ ១០

៣- ទេវតានិងមនុស្សសួរបញ្ហានឹងតថាគត ១០

៤- តថាគតឆ្លើយដោះស្រាយនូវបញ្ហា ១០

៥- តថាគតញ៉ាំងចិត្តអ្នកសួរឱ្យត្រេកអរ ១០

៦- ស្ដាប់ហើយ សម្គាល់ថាជាពាក្យគួរស្ដាប់ ១០

៧- ស្ដាប់ហើយ រមែងជ្រះថ្លានឹងតថាគត ១០

៨- ជ្រះថ្លាហើយសម្ដែងអាការតាមសេចក្ដីជ្រះថ្លានោះ១០

៩- សម្ដែងអាការជ្រះថ្លាហើយ ប្រតិបត្តិតាម ១០

១០- ញុំាងតថាគតឱ្យត្រេកអរនឹងការប្រតិបត្តិនោះ ១០

រួមជាមហាសីហនាទ ១១០ គឺ មហាសីហនាទ ១០ ជាប្រធាន និងមហាសីហនាទ ១០០ ដោយអំណាចនៃបរិវារ ។ ក្នុងព្រះសូត្រដទៃក្រៅអំពីព្រះសូត្រនេះ សីហនាទមានប្រមាណប៉ុណ្ណេះ រកបានដោយក្រ ព្រោះហេតុនោះ ព្រះសូត្រនេះទើបហៅថា មហាសីហនាទសូត្រ ។

ក្នុងចន្លោះនៃមហាសីហនាទសូត្រនេះ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលកស្សបៈ លោកុត្តរមគ្គក៏មាន បុព្វភាគប្បដិ-បទាក៏មាន ដែលបុគ្គលប្រតិបត្តិឱ្យសមគួរហើយ គង់នឹងជាក់ច្បាស់នូវសាមញ្ញផល គង់នឹងឃើញដោយខ្លួនឯងថា ព្រះ-សមណគោតម ពោលពាក្យត្រូវតាមកាល ពោលពាក្យពិត ពោលពាក្យប្រកបដោយប្រយោជន៍ ពោលតាមធម៌ និង ពោលតាមវិន័យ ។ មគ្គប្រកបដោយអង្គ ៨ ប្រការរមែងមាន ដើម្បីដឹងនូវភាពមិនវិបរិតនៃមហាសីហនាទនេះ ។

អចេលកស្សបៈ បានពោលអំពីតបៈ ដែលរាប់ថាជាកិច្ចការនៃសមណព្រាហ្មណ៍ ប៉ុន្តែព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា ការព្យាយាមបំពេញតបៈនោះ វៀរចាកសីលសម្បទា ចិត្តសម្បទា និង

បញ្ញាសម្បទា ឈ្មោះថា ឆ្ងាយពីសាមញ្ញគុណ ឆ្ងាយពីព្រហ្មញ្ញ-គុណ ដែលជាអំពើប្រាសចាកនូវប្រយោជន៍ ។

កាលដែលអចេលកស្សបៈ ទូលសួរព្រះដ៏មានព្រះភាគនូវសម្បទាទាំង ៣ មានសីលសម្បទាជាដើម ដើម្បីបានយល់អំពីភាពជាសមណព្រាហ្មណ៍ពិតប្រាកដ ព្រះបរមសាស្តា ទ្រង់បានត្រាស់សម្តែងព្រះធម៌ដូចក្នុងសាមញ្ញផលសូត្រ ហើយព្រះអង្គទ្រង់បញ្ជាក់ថា សីលសម្បទា ចិត្តសម្បទា និង បញ្ញាសម្បទាឯទៀតដ៏លើសលប់ថ្លៃថ្លា ជាងសីលសម្បទា ចិត្តសម្បទា និង បញ្ញា-សម្បទានេះ មិនមានឡើយ គឺព្រះអង្គទ្រង់ប្រកាសនូវសម្បទាទាំង ៣ ដ៏លើសលប់ថ្លៃថ្លាក្នុងអរហត្តផល ។

នៅខាងចុងនៃព្រះសូត្រនេះ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ប្រាប់អចេលកស្សបៈ អំពីនិគ្រោធបរិព្វាជក ធ្លាប់បានសួរប្រស្នានឹងព្រះអង្គអំពីការខ្ពើមកិលេសដ៏ក្រៃលែង ។ និគ្រោធ-បរិព្វាជកនេះ ជាសព្រហ្មចារីរបស់អចេលកស្សបៈនេះឯង មានសម្តែងនៅក្នុងឧទុម្ពរិកសូត្រ ទីឃនិកាយ បាដិកវគ្គ ។ ព្រះដ៏មាន-ព្រះភាគទ្រង់ត្រាស់ថា និគ្រោធបរិព្វាជកនោះ កាលដែលតថាគតបានដោះស្រាយប្រស្នាហើយ ក៏មានចិត្តត្រេកអរពន់ប្រមាណ ។ អចេលកស្សបៈ ពោលថា នរណាហ្ន៎ ដែលបានស្តាប់ធម៌របស់

ព្រះដ៏មានព្រះភាគហើយ មិនមានចិត្តត្រេកអរពន់ប្រមាណនោះ បពិត្រព្រះអង្គដ៏ចម្រើន ឯខ្ញុំព្រះអង្គស្តាប់ធម៌របស់ព្រះដ៏មានព្រះ-ភាគហើយ មានចិត្តត្រេកអរពន់ប្រមាណណាស់ ។

អចេលកស្សបៈ បានពោលសរសើរព្រះធម៌ បានសូមដល់ព្រះដ៏មានព្រះភាគផង ព្រះធម៌ផង ព្រះសង្ឃផង ជាសរណៈ ហើយសូមបព្វជ្ជាឧបសម្បទា ក្នុងសម្នាក់ព្រះដ៏មានព្រះភាគ ។ អចេលកស្សបៈ មានចិត្តរំភើបរីករាយពន់ពេកណាស់ គេគិតថា យើងបានប្រកបខ្លួន ក្នុងចំណែកដែលមិនអាចចេញចាកទុក្ខបាន យើងប្រព្រឹត្តខ្លួន ឱ្យលំបាកអស់កាលដ៏យូរមកហើយ មិនមានប្រយោជន៍អ្វីសោះ ឱហ្ន៎ ! ព្រះពុទ្ធសាសនាជារតនៈដ៏អស្ចារ្យ ។

ព្រះដ៏មានព្រះភាគ ទ្រង់ជ្រាបថា អចេលកស្សបៈនេះមានឆន្ទៈខ្លាំងក្លា មិនគួរនៅបរិវាស ទើបត្រាស់ហៅភិក្ខុមួយអង្គមកថា ម្នាលភិក្ខុ អ្នកចូរនាំកស្សបៈទៅងូតទឹក ហើយឱ្យបព្វជ្ជារួចនាំមក ។ ភិក្ខុអង្គនោះ បានធ្វើតាមព្រះពុទ្ធតម្រាស់ ឱ្យកស្សបៈបួសហើយ នាំមកកាន់សម្នាក់ព្រះបរមសាស្តា ។ ព្រះដ៏មានព្រះ-ភាគទ្រង់ឱ្យកស្សបៈនោះគង់អង្គុយក្នុងកណ្តាលគណៈហើយ ទ្រង់ឱ្យឧបសម្បទា ដោយហេតុនោះ ទើបពោលថា អចេលកស្សបៈបានបព្វជ្ជា បានឧបសម្បទាក្នុងសម្នាក់នៃព្រះដ៏មានព្រះភាគ ។

មិនយូរប៉ុន្មាន ព្រះកស្សបៈដ៏មានអាយុ ក៏បានសម្រេចព្រះអរហត្ត ជាព្រះអរហន្តមួយអង្គដែរ ។

## បុគ្គលមានភ័ព្វប្រកបដោយអង្គ ៧ យ៉ាង[១]

១- មិនធ្វើអនន្តរិយកម្ម ៥ យ៉ាង

២- មិនមាននិយតមិច្ឆាទិដ្ឋិ

៣- តិហេតុកបដិសន្ធិ

៤- មានសទ្ធាក្នុងព្រះរតនត្រ័យ

៥- មានឆន្ទៈក្នុងការធ្វើកុសល

៦- មានភវង្គប្បញ្ញាបរិបូណ៌

៧- មានឧបនិស្ស័យនៃមគ្គផល ។

**សូមអនុមោទនា !**

១ អដ្ឋកថា បុគ្គលប្បញ្ញត្តិ ភព្វាគមនបុគ្គល ។

# ៥. បោដ្ឋបាទសូត្រ

ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅនាមហាវិហារព្រះជេតពន ជិតក្រុងសាវត្ថី ។ សម័យនោះឯង មានបរិព្វាជកម្នាក់ ឈ្មោះ បោដ្ឋបាទ នៅអាស្រ័យនឹងមល្លិការាម ជាអារាមរបស់ព្រះនាង មល្លិកា ព្រះរាជទេពីនៃព្រះបាទបសេនទិកោសល ។ មល្លិការាម សម្បូណ៌ទៅដោយជួរនៃដើមទន្លាប់ មានសាលាធំៗជាច្រើនដែល ពួកព្រាហ្មណ៍ជាដើម យកជាទីប្រជុំជជែកគ្នាអំពីលទ្ធិរបស់ខ្លួន ដូចជាបោដ្ឋបាទបរិព្វាជកក្នុងកាលនោះ នៅជាមួយនឹងបរិស័ទ ប្រមាណបីពាន់នាក់ ។ សម័យនោះ ពេលជិតភ្លឺ ព្រះដ៏មាន-ព្រះភាគទ្រង់ផ្សាយព្រះសព្វញ្ញុតញ្ញាណ ទ្រង់ពិចារណាមើល ឧបនិស្ស័យនៃសត្វលោក ព្រះអង្គទ្រង់ទតឃើញបោដ្ឋបាទបរិព្វា-ជកចូលមកក្នុងសំណាញ់ព្រះញាណនៃព្រះអង្គ ទ្រង់ពិចារណាថា បោដ្ឋបាទនេះ បានប្រាកដក្នុងសំណាញ់ញាណរបស់យើង តើ ឧបនិស្ស័យនឹងឱ្យសម្រេចដូចម្ដេច ។ ព្រះដ៏មានព្រះភាគទ្រង់ ជ្រាបដោយព្រះញាណថា ក្នុងថ្ងៃនេះ យើងតថាគតនឹងទៅកាន់ អារាមនោះ ហើយពេលនោះ បោដ្ឋបាទនឹងសួរយើងអំពីនិរោធ

និងការចេញចាកនិរោធ កាលដែលយើងសម្តែងនូវនិរោធតាមលំដាប់នោះ ដោយញាណ ដូចជាញាណនៃព្រះពុទ្ធទាំងឡាយហើយ ពីរបីថ្ងៃក្រោយ បោដ្ឋបាទនឹងនាំចិត្តហត្ថិសារីបុត្ត មកកាន់សម្នាក់យើងវិញ យើងនឹងសម្តែងធម៌ដល់គេទាំងពីរនាក់នោះ ក្នុងទីបំផុតនៃព្រះធម៌ទេសនា បោដ្ឋបាទនឹងដល់យើងតថាគតជាសរណៈ ចំណែកចិត្តហត្ថិសារីបុត្ត នឹងបួសក្នុងសម្នាក់របស់យើង ហើយសម្រេចព្រះអរហត្ត ដោយប្រការដូច្នេះឯង ។ ព្រះដ៏មាន-ព្រះភាគទ្រង់បដិបត្តិព្រះសរីរៈអំពីព្រលឹម ទ្រង់ស្បង់និងចីវរពីរជាន់ ប្រដាប់ដោយបាត្រសិលាទិព្វ ស្តេចយាងចូលក្រុងសាវត្ថីដើម្បីបិណ្ឌបាត ។ ក្នុងព្រះដំណើរដែលព្រះអង្គទ្រង់យាងចេញអំពីព្រះវិហារ គួរនាបីដូចរាជសីហ៍ចេញចាកជើងភ្នំហិមពាន្ត ។ តាមដូចដែលព្រះអង្គទ្រង់ញាណបានជ្រាបហើយ មុននឹងស្តេចយាងចូលក្រុងដើម្បីបិណ្ឌបាតប្រោសសត្វ ព្រះអង្គទ្រង់ពុទ្ធដំណើរចូលកាន់មល្លិការាមនោះឯង ។ បន្ទាប់អំពីបដិសណ្ឋារកិច្ចស្រួល-បួលហើយ បោដ្ឋបាទបរិព្វាជក ក៏បានទូលសួរព្រះដ៏មានព្រះភាគអំពីអភិសញ្ញានិរោធ ។

បោដ្ឋបាទបរិព្វាជកនេះ មានជាតិជាបណ្ឌិត កាលដែលបានស្តាប់ពាក្យពោលរបស់ពួកសមណព្រាហ្មណ៍ដែលមានលទ្ធិ

ផ្សេងៗ ប្រជុំគ្នានិយាយអំពីអភិសញ្ញានិរោធ អ្នកខ្លះថាយ៉ាងនេះ អ្នកខ្លះថាយ៉ាងនោះ គាត់មានសេចក្ដីក្ដៅក្រហាយព្រោះបានស្ដាប់នូវពាក្យពោលទាំងនោះ គាត់គិតថា ពួកសមណព្រាហ្មណ៍ទាំងអស់នេះ ពោលអំពីនិរោធផ្ដេសផ្ដាស ពួកអស់នេះដូចសត្វពពែឆ្កួតអីចឹង ។ បោដ្ឋបាទបរិព្វាជក ស្រាប់តែនឹករលឹកដល់ព្រះដ៏មានព្រះភាគថា មានតែព្រះសព្វញ្ញូពុទ្ធទេ ដែលអាចធ្វើនិរោធឱ្យប្រាកដបាន ប្រៀបដូចគេអុជប្រទីបមួយពាន់ដួងឱ្យភ្លឺស្វាងឡើងថា នេះគឺនិរោធ នេះមិនមែននិរោធទេ ព្រោះហេតុដូច្នោះ កាលដែលគាត់បានឱកាសជួបព្រះទសពលហើយ ទើបផ្ដើមបញ្ហាទូលសួរព្រះអង្គតែម្ដង ។

ព្រះដ៏មានព្រះភាគ ទ្រង់សម្ដែងអំពីសីលនិងសម្ដែងនូវអភិសញ្ញានិរោធតាមលំដាប់ តាំងពីបឋមជ្ឈានរហូតដល់និរោធ-សមាបត្តិ ព្រមទាំងវិសជ្ជនាអំពីការចេញចាកនិរោធ គឺសញ្ញាកើតឡើងមុន ញាណកើតតាមក្រោយ ព្រោះសញ្ញាជាបច្ច័យ ។

ពិតមែនថាបោដ្ឋបាទពេញចិត្តនឹងស្ដាប់នូវនិរោធកថារបស់ព្រះដ៏មានព្រះភាគ ប៉ុន្តែអត្តសញ្ញាគឺសេចក្ដីសម្គាល់ថាមានសត្វបុគ្គលតួខ្លួនរបស់គាត់នេះ រឹងមាំណាស់ ព្រោះហេតុដូច្នេះហើយ ទើបគាត់ទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន សញ្ញាឈ្មោះថាខ្លួន

ឬក៏សញ្ញាដទៃ ខ្លួនដទៃទេ ? ពោដ្ឋបាទ គាត់មានសភាពដូចជាជ្រូកដែលគេងូតទឹកក្រអូបនិងលាបដោយគ្រឿងក្រអូបឱ្យ ព្រម-ទាំងប្រដាប់ទៅដោយកម្រងមាលា ហើយលើកឱ្យដេកលើគ្រែពូកដ៏មានសិរី ក៏មិនបាននូវសេចក្ដីសុខដូច្នោះដែរ ត្រូវប្រញាប់ចុះមកដេកត្រាំភក់លាមកវិញ ទើបជ្រូកមានសេចក្ដីសុខ យ៉ាងណា ពោដ្ឋបាទ គាត់យ៉ាងនោះឯង ត្រូវព្រះដ៏មានព្រះភាគឱ្យងូត ឱ្យលាបនិងឱ្យប្រដាប់តាក់តែងដោយទេសនាដែលប្រកបដោយត្រៃ-លក្ខណ៍ដ៏ល្អិតសុខុម ព្រមទាំងលើកឡើងកាន់ដំណេកដ៏មានសិរីគឺនិរោធកថា កាលបើមិនបានសេចក្ដីសុខក្នុងនិរោធកថានោះ ក៏កាន់យកនូវលទ្ធិគឺទិដ្ឋិរបស់ខ្លួន ដែលប្រៀបដូចជារណ្ដៅភក់លាមកហ្នឹងឯង ។

ពោដ្ឋបាទ ទូលសួរបញ្ហាជាបន្តបន្ទាប់ជាប់ដោយទិដ្ឋិ មានជាដើមថា លោកទៀងឬ ? សុទ្ធតែជាបញ្ហាដែលព្រះដ៏មានព្រះ-ភាគមិនព្យាករ ព្រោះមិនប្រព្រឹត្តទៅដើម្បីជាប្រយោជន៍ ។ អ្វីដែលព្រះពុទ្ធអង្គទ្រង់ព្យាករ គឺចតុរារិយសច្ច ។ ក្នុងបទថា នេះទុក្ខជាដើម មានអត្ថថា ខន្ធ ៥ ដែលប្រព្រឹត្តទៅក្នុងភូមិបីវៀរតណ្ហាតថាគតព្យាករថាទុក្ខ តណ្ហាដែលជាបច្ច័យនៃខន្ធ ៥ នោះ ជាអណ្ដូងកើតនៃទុក្ខ តថាគតព្យាករថាទុក្ខសមុទ័យ ការមិនប្រព្រឹត្ត

ទៅនៃខន្ធនិងតណ្ហា តថាគតព្យាករថាទុក្ខនិរោធ មគ្គមានអង្គ ៨ ដ៏ប្រសើរ តថាគតព្យាករថាទុក្ខនិរោធគាមិនីបដិបទា ។ លុះព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សម្តែងដូច្នេះហើយ ព្រះអង្គទ្រង់ព្រះតម្រិះថាការប្រាកដឡើងនៃមគ្គ ឬការធ្វើឱ្យជាក់ច្បាស់នូវផលមិនមានដល់បរិព្វាជកនេះឡើយ ដូច្នេះ វេលានេះជាវេលាភិក្ខាចារនៃយើងហើយ ។ ព្រះដ៏មានព្រះភាគទ្រង់ក្រោកអំពីអាសនៈហើយព្រះអង្គទ្រង់ពុទ្ធដំណើរចេញពីមល្លិការាមដើម្បីបិណ្ឌបាត ។

ចិត្តហត្ថិសារីបុត្ត ជាកូនហ្មដំរីក្រុងសាវត្ថី ធ្លាប់បួស និងធ្លាប់សឹកជាច្រើនលើកក្នុងសម្នាក់ព្រះដ៏មានព្រះភាគ នៅក្នុងផ្នួសលោករៀនព្រះត្រៃបិដក ជាបុគ្គលឆ្លាតក្នុងអត្ថដ៏ល្អិតល្អន់ តែដោយអំណាចកិលេសក្នុងភាពជាបុថុជ្ជន និងដោយអំណាចកម្មពៀរផងនោះ ទើបធ្វើឱ្យលោកសឹកច្រើនដង ។ នៅពេលចិត្តហត្ថិសារីបុត្តសឹកលើកក្រោយ បានទៅជួបនឹងបោដ្ឋបាទ ព្រោះធ្លាប់ជាមិត្តភក្តិនឹងគ្នា ទើបបានបោដ្ឋបាទបរិព្វាជកនោះឯងបបួលដោយពាក្យថានៃសម្លាញ់ ម៉េចបានធ្វើអ៊ីចឹង អ្នកឯងចេញពីសាសនារបស់ព្រះ-សាស្តាដែលមានសភាពបែបនេះ មិនសមគួរឡើយ អ្នកត្រូវតែបួសក្នុងថ្ងៃនេះវិញ ។ ទាំងពីរនាក់ក៏បានចូលគាល់ព្រះបរមសា-ស្តាសម្មាសម្ពុទ្ធ ។ នៅក្នុងធម្មបទដ្ឋកថា បានសម្តែងថា ចិត្តហត្ថិ-

សារីបុត្ត ទៅផ្ទះដើម្បីយកត្រៃចីវរ បានអារម្មណ៍កម្មដ្ឋានល្អ មកតាមផ្លូវសម្រេចសោតាបត្តិផល ។

នៅពេលចូលគាល់ព្រះពុទ្ធអង្គ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា បោដ្ឋបាទជាអ្នកមានចក្ខុតែម្នាក់គត់ ក្នុងបណ្ដាពួកបរិព្វាជកជាបរិស័ទបីពាន់នាក់នោះ ដោយសេចក្ដីថា មានបញ្ញាដឹងពាក្យជាសុភាសិតនិងទុព្ភាសិត ។ ព្រះបរមសាស្ដា ទ្រង់ត្រាស់សម្ដែងអំពីភាសិតរបស់សមណព្រាហ្មណ៍ទាំងឡាយ ដែលប្រកបដោយការយល់ខុសថា ខ្លួនមានសេចក្ដីសុខតែម្យ៉ាង មិនមានរោគខាងមុខអំពីសេចក្ដីស្លាប់ទៅ គឺជាភាសិតដែលមិនជាអស្ចារ្យឡើយ ។ ជាបន្ត ព្រះបរមសាស្ដា ទ្រង់ត្រាស់សម្ដែងអំពីអត្តភាពបីយ៉ាងគឺ ឱឡារិកអត្តភាព ១, មនោមយអត្តភាព ១ និងអរូប-អត្តភាព ១ ។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់អំពីភពបីដោយពាក្យថា ការបាននូវអត្តភាពនេះ មានបីយ៉ាង ដូច្នេះឯង ។ ព្រះអង្គទ្រង់ត្រាស់សម្ដែងធម៌ដើម្បីឱ្យលះបង់នូវការបានអត្តភាព ទាំងបីយ៉ាង កាលបើសាវ័កប្រតិបត្តិតាមហើយ រមែងលះបង់បាននូវធម៌សៅហ្មងទាំងឡាយ ចំណែកសមថៈនិងវិបស្សនាក៏ដល់នូវការចម្រើនដុះដាល រហូតដល់ជាក់ច្បាស់ដោយបញ្ញាដ៏ឧត្តមដោយខ្លួនឯង គឺថា បានដល់នូវសភាវៈដ៏ពេញលេញនិងធំទូលាយនៃ

មគ្គបញ្ញានិងផលបញ្ញាក្នុងបច្ចុប្បន្ន ហើយនៅដោយសេចក្តីសុខក្នុងឥរិយាបថទាំងពួង ប្រកបដោយបាមោជ្ជៈ បីតិ បស្សទ្ធិ សតិ និងសម្បជញ្ញៈ ។ ព្រះដ៏មានព្រះភាគ ទ្រង់សម្តែងអំពីសេចក្តីសុខពិតក្នុងកិច្ចប្រតិបត្តិលះបង់នូវការបានអត្តភាព ជាភាសិតប្រកបដោយសេចក្តីអស្ចារ្យ ដោយព្រះអង្គទ្រង់ធ្វើនូវឧបមាយ៉ាងពីរោះ។

ចិត្តហត្ថិសារីបុត្ត បានលើកយកអត្តភាពទាំងបី មកទូលសួរព្រះដ៏មានព្រះភាគ ទាក់ទងទៅក្នុងកាលទាំងបី ។ កាលបើពោលអំពីកាល គឺអតីតកាល អនាគតកាល និងបច្ចុប្បន្នកាល គឺជាការពោលអំពីបរមត្ថសុទ្ធ បានដល់ចិត្ត ចេតសិក រូប ។ បរមត្ថធម៌ក្នុងអតីត មិនមែនជាបរមត្ថធម៌ក្នុងអនាគតនិងបច្ចុប្បន្ន បរមត្ថធម៌ក្នុងបច្ចុប្បន្ន មិនមែនជាបរមត្ថធម៌ក្នុងអតីតនិងអនាគត បរមត្ថធម៌ក្នុងអនាគត មិនមែនជាបរមត្ថធម៌ក្នុងអតីតនិងបច្ចុប្បន្នឡើយ ។ ពាក្យថា ការបាននូវអត្តភាពគឺជាវោហារ ជាបញ្ញត្តិអាស្រ័យបរមត្ថ ដោយបរមត្ថមិនមានសត្វបុគ្គលទេ លោកសូន្យទទេចាកខ្លួន និងចាកវត្ថុជារបស់ខ្លួន ។

កថារបស់ព្រះពុទ្ធទាំងឡាយ មានពីរយ៉ាងគឺ សម្មតិកថា និងបរមត្ថកថា ។ ក្នុងកថាទាំងពីរយ៉ាងនោះ កាលបើពោលថា សត្វ បុគ្គល មនុស្ស ទេវតា ព្រហ្មជាដើម ឈ្មោះថា សម្មតិកថា

កាលបើពោលថា អនិច្ចំ ទុក្ខំ អនត្តា ខន្ធ ធាតុ អាយតនៈ សតិប្បដ្ឋាន សម្មប្បធាន ជាដើមដូច្នេះ ឈ្មោះថា បរមត្ថកថា ។ កថាទាំងពីរ សុទ្ធតែអាចឱ្យសត្វដឹងច្បាស់ ចាក់ធ្លុះ ជាកថាដើម្បីនាំសត្វចេញចាកទុក្ខ កាន់យកនូវទង់គឺព្រះអរហត្តបានទាំងអស់។

អ្វី១បានប្រព្រឹត្តទៅ ដូចដែលព្រះអង្គទ្រង់ញាណហើយដូច្នោះឯង ព្រោះអ្នកទាំងពីរមានឧបនិស្ស័យជាមួយនឹងព្រះពុទ្ធ-អង្គ ។

## សិក្សាព្រះសូត្រនាំកើតសទ្ធា

| | |
|---|---|
| សិក្សាព្រះសូត្រនាំកើតសទ្ធា | កុសលភាវនាអប់រំចិត្តស្ងប់ |
| បញ្ញាបារមីនិស្ស័យគុណគាប់ | មានធមិជាទ្រព្យជួបភ័ព្វមគ្គផល ។ |

**សូមអនុមោទនា !**

# ៦_ សុភសូត្រ

ព្រះដ៏មានព្រះភាគ ទ្រង់បរិនិព្វានទៅហើយ ប្រមាណ ១ ខែ ព្រះអានន្ទបានកាន់បាត្រ និងចីវររបស់ព្រះដ៏មានព្រះភាគ ហើយមកគង់ឆាន់ថ្នាំបញ្ចុះផ្សំដោយទឹកដោះ នៅនាមហាវិហារព្រះជេតពន ។

សម័យនោះឯង សុភមាណពនៅក្រុងសាវត្ថី មានបំណងប្រាថ្នានិមន្តព្រះអានន្ទមកកាន់ភូមិគ្រឹះរបស់ខ្លួន ដើម្បីជាប្រយោជន៍ដល់ការធ្វើទានផង សួរពីការបរិនិព្វានរបស់ព្រះដ៏មានព្រះភាគផង និងជាពិសេស មានបំណងសួរព្រះធម៌ជាមួយនឹងព្រះអានន្ទ ទើបចាត់ឱ្យគេទៅនិមន្តមកកាន់ផ្ទះរបស់ខ្លួន ។

សុភមាណព ជាបុត្ររបស់តោទេយ្យព្រាហ្មណ៍ មានរឿងកន្លងទៅហើយ គឺមានស្រុកមួយឈ្មោះតុទិគ្រាម នៅមិនឆ្ងាយពីក្រុងសាវត្ថី ។ នៅស្រុកនោះ មានព្រាហ្មណ៍ម្នាក់ឈ្មោះតោទេយ្យៈ ឈ្មោះនេះ ដោយសារគាត់ជាមនុស្សធំដុំ មានមុខមាត់ក្នុងស្រុកតុទិគ្រាមនោះឯង គាត់មានទ្រព្យសម្បត្តិប្រមាណ ៨៥ កោដិ ប៉ុន្តែគាត់ជាមនុស្សកំណាញ់ដ៏ក្រៃលែង គាត់គិតថា ការដែលមិនវិនាស

អស់នូវទ្រព្យសម្បត្តិ ដោយការឱ្យទាន រមែងមិនមានឡើយ គឺបានសេចក្តីថា ការឱ្យទាន ប្រាកដជានាំឱ្យវិនាសបាត់បង់នូវទ្រព្យសម្បត្តិ មិនមានសេសសល់ នេះជាគំនិតកំណាញ់អាស្រ័យមិច្ឆាទិដ្ឋិរបស់តោទេយ្យព្រាហ្មណ៍ ។ តោទេយ្យព្រាហ្មណ៍ តែងតែពោលប្រដៅសុភមាណពជាកូនរឿយៗថា មនុស្សឆ្លាត គួរមើលការអស់ទៅនៃថ្នាំបន្តក់ភ្នែក កូនត្រូវមើលដំបូកកណ្តៀរ និងការសន្សំទឹកឃ្មុំរបស់មេឃ្មុំ ហើយគប្បីគ្រប់គ្រងផ្ទះចុះ ។

កាលដែលតោទេយ្យព្រាហ្មណ៍ឱ្យកូនសិក្សា កាន់យកនូវការមិនឱ្យទានយ៉ាងនេះហើយ ដល់ពេលស្លាប់ទៅ បានកើតជាឆ្កែនៅនឹងផ្ទះហ្នឹងឯង ។ សុភមាណពស្រឡាញ់ឆ្កែនោះណាស់ ឱ្យស៊ីអាហារដូចខ្លួនឯងបរិភោគដែរ ទាំងបានបីដាក់ឱ្យដេកលើគ្រែយ៉ាងល្អទៀតផង ។ ថ្ងៃមួយ កាលដែលសុភមាណពចេញទៅក្រៅផ្ទះ ព្រះដ៏មានព្រះភាគទ្រង់យាងចូលមកបិណ្ឌបាត ឆ្កែឃើញព្រះដ៏មានព្រះភាគ ក៏ព្រុសស្ទុះចូលទៅរកព្រះអង្គ ។ ព្រះដ៏មាន-ព្រះភាគទ្រង់ត្រាស់ទៅរកឆ្កែថា ម្នាលតោទេយ្យៈ កាលមុនអ្នកខ្វះការគោរព ពោលពាក្យមើលងាយ ហៅតថាគតថា លោក លោក ដូច្នេះបានកើតជាឆ្កែ ហើយឥឡូវនេះ នៅមកព្រុសតថាគតទៀត អ្នកនឹងធ្លាក់ទៅអវីចីមហានរក ។ ឆ្កែ បានស្តាប់

ពួដូច្នោះហើយ មានចិត្តក្តៅក្រហាយ ទើបកាយផេះដេកក្បែរ ចង្ក្រាន ពួកមនុស្សមិនអាចឱ្យទៅដេកលើគ្រែដូចមុនបានឡើយ កាលដែលសុភមាណពត្រឡប់មកហើយ សួរថា អ្នកណានាំឆ្កែឱ្យមកដេកអីចឹង ពួកមនុស្សប្រាប់ថា មិនមានអ្នកណាទេ ហើយក៏បានពោលរឿងរ៉ាវឱ្យស្តាប់ ។

សុភមាណពស្តាប់ហើយក៏មានសេចក្តីក្រោធថា បិតារបស់យើងទៅកើតក្នុងព្រហ្មលោក តែព្រះសមណគោតមថាបិតារបស់យើងជាឆ្កែ ម៉េចបានថាយ៉ាងហ្នឹង មាត់នេះខូចមែន ចាំមើលយើងទៅដេញដោល កុំឱ្យព្រះសមណគោតមចេះតែនិយាយកុហក ។ សុភមាណពបានទៅមហាវិហារជេតពនទូលសួរការពិតព្រះដ៏មានព្រះភាគ បានត្រាស់សួរអំពីទ្រព្យដែលបិតារបស់អ្នកមិនបានប្រាប់មានដែរទេ សុភមាណពបានទូលថា មួកមាសមានតម្លៃមួយសែន ស្បែកជើងមាសមានតម្លៃមួយសែន ថាសមាសមានតម្លៃមួយសែន ព្រមទាំងកហាបណៈមួយសែន ដែលបិតារបស់ខ្ញុំព្រះអង្គមិនបានប្រាប់ ។ ព្រះដ៏មានព្រះភាគត្រាស់ថា អ្នកចូរទៅឱ្យឆ្កែបរិភោគបាយមធុបាយាសមានទឹកតិច ហើយបីឱ្យទៅដេកលើគ្រែ ល្មមពេលឆ្កែបានដេកលក់បន្តិចទៅ អ្នកចូរសួរឆ្កែចុះ ឆ្កែនឹងប្រាប់អ្វីៗគ្រប់យ៉ាងដល់អ្នក ។ កាលដែលសុភមាណពបាន

ធ្វើតាម ទើបបានដឹងខ្លួនឯងថា ឆ្កែនេះជាបិតារបស់យើងមែន ព្រោះឆ្កែបានប្រាប់ដល់ទីកន្លែងនៃទ្រព្យទាំងនោះ ទើបចាប់ផ្តើម ជ្រះថ្លាក្នុងព្រះដ៏មានព្រះភាគ ទៅទូលសួរបញ្ហា ១៤ ចំណុច ក្នុងបិដកលេខ ២៨ ចូឡកម្មវិភង្គសូត្រ កាលដែលព្រះដ៏មាន-ព្រះភាគត្រាស់ឆ្លើយចប់សព្វគ្រប់ហើយ ក៏បានដល់ព្រះដ៏មានព្រះ-ភាគជាទីពឹង ជាសរណៈ ចាប់តាំងអំពីពេលនោះមក ។

ក្រោយមក សុភមាណពបានមករស់នៅក្នុងក្រុងសាវត្ថី សុភមាណពបានឮថា ព្រះអានន្ទកាន់បាត្រនិងចីវររបស់ព្រះសុ-គតសាស្តាមក មហាជនក៏បានចូលទៅរកលោកដើម្បីសាកសួរពី ព្រះដ៏មានព្រះភាគទ្រង់បរិនិព្វានទៅ ទើបសុភមាណពគិតថា បើ យើងទៅមហាវិហារ ប្រាកដជាមិនអាចបានស្តាប់ធម្មកថាស្រួល-បួលឡើយក្នុងកណ្តាលហ្វូងនៃមហាជន ដូច្នេះ មានតែនិមន្ត លោកមកកាន់ផ្ទះតែប៉ុណ្ណោះ ទើបធ្វើបដិសណ្ឋារៈបានងាយ ហើយយើងនឹងសួរក្នុងបញ្ហាដែលយើងសង្ស័យ ។

សំណួរដែលសុភមាណពលើកឡើងគឺ បពិត្រព្រះអានន្ទ ដ៏ចម្រើន ព្រះគោតមដ៏ចម្រើននោះ បានត្រាស់សរសើរនូវធម៌ ទាំងឡាយនោះដូចម្តេចខ្លះ ទាំងបានណែនាំប្រជុំជននេះ ឱ្យតាំង នៅ ឱ្យប្រតិស្ឋាន ក្នុងធម៌ដូចម្តេចខ្លះ ។

ព្រះអានន្ទតបថា ម្នាលមាណព ព្រះដ៏មានព្រះភាគព្រះ-អង្គបានត្រាស់សរសើរនូវខន្ធបីយ៉ាង ទាំងបានណែនាំប្រជុំជននេះ ឱ្យតាំងនៅ ឱ្យប្រតិស្ឋាន ក្នុងខន្ធទាំងបីយ៉ាងនោះ ខន្ធទាំងបីយ៉ាងនោះ តើដូចម្តេចខ្លះ គឺអរិយសីលក្ខន្ធ ១, អរិយសមាធិក្ខន្ធ ១ និង អរិយបញ្ញាខន្ធ ១ ។

កាលដែលសុភមាណពទូលសួរព្រះអានន្ទ អំពីខន្ធនីមួយៗ ព្រះអានន្ទបានអធិប្បាយដូចព្រះធម៌ដែលព្រះដ៏មានព្រះភាគ ទ្រង់សម្តែងក្នុងសាមញ្ញផលសូត្រដែរ ។ សុភមាណព បានសរសើរព្រះធម៌ទេសនា ហើយបានសូមដល់ព្រះពុទ្ធ ព្រះធម៌និងព្រះសង្ឃជាសរណៈ ម្តងទៀត ។

## គូគាប់បវរ

| | |
|---|---|
| មួយចំណោះដឹងពីរគុណធម៌ | គូគាប់បវរគួរអភិវឌ្ឍ |
| បាននៅរស់ហើយកុំខ្លាចហត់ | មនុស្សអភិវឌ្ឍទើបផុតទុក្ខ ។ |

## សូមអនុមោទនា !

# ៧. កេវដ្ដសូត្រ

ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងបាវារិកម្ពវន័ គឺចម្ការស្វាយរបស់បាវារិកសេដ្ឋី ជិតស្រុកនាឡន្ទា ។ កេវដ្ដៈ នេះជាឈ្មោះនៃគហបតិបុត្រ កេវដ្ដៈមានទ្រព្យប្រមាណ ៤០ កោដិ មានសេចក្ដីជ្រះថ្លាក្នុងព្រះពុទ្ធសាសនាដ៏ក្រៃលែង ព្រោះហេតុតែសទ្ធាខ្លាំងនេះឯង ទើបកេវដ្ដៈគិតថា ប្រសិនបើមានភិក្ខុមួយអង្គហោះទៅក្នុងអាកាស ហើយសម្ដែងបាដិហារ្យផ្សេងៗ ប្រាកដជាមហាជនជ្រះថ្លាក្រៃលែងណាស់ ដូច្នេះ យើងនឹងក្រាបទូលសូមព្រះដ៏មានព្រះភាគឱ្យទ្រង់អនុញ្ញាតរឿងនេះ ហើយកេវដ្ដៈបានចូលគាល់ព្រះពុទ្ធអង្គដែលទ្រង់គង់ប្រថាប់នៅបាវារិការាមនោះឯង ។

ព្រះពុទ្ធអង្គទ្រង់មិនអនុញ្ញាតក្នុងរឿងនេះឡើយ ម្ល៉ោះហើយកេវដ្ដៈចេះតែសំណូមពរព្រះដ៏មានព្រះភាគដល់ទៅ ៣ ដង។ ព្រះដ៏មានព្រះភាគទ្រង់ព្រះតម្រិះថា ឧបាសកនេះ ទោះបីយើងហាមហើយក៏នៅតែសូមរឿយៗ ឥឡូវនេះ យើងនឹងចង្អុលប្រាប់ទោសក្នុងការសម្ដែងបាដិហារ្យ ទើបព្រះអង្គទ្រង់ត្រាស់សម្ដែងអំពីបាដិហារ្យ ៣ យ៉ាង ។ បាដិហារ្យ ៣ យ៉ាងគឺ

១- **ឥទ្ធិបាដិហារ្យ** សម្ដែងឫទ្ធិផ្សេងៗ ។ បាដិហារ្យនេះ អ្នកនៅក្រៅពីព្រះពុទ្ធសាសនាក៏គេអាចសម្ដែងបានដែរ ហើយក៏មិនអាចដឹកនាំសត្វឱ្យរួចផុតចាកទុក្ខបានឡើយ ។

២- **អាទេសនាបាដិហារ្យ** ទាយចិត្តចេតសិករបស់អ្នកដទៃ ។ បាដិហារ្យនេះ ក៏មាននៅក្រៅពីព្រះពុទ្ធសាសនាដែរ គឺគេអាចដឹងចិត្តអ្នកដទៃបាន តែមិនមែនដឹងអរិយសច្ចទេ ។

៣- **អនុសាសនីបាដិហារ្យ** សេចក្ដីអស្ចារ្យដ៏ក្រៃលែង គឺភិក្ខុក្នុងសាសនានេះ តែងប្រៀនប្រដៅយ៉ាងនេះថា អ្នកទាំងឡាយចូរត្រិះរិះយ៉ាងនេះចុះ កុំត្រិះរិះយ៉ាងនេះឡើយ ចូរធ្វើទុកក្នុងចិត្តយ៉ាងនេះចុះ កុំធ្វើទុកក្នុងចិត្តយ៉ាងនេះឡើយ ចូរលះបង់តម្រេកក្នុងបញ្ចកាមគុណ ចូរដល់នូវលោកុត្តរធម៌នេះ ហើយសម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ ។ សេចក្ដីអស្ចារ្យក្នុងបាដិហារ្យទី ៣ នេះ គឺជាពាក្យទូន្មានប្រៀនប្រដៅ ជាការសម្ដែងធម៌ ដឹកនាំសត្វលោកឱ្យរួចផុតចាកទុក្ខបាន ។

ក្នុងបាដិហារ្យទាំង ៣ យ៉ាងនេះ ឥទ្ធិបាដិហារ្យ និងអាទេសនាបាដិហារ្យ នៅមានការតិះដៀលបាន នៅមានទោសមិនឋិតថេរយឺនយូរ និងមិនអាចនាំសត្វឱ្យរួចផុតចាកទុក្ខបានឡើយ ។ ចំណែកអនុសាសនីបាដិហារ្យមិនមានទោសគួរដល់ការ

តិះដៀលឡើយ ទាំងការតាំងនៅ ក៏បានយូរ ហើយជាពិសេស នៅត្រង់ដឹកនាំសត្វឱ្យរួចផុតចាកទុក្ខបាន ព្រោះហេតុដូច្នោះ ទើប ព្រះដ៏មានព្រះភាគ ទ្រង់តិះដៀលនូវបាដិហារ្យពីរយ៉ាងខាងដើម ហើយព្រះអង្គទ្រង់សរសើរនូវអនុសាសនីបាដិហារ្យតែម្យ៉ាង ទាំង ការសម្តែងធម៌រឿយៗនៃព្រះសម្មាសម្ពុទ្ធទាំងឡាយ គឺជាអនុសា-សនីបាដិហារ្យហ្នឹងឯង ។

ព្រះដ៏មានព្រះភាគ ទ្រង់ប្រកាសសម្តែងព្រះធម៌ក្នុងកេវដ្ដ-សូត្រនេះដូចសាមញ្ញផលសូត្រដែរ ដោយព្រះអង្គត្រាស់ថា ម្នាល កេវដ្ដៈ នេះតថាគតហៅថា អនុសាសនីបាដិហារ្យ ។

ជាបន្តនៅក្នុងព្រះសូត្រ ព្រះពុទ្ធអង្គទ្រង់ត្រាស់ថា រឿង ធ្លាប់មានមកហើយ ។ ព្រះអង្គត្រាស់សម្តែងអំពីភិក្ខុមួយអង្គ និមន្ត ទៅទេវលោករហូតដល់ព្រហ្មលោក ដើម្បីសួរបញ្ហា ដោយពុំបាន ទទួលចម្លើយ ទើបមកទូលសួរព្រះបរមសាស្ដា ហើយក៏អស់ សង្ស័យទៅ ។ ព្រោះហេតុអ្វី ទើបព្រះដ៏មានព្រះភាគទ្រង់ប្រារព្ធ រឿងនេះឡើង ព្រោះដើម្បីបញ្ជាក់ដល់ឥទ្ធិបាដិហារ្យនិងអាទេស-នាបាដិហារ្យ មិននាំសត្វឱ្យរួចផុតចាកទុក្ខបានឡើយ ហើយក៏ដើម្បី បញ្ជាក់ដល់អនុសាសនីបាដិហារ្យតែមួយប៉ុណ្ណោះឯង ដែលអាចនាំ សត្វឱ្យរួចផុតចាកទុក្ខបាន ។

ប្រស្នាដែលភិក្ខុអង្គនោះលើកឡើងគឺ មហាភូតរូបទាំង ៤ នេះ បានដល់ បឋវីធាតុ ១, អាបោធាតុ ១, តេជោធាតុ ១, វាយោធាតុ ១ តែងរលត់ឥតមានសេសសល់ក្នុងទីណាហ្ន៎ ។ ទេវតា ព្រះឥន្ទ្រ ព្រះព្រហ្ម កាលដែលត្រូវភិក្ខុអង្គនោះសាកសួរ ក៏គិតថា បញ្ហានេះជាពុទ្ធវិស័យ អ្នកដទៃមិនអាចឆ្លើយបានឡើយ ក៏ភិក្ខុនេះ លះបង់ព្រះសម្មាសម្ពុទ្ធ ដែលជាអគ្គបុគ្គលក្នុងលោក ត្រាច់មកសួរអ្នកដទៃ ដូចជាមនុស្សដែលលះបង់នូវគំនរភ្នក់ភ្លើង ហើយ មកផ្លុំអំពិលអំពែកដូច្នោះឯង ឬក៏ដូចជាបុគ្គលមិនទូងស្គរ បែរទៅជាមកវាយក្បាលពោះ ពុំនោះសោត ដូចបុគ្គលត្រូវការប្រេងហើយ ខំប្រឹងច្របាច់ដីខ្សាច់ដូច្នោះដែរ ។

សំណួរដែលភិក្ខុសាកសួរ ទាក់ទងនឹងព្រះនិព្វានគឺនិរោធ-សច្ច ដោយពាក្យថារលត់ឥតមានសេសសល់ ប៉ុន្តែ ព្រះពុទ្ធអង្គទ្រង់ជ្រាបថាជាសំណួរពុំត្រឹមត្រូវ ព្រោះភិក្ខុសំដៅយកមហាភូត-រូបដែលមិនជាប់ទៅដោយឥន្ទ្រិយ ជាអនុបាទិន្នករូបក្រៅពីទុក្ខសច្ច ដូចជាមហាភូតរូបក្នុងដើមឈើ ឬផែនដីជាដើម ។ ព្រះពុទ្ធអង្គទ្រង់រៀបចំសំណួរដែលត្រឹមត្រូវ គឺត្រូវសួរអំពីអង្គធម៌ដែលជាទុក្ខសច្ច រលត់ឥតមានសេសសល់ក្នុងទីណា ។ ឯចម្លើយគឺ **អសេសំ ឧបរុជ្ឈតិ** បានដល់ព្រះនិព្វានដែលជានិរោធសច្ច ព្រោះ

ការរលត់ទៅនៃអភិសង្ខារវិញ្ញាណដោយសោតាបត្តិមគ្គ សកទាគាមិមគ្គ អនាគាមិមគ្គ និងអរហត្តមគ្គ ទើបនាមរូបដែលជាទុក្ខសច្ចរលត់អស់ឥតមានសេសសល់ក្នុងព្រះនិព្វាននោះ ។

ព្រះពុទ្ធដីកាទាំងស្រុងនៅក្នុងព្រះសូត្រ កាលដែលព្រះដ៏មានព្រះភាគទ្រង់ត្រាស់សម្ដែងនូវព្រះសូត្រនេះចប់ហើយ កេវដ្ដគហបតិបុត្រ ក៏មានចិត្តរីករាយ ត្រេកអរនឹងភាសិតរបស់ព្រះដ៏មានព្រះភាគ ។

## ធម៌ពិតក្នុងលោក

ធម៌ពិតក្នុងលោកកើតពីបច្ច័យ អត់មានថោកថ្លៃធម៌បីបរមត្ថ
ចិត្តចេតសិករូបបញ្ញាកាប់កាត់ អត់មានមនុស្សសត្វមានសុទ្ធតែធម៌ ។
ខ្ពស់ទាបថោកថ្លៃប្រុសស្រីសន្មត ប្រៀបធៀបកំណត់អាក្រក់ឬល្អ
ចំណែកបរមត្ថត្រង់លក្ខណៈធម៌ ពីកើតដល់មរ៍គឺធម៌ត្រៃលក្ខណ៍ ។

**សូមអនុមោទនា !**

# ៨. លោហិច្ចសូត្រ

ព្រះដ៏មានព្រះភាគ ទ្រង់យាងទៅកាន់ស្រុកមួយឈ្មោះសាលវតិកា ក្នុងដែនកោសល មួយអន្លើដោយភិក្ខុ ៥០០ អង្គ ។ ក្នុងសម័យនោះ លោហិច្ចព្រាហ្មណ៍ជាម្ចាស់ស្រុកសាលវតិកា មានទិដ្ឋិអាក្រក់កើតឡើងថា សមណៈ ឬព្រាហ្មណ៍ក្នុងលោកនេះគប្បីបាននូវកុសលធម៌ លុះបាននូវកុសលធម៌ហើយ មិនគប្បីប្រាប់ដល់អ្នកដទៃទេ ព្រោះថា អ្នកដទៃនឹងធ្វើអ្វីឱ្យអ្នកដទៃបាន ដូចជាបុគ្គលកាត់ចំណងចាស់ ចងចំណងថ្មីដទៃវិញ យ៉ាងណាមិញ សេចក្តីនេះក៏យ៉ាងនោះដែរ អាត្មាអញយល់ថា លោភធម៌ដ៏លាមក អ្នកដទៃនឹងធ្វើអ្វីឱ្យអ្នកដទៃបាន ។

លោហិច្ចព្រាហ្មណ៍ បានឮព្រះកិត្តិសព្ទនៃព្រះដ៏មានព្រះ-ភាគដ៏អស្ចារ្យហើយ បានចាត់ឱ្យជាងកាត់សក់ឈ្មោះរោសិកៈ ទៅអារាធនាព្រះពុទ្ធអង្គនិងភិក្ខុសង្ឃមកកាន់ផ្ទះ ដើម្បីទទួលភត្ត ។ នៅពេលដែលព្រះពុទ្ធអង្គទ្រង់យាងមកនោះ ជាងកាត់សក់បានដើរតាមក្រោយព្រះអង្គ ហើយបានលើកយកទិដ្ឋិអាក្រក់របស់លោហិច្ចព្រាហ្មណ៍ ក្រាបទូលព្រះដ៏មានព្រះភាគ ព្រមទាំងសូម

ព្រះដ៏មានព្រះភាគ ទ្រង់ព្រះមេត្តាប្រោស ជួយដោះលោហិច្ច-ព្រាហ្មណ៍ ឱ្យរួចចាកទិដ្ឋិអាក្រក់នោះផង ។ ព្រះដ៏មានព្រះភាគ ទ្រង់ទទួលពាក្យរបស់ជាងកាត់សក់ថា ម្នាលរោសិកៈ កិច្ចប៉ុណ្ណោះ មិនធ្ងន់អ្វីដល់តថាគតទេ ម្នាលរោសិកៈ កិច្ចប៉ុណ្ណោះមិនលំបាកអ្វីដល់តថាគតឡើយ ។ ក្រោយអំពីព្រះពុទ្ធអង្គទ្រង់សោយនិងភិក្ខុ-សង្ឃឆាន់ហើយ ការដោះស្រាយបញ្ហាក៏បានចាប់ផ្តើម ។

ទិដ្ឋិអាក្រក់របស់លោហិច្ចព្រាហ្មណ៍ គឺគាត់បដិសេធការសង្គ្រោះ ត្រង់ដែលថា សមណព្រាហ្មណ៍ក្នុងលោកនេះ គប្បីបានសម្រេចកុសលធម៌ លុះបានសម្រេចកុសលធម៌ហើយ មិនគប្បីប្រាប់ដល់បុគ្គលដទៃទេ ព្រោះថា បុគ្គលដទៃនឹងធ្វើអ្វីឱ្យបុគ្គលដទៃបាន ។ អ្នកណានិយាយពាក្យទាំងនេះ តាមដូចដែលព្រាហ្មណ៍គាត់យល់ខុស អ្នកនោះឈ្មោះថា ជាអ្នកធ្វើសេចក្តីអន្តរាយដល់ពួកកុលបុត្រដែលអាស្រ័យនឹងធម្មវិន័យ ដែលព្រះតថាគតបានប្រកាសហើយ ព្រោះថា កុលបុត្របានសម្រេចគុណវិសេស រួចផុតចាកទុក្ខទាំងពួង មានចំនួនច្រើនលើសលប់ ដោយអាស្រ័យធម្មវិន័យដែលព្រះតថាគតបានប្រកាសហើយ ។

ពាក្យដែលថា បុគ្គលដទៃនឹងធ្វើអ្វីឱ្យបុគ្គលដទៃបាន ពាក្យនេះគួរដល់ការចោទប្រកាន់ចំពោះសាស្តាបីពួកតែប៉ុណ្ណោះ មិនគួរ

ដល់ការចោទប្រកាន់ចំពោះព្រះបរមសាស្តាសម្មាសម្ពុទ្ធឡើយ ។

សាស្តាបីពួកដែលគួរដល់ការចោទប្រកាន់គឺ

១- សាស្តាមិនបានសម្រេចគុណរបស់សមណៈ ទាំងសាវ័កក៏មិនស្តាប់គ្រូ ។

២- សាស្តាមិនបានសម្រេចគុណរបស់សមណៈ តែសាវ័កតាំងចិត្តស្តាប់គ្រូ ។

៣- សាស្តាបានសម្រេចគុណរបស់សមណៈ តែសាវ័កមិនតាំងចិត្តស្តាប់គ្រូ ។

សាស្តាពួកទី ១ និងពួកទី ២ គួរចោទប្រកាន់ថា លោកគ្រូឯងប្រដៅចំពោះអ្នកដទៃដោយធម៌ណា ចូរធ្វើខ្លួនឱ្យដល់ព្រមក្នុងធម៌នោះជាមុន គឺត្រូវធ្វើខ្លួនឱ្យត្រង់ត្រឹមត្រូវ ព្រោះបុគ្គលដទៃនឹងធ្វើអ្វីឱ្យបុគ្គលដទៃបាន ។ សាស្តាពួកទី ៣ គួរចោទប្រកាន់ថា លោកគ្រូហ្នឹងឯង ដែលគួរដល់នូវការខ្វល់ខ្វាយតិច គួរគោរពបូជាធម៌ដែលខ្លួនបានសម្រេចហើយនោះទៅ នឹងធ្វើអ្វីដល់អ្នកដទៃបាន បើគេមិនព្រមស្តាប់តាមពាក្យរបស់គ្រូហើយនោះ ។

សាស្តាពួកទី ១ ដូចបុរសចូលទៅឱបស្ត្រីដែលមិនស្រឡាញ់ខ្លួនពីក្រោយ ។

សាស្តាពួកទី ២ ដូចការមិនដកស្មៅស្រែខ្លួនឯង ទៅដក

ស្មៅស្រែអ្នកដទៃ ។

សាស្តាពួកទី ៣ ដូចបុគ្គលកាត់ចំណងចាស់ហើយចងចំណងថ្មីឡើងវិញ ។

លោភធម៌ជាបាបអកុសល គួរពោលដល់សាស្តាទាំងបីពួកនេះឯង ។

លោហិច្ចព្រាហ្មណ៍ បានក្រាបទូលសួរព្រះដ៏មានព្រះភាគថា បពិត្រព្រះគោតមដ៏ចម្រើន សាស្តាណាមួយដែលមិនគួរដល់ការចោទប្រកាន់ក្នុងលោក តើមានឬទេ ? ព្រះបរមសាស្តា ទ្រង់ត្រាស់ថា ម្នាលលោហិច្ច សាស្តាដែលមិនគួរដល់ការចោទប្រកាន់ក្នុងលោកក៏មានដែរ ។ កាលដែលព្រាហ្មណ៍ទូលសួរហើយ ព្រះអង្គទ្រង់ត្រាស់អំពីព្រះតថាគតកើតឡើងក្នុងលោក ជាព្រះ-អរហន្តសម្មាសម្ពុទ្ធ ដូចក្នុងសាមញ្ញផលសូត្រដែរ ។

លុះព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ លោ-ហិច្ចព្រាហ្មណ៍ បានក្រាបបង្គំទូលព្រះដ៏មានព្រះភាគយ៉ាងនេះថា បពិត្រព្រះគោតមដ៏ចម្រើន បុរសចាប់សក់បុរសផងគ្នាដែលធ្លាក់ទៅក្នុងជ្រោះជ្រៅ ទាញឡើងលើគោកបានយ៉ាងណា ព្រះគោតមដ៏ចម្រើន ក៏បានស្រង់ខ្ញុំព្រះអង្គដែលធ្លាក់ទៅក្នុងជ្រោះជ្រៅ គឺអបាយភូមិ យកមកដាក់លើគោកគឺឋានសួគ៌បានយ៉ាងនោះដែរ ។

លោហិច្ចព្រាហ្មណ៍ បានពោលសរសើរព្រះធម៌ទេសនា គឺព្រះធម៌ទេសនាដូចជាព្រះហស្តរបស់ព្រះពុទ្ធអង្គ ដែលចាប់ទាញសក់ក្បាលគាត់ដូច្នោះឯង គាត់សូមដល់ព្រះដ៏មានព្រះភាគផង ព្រះធម៌ផង ព្រះសង្ឃផង ជាសរណៈស្មើដោយជីវិត តរៀងទៅ ។

## **រៀនរស់ជាមួយនឹងការពិត**

រៀនរស់ជាមួយនឹងការពិត កំណត់ជីវិតពិតតាមហេតុ
ក្នុងយើងក្នុងគេច្បាស់ក្រឡែត ធម៌កើតពីហេតុឱ្យសុខចិត្ត ។
ចូលដល់នាមរូបបើកបញ្ញត្តិ ឃើញធម៌បរមត្ថស្ងាត់ប្រណីត
មិនចាំបាច់សាងធម៌ប្រតិដ្ឋ ទៅតាមដែលចិត្តចង់នោះឡើយ ។
យល់ព្រមសុខចិត្តព្រោះបញ្ញា រារាំងតណ្ហាទុក្ខាស្បើយ
ការពិតគ្រប់យ៉ាងមានស្រាប់ហើយ មិនចាំបាច់ឡើយអ្វីដទៃ ។
អារម្មណ៍វិបស្សនាគឺការពិត អប់រំគំនិតឃើញប្រពៃ
កម្ចាត់អវិជ្ជាបានផុតភ័យ ទីពឹងប្រពៃក្ស័យតណ្ហា ។

**សូមអនុមោទនា !**

# ៩. តេវិជ្ជសូត្រ

ព្រះដ៏មានព្រះភាគ ទ្រង់ពុទ្ធដំណើរទៅកាន់ស្រុកព្រាហ្មណ៍ឈ្មោះមនសាកតៈ ក្នុងកោសលជនបទ ព្រមដោយភិក្ខុសង្ឃប្រមាណ ៥០០ អង្គ ។ ព្រះដ៏មានព្រះភាគ ទ្រង់គង់ប្រថាប់នៅក្នុងអម្ពវ័ន ជិតមាត់ស្ទឹងអចិរវតី នាទិសឧត្តរនៃមនសាកតគ្រាម ។

គ្រានោះ វាសេដ្ឋមាណព ជាសិស្សរបស់បោក្ខរសាតិ-ព្រាហ្មណ៍ និងភារទ្វាជមាណព ជាសិស្សរបស់តារុក្ខព្រាហ្មណ៍ កំពុងដើរជជែកគ្នាអំពីផ្លូវនិងមិនមែនផ្លូវ ។ មាណពទាំងពីរជជែកមិនត្រូវគ្នាសោះ លំដាប់នោះ វាសេដ្ឋមាណពក៏បានគិតឃើញថាពាក្យរបស់យើងទាំងពីរនាក់នេះ ប្រាកដជាមិនមែនផ្លូវនាំចេញទេ ដែលឈ្មោះថាជាបុគ្គលឆ្លាតក្នុងផ្លូវនៅក្នុងលោកនេះ ឱ្យដូចជាព្រះគោតមដ៏ចម្រើន មិនមានឡើយ ហើយព្រះគោតមដ៏ចម្រើនក៏គង់ប្រថាប់នៅមិនឆ្ងាយពីទីនេះដែរ ព្រះអង្គនឹងកម្ចាត់សេចក្តីសង្ស័យរបស់ពួកយើងបាន ។ វាសេដ្ឋមាណព គិតឃើញដូច្នេះហើយ ទើបបានប្រាប់សេចក្តីនេះដល់ភារទ្វាជមាណព រួចក៏នាំគ្នាចូលគាល់ព្រះដ៏មានព្រះភាគ ក្រាបទូលព្រះអង្គអំពីពាក្យដែលពួក

ខ្លួនជជែកគ្នា ។

វាសេដ្ឋមាណព បានក្រាបទូលព្រះដ៏មានព្រះភាគ អំពីការបញ្ញត្តផ្លូវទាំងឡាយផ្សេងៗគ្នារបស់ពួកព្រាហ្មណ៍ទាំងឡាយថា ផ្លូវទាំងនោះសុទ្ធតែស្រោចស្រង់សត្វ នាំអ្នកប្រតិបត្តិតាមផ្លូវនោះឱ្យទៅកើតជាមួយនឹងពួកព្រហ្មបាន ។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សួរបញ្ជាក់បីដងថា ម្នាលវាសេដ្ឋ អ្នកនិយាយថា ផ្លូវរបស់ពួកព្រាហ្មណ៍ទាំងនោះ រមែងស្រោចស្រង់សត្វបានឬ ? វាសេដ្ឋ-មាណព ទទួលទាំងបីដងដែរថា បពិត្រព្រះគោតមដ៏ចម្រើន ខ្ញុំ-ព្រះអង្គនិយាយថា ផ្លូវទាំងនោះរមែងស្រោចស្រង់សត្វបាន ដូច្នោះមែន ។

ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សួរវាសេដ្ឋមាណពថា បណ្ដាពួកព្រាហ្មណ៍ដែលបានសម្រេចត្រៃវិជ្ជា តើមានព្រាហ្មណ៍ណាមួយ ទោះបីតែម្នាក់ក៏ដោយបានឃើញព្រហ្មផ្ទាល់នឹងភ្នែករបស់ខ្លួន ដែរឬទេ ?... សូម្បីតែអាចារ្យម្នាក់,... សូម្បីតែអាចារ្យជាប្រធានលើអាចារ្យ... តាំងអំពីតំណនៃអាចារ្យជាគម្រប់ ៧ មក ... ពួកឫសីជាន់មុនៗ... តើមានឫសីណាមួយពោលពាក្យនេះនឹងអ្នកថា ព្រហ្មនៅក្នុងទីណា ព្រហ្មមានសណ្ឋានយ៉ាងណា ព្រហ្មនៅត្រង់កន្លែងណា យើងទាំងឡាយស្គាល់ទីនោះ យើងទាំងឡាយ

ឃើញព្រហ្មនោះ ដូច្នេះដែរឬទេ ? វាសេដ្ឋមាណពក្រាបទូលថា បពិត្រព្រះគោតមដ៏ចម្រើន ការស្គាល់និងការឃើញនោះមិនមានទេ ។ ... ព្រះពុទ្ធអង្គត្រាស់ថា ពួកព្រាហ្មណ៍ដែលបានសម្រេចត្រៃវិជ្ជានោះឯង តែងនិយាយយ៉ាងនេះថា យើងមិនស្គាល់ យើងមិនឃើញទេ តែយើងទាំងឡាយសម្តែងផ្លូវដើម្បីកើតជាមួយនឹងព្រហ្មនោះបានថា នេះឯងជាផ្លូវត្រង់ នេះជាផ្លូវទៀងទាត់ ជាទីស្រោចស្រង់សត្វ រមែងនាំអ្នកបដិបត្តិតាមផ្លូវនោះ ឱ្យទៅកើតជាមួយនឹងពួកព្រហ្មបាន ។ ... កាលបើដូច្នោះ ភាសិតរបស់ពួកព្រាហ្មណ៍អ្នកត្រៃវិជ្ជា ជាភាសិតមិនមានសេចក្តីអស្ចារ្យ នឹងយកជាការមិនបានឡើយ ។ ម្នាលវាសេដ្ឋៈ ដូចមនុស្សមានភ្នែកខ្វាក់ដើរជាជួរតោងគ្នានឹងគ្នា អ្នកដើរមុន ក៏មើលមិនឃើញ អ្នកដើរកណ្តាលក៏មើលមិនឃើញ អ្នកដើរក្រោយក៏មើលមិនឃើញ ដូចម្តេចមិញ ម្នាលវាសេដ្ឋៈ ភាសិតរបស់ពួកព្រាហ្មណ៍អ្នកត្រៃវិជ្ជា ក៏មានទំនងឧបមេយ្យដូចជាមនុស្សខ្វាក់ដើរជាជួរដូច្នោះឯង សុទ្ធតែជាអ្នកមើលមិនឃើញ ជាភាសិតគួរឱ្យអ្នកផងសើចចំអកបាន ជាភាសិតអន់ថយ ជាភាសិតទទេ ជាភាសិតសោះសូន្យ មែនពិត ។ សូម្បីមើលឃើញព្រះអាទិត្យនិងព្រះចន្ទ ក៏ពួកព្រាហ្មណ៍អ្នកត្រៃវិជ្ជាមិនអាចសម្តែងផ្លូវដើម្បីទៅនៅរួមជាមួយនឹងព្រះអាទិត្យ និង

ព្រះចន្ទនោះបានផង ទម្រាំដល់ព្រហ្មដែលមិនបានស្គាល់ មិនបានឃើញទៀតនោះ ... ។

ព្រះដ៏មានព្រះភាគ ទ្រង់ប្រៀបព្រាហ្មណ៍អ្នកត្រៃវិជ្ជាពោលពាក្យមិនបានការ ដូចបុរសពោលថា ខ្ញុំប្រាថ្នាចង់បានស្រីស្អាតក្នុងជនបទ ប៉ុន្តែមិនដែលស្គាល់ មិនដែលឃើញ មិនដែលដឹងពូជពង្សវង្សត្រកូលអ្វីទាំងអស់ មិនទាំងដឹងថា ស្រីនោះនៅឯណាទៀតផង ពុំនោះសោត ដូចបុរសធ្វើជណ្ដើរបម្រុងឡើងប្រាសាទប៉ុន្តែអត់ដឹងថាប្រាសាទនោះនៅឯណា តូចធំ ខ្ពស់ទាបយ៉ាងណាក៏អត់ដឹងទាំងអស់ ដូច្នោះឯង ។

ព្រាហ្មណ៍អ្នកត្រៃវិជ្ជាទាំងនោះ ប្រព្រឹត្តលះបង់ធម៌ដែលធ្វើបុគ្គលឱ្យទៅជាព្រាហ្មណ៍ ហើយប្រព្រឹត្តសមាទានធម៌ដែលមិនធ្វើបុគ្គលឱ្យទៅជាព្រាហ្មណ៍វិញ លុះបែកធ្លាយរាងកាយ បន្ទាប់អំពីសេចក្ដីស្លាប់ នឹងទៅកើតជាមួយនឹងពួកព្រហ្ម ព្រោះហេតុស្រែកហៅ ព្រោះហេតុអង្វរ ព្រោះហេតុប្រាថ្នា ឬព្រោះហេតុតែសេចក្ដីត្រេកអរនោះ មិនដែលមានទេ ដូចបុរសដែលត្រូវការឆ្លងទៅត្រើយខាងនាយនៃស្ទឹងអចិរវតីនេះ បុរសនោះ គ្រាន់តែឈរនៅត្រើយអាយ ហើយស្រែកហៅឱ្យត្រើយនាយមកអាយដូច្នេះ គឺមិនបានសម្រេចដូចសេចក្ដីប្រាថ្នាឡើយ ។

ម្យ៉ាងទៀត ពួកព្រាហ្មណ៍អ្នកត្រៃវិជ្ជា ជាអ្នកជាប់ជំពាក់លិចចុះក្នុងកាមគុណ ៥ មិនមានបញ្ញាជាគ្រឿងរលាស់ខ្លួន តែងបរិភោគនូវកាមគុណដោយមិនបានឃើញទោស ជាអ្នកមានកាមច្ឆន្ទៈជាចំណង លុះបែកធ្លាយកាយ ខាងមុខអំពីសេចក្ដីស្លាប់នឹងទៅកើតជាមួយនឹងពួកព្រហ្ម ហេតុនេះមិនអាចប្រព្រឹត្តទៅបានទេ ដូចបុរសដែលត្រូវការឆ្លងទៅត្រើយខាងនាយនៃស្ទឹងអចិរវតីនេះ បានមកដល់ត្រើយអាយហើយក៏យកខ្សែចងដើមដៃទៅខាងក្រោយយ៉ាងមាំ ជាប់នៅនឹងត្រើយអាយនេះឯង គឺមិនអាចឆ្លងទៅត្រើយនាយបានឡើយ ។ កាមគុណ ៥ ជាខ្នោះ ជាចំណងក្នុងអរិយវិន័យ ។

ម្យ៉ាងវិញទៀត ពួកព្រាហ្មណ៍អ្នកត្រៃវិជ្ជា ត្រូវនីវរណៈទាំង ៥ នេះដោតក្រង ចងរឹត ក្រៀកជាប់ ចាក់ស្រែះហើយ លុះបែកធ្លាយកាយ ខាងមុខអំពីសេចក្ដីស្លាប់នឹងទៅកើតជាមួយនឹងពួកព្រហ្ម ហេតុនេះមិនមានទេ ដូចបុរសដែលត្រូវការឆ្លងទៅត្រើយខាងនាយនៃស្ទឹងអចិរវតីនេះ បុរសនោះមកដល់ហើយក៏ដេកទទូរនៅនឹងត្រើយខាងអាយនេះដូច្នោះឯង គឺមិនអាចឆ្លងទៅត្រើយនាយបានឡើយ ។ នីវរណធម៌ ៥ ប្រការ ជាគ្រឿងរារាំង ជាគ្រឿងទប់ ជាគ្រឿងទាញ និងជាគ្រឿងរួបរឹត ក្នុងអរិយវិន័យ។

ពួកព្រាហ្មណ៍អ្នកត្រៃវិជ្ជា មានស្ត្រីជាគ្រឿងជាប់ជំពាក់ ចំណែកព្រហ្មមិនមានស្ត្រីជាគ្រឿងជាប់ជំពាក់ទេ ព្រោះមិនមានកាមច្ឆន្ទនីវរណៈ ។

ពួកព្រាហ្មណ៍អ្នកត្រៃវិជ្ជា មានចិត្តចងពៀរ ចំណែកព្រហ្មមិនមានចិត្តចងពៀរទេ ព្រោះមិនមានព្យាបាទនីវរណៈនោះឯង ។

ពួកព្រាហ្មណ៍អ្នកត្រៃវិជ្ជា មានចិត្តប្រកបដោយព្យាបាទ ចំណែកព្រហ្មមិនមានចិត្តប្រកបដោយព្យាបាទ ដែលជារោគគ្រុនសន្ធំផ្លូវចិត្តនោះទេ ព្រោះមិនមានថីនមិទ្ធនីវរណៈ ។

ពួកព្រាហ្មណ៍អ្នកត្រៃវិជ្ជា មានចិត្តសៅហ្មង ចំណែកព្រហ្មមិនមានចិត្តសៅហ្មងទេ ព្រោះមិនមានឧទ្ធច្ចកុក្កុច្ចនីវរណៈ ។

ពួកព្រាហ្មណ៍អ្នកត្រៃវិជ្ជា មិនបានប្រព្រឹត្តទៅឱ្យចិត្តនៅក្នុងអំណាចឡើយ ចំណែកព្រហ្មឈ្មោះថា វសវត្តី គឺធ្វើចិត្តឱ្យនៅក្នុងអំណាចបាន ព្រោះមិនមានវិចិកិច្ឆានីវរណៈ ។

ពួកព្រាហ្មណ៍អ្នកត្រៃវិជ្ជា ចូលទៅកាន់ទីមិនមែនផ្លូវ ដោយសម្គាល់ថាជាផ្លូវទៅកាន់ព្រហ្មលោក ដូចជាការចុះទៅកាន់ទីដែលមានភក់ ដោយសម្គាល់ថាជាទីរាបស្មើនិងសម្គាល់ថា ឆ្លងបានងាយ លុះចុះទៅហើយក៏ដល់នូវការបែកបាក់អវយវៈតូចធំ មិនបានសេចក្តីសុខឡើយ ព្រោះហេតុនោះ ត្រៃវិជ្ជារបស់ពួក

ព្រាហ្មណ៍ទាំងនោះ អ្នកប្រាជ្ញហៅថា ព្រៃធំ ជាព្រៃដែលមិនមានទឹកផឹក មិនមានផ្លែផ្កាសម្រាប់បរិភោគ ជាព្រៃធ្វើឱ្យអ្នកដំណើរដល់នូវសេចក្ដីវិនាស ។

វាសេដ្ឋមាណព បានទូលសួរព្រះដ៏មានព្រះភាគថា បពិត្រព្រះគោតមដ៏ចម្រើន ខ្ញុំព្រះអង្គបានឮដូច្នេះថា ព្រះសមណគោតមស្គាល់ផ្លូវដើម្បីទៅកើតជាមួយនឹងព្រហ្ម ពិតមែនឬព្រះអង្គ ?

ព្រះដ៏មានព្រះភាគ ទ្រង់ប្រៀបដូចជាអ្នកស្គាល់មនសាកតគ្រាមច្បាស់លាស់ កាលបើមានគេសួរផ្លូវនៃមនសាកតគ្រាម ក៏ឆ្លើយបានដោយមិនយឺតយូរ ទើបព្រះបរមសាស្ដាទ្រង់ត្រាស់ថា ម្នាលវាសេដ្ឋៈ តថាគតស្គាល់ទាំងព្រហ្ម ស្គាល់ទាំងព្រហ្មលោក ស្គាល់ទាំងបដិបទាជាទីទៅកាន់ព្រហ្មលោក មិនត្រឹមតែប៉ុណ្ណោះ ព្រហ្មប្រតិបត្តិយ៉ាងណា ទើបបានទៅកើតក្នុងព្រហ្មលោក តថាគតក៏បានស្គាល់ច្បាស់នូវសេចក្ដីប្រតិបត្តិនោះ ។

វាសេដ្ឋមាណព ក្រាបបង្គំទូលសូមព្រះដ៏មានព្រះភាគដូច្នេះថា ខ្ញុំព្រះអង្គសូមឱកាស សូមព្រះគោតមដ៏ចម្រើន សម្ដែងផ្លូវដើម្បីទៅកើតជាមួយនឹងព្រហ្ម សូមព្រះគោតមដ៏ចម្រើនស្រោចស្រង់ព្រាហ្មណ៍និងពពួកសត្វផងចុះ ។

ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សម្ដែងដូចក្នុងសាមញ្ញផល-

សូត្រ ដល់ការលះបង់នូវនីវរណធម៌ទាំង ៥ តាំងនៅក្នុងព្រហ្ម-វិហារ មានមេត្តាចេតោវិមុត្តិជាដើម ។

វាសេដ្ឋមាណពនិងភារទ្វាជមាណព ទាំងពីរនាក់ពោលសរសើរព្រះធម៌ ព្រមទាំងសូមដល់ព្រះដ៏មានព្រះភាគផង ព្រះធម៌ផង ព្រះសង្ឃផង ជាសរណៈជាលើកទី ២ ។ តាមពិត មាណពទាំងពីរនេះមានឧបនិស្ស័យនៃព្រះអរហត្ត ពោលគឺ បានស្តាប់ **វាសេដ្ឋសូត្រ** ក្នុងមជ្ឈិមនិកាយ មជ្ឈិមបណ្ណាសកៈហើយ ដល់សរណៈជាលើកទី ១ មកដល់បានស្តាប់ **តេវិជ្ជសូត្រ** នេះ ដល់សរណៈជាលើកទី ២ កន្លងទៅពីរបីថ្ងៃ បានបព្វជ្ជា ក្រោយមកកំពុងបង្អោនចិត្តរលឹកទៅតាមក្រសែធម៌ក្នុង **អគ្គញ្ញសូត្រ** ក្នុងទីឃនិកាយ បាដិកវគ្គ ក៏បានសម្រេចព្រះអរហត្ត ព្រមដោយបដិសម្ភិទា ទាំងនៅក្នុងភូមិនៃសាមណេរនៅឡើយ ក្រោយមកទើបឧបសម្បទា ជាទក្ខិណេយ្យបុគ្គលដ៏ប្រសើរក្នុងលោក ។

**សូមអនុមោទនា !**

# ព្រះសុត្តន្តបិដកខ្មែរលេខ ១៦

## ទីឃនិកាយ មហាវគ្គ មាន ៣ ព្រះសូត្រ គឺ

១- មហាបទានសូត្រ

២- មហានិទានសូត្រ

៣- មហាបរិនិព្វានសូត្រ

## ពាក្យគួរយល់ដឹង

≈≈≈≈≈≈≈≈≈≈≈≈≈≈

**អត្ថានំ សូចនតោ សុវុត្តតោ សវនតោថ សូទនតោ សុត្តាណា សុត្តសភាគតោ ច សុត្តំ សុត្តន្តិ អក្ខាតំ ។**

ព្រះសុត្តន្តបិដក លោកហៅថា ព្រះសូត្រ ដោយសេចក្តី ៦ យ៉ាង ព្រោះសម្តែងអត្ថ ព្រោះត្រាស់ទុកល្អហើយ ព្រោះផលិតប្រយោជន៍ ព្រោះបង្ហូរនូវប្រយោជន៍ ព្រោះទីពឹងបានល្អ និងព្រោះមានចំណែកប្រៀបដោយខ្សែបន្ទាត់ឬខ្សែដោតក្រង ដូច្នោះឯង ។

# ១. មហាបទានសូត្រ

ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅវត្តជេតពន ព្រះអង្គសម្តែងធម្មីកថាប្រកបដោយបុព្វេនិវាស ។

ព្រះពុទ្ធ ៧ ព្រះអង្គ :

១- ព្រះវិបស្សី ៩១ ផែនដីមុន

២- ព្រះសិខី ៣១ ផែនដីមុន

៣- ព្រះវេស្សភូ ៣១ ផែនដីមុន

៤- ព្រះកកុសន្ធោ ព្រះអង្គទី ១ ក្នុងភទ្ទកប្បនេះ

៥- ព្រះកោនាគមនោ ព្រះអង្គទី ២ ក្នុងភទ្ទកប្បនេះ

៦- ព្រះកស្សបោ ព្រះអង្គទី ៣ ក្នុងភទ្ទកប្បនេះ

៧- ព្រះសមណគោតម ព្រះអង្គទី ៤ ក្នុងភទ្ទកប្បនេះ

ព្រះសម្មាសម្ពុទ្ធបីព្រះអង្គខាងដើមត្រកូលក្សត្រ បីព្រះអង្គបន្តមកទៀត ត្រកូលព្រាហ្មណ៍ ចំណែកព្រះសមណគោតមព្រះអង្គទី ៧ ត្រកូលក្សត្រ ។ បីព្រះអង្គខាងដើមកោណ្ឌញ្ញគោត្របីព្រះអង្គ បន្តមកទៀត កស្សបគោត្រ ចំណែកព្រះអង្គទី ៧ គោតមគោត្រ ។

## ព្រះជន្មាយុព្រះពុទ្ធ ៧ អង្គ

ព្រះអង្គទី ១ ព្រះជន្ម ៨ ម៉ឺនឆ្នាំ

ព្រះអង្គទី ២ ព្រះជន្ម ៧ ម៉ឺនឆ្នាំ

ព្រះអង្គទី ៣ ព្រះជន្ម ៦ ម៉ឺនឆ្នាំ

ព្រះអង្គទី ៤ ព្រះជន្ម ៤ ម៉ឺនឆ្នាំ

ព្រះអង្គទី ៥ ព្រះជន្ម ៣ ម៉ឺនឆ្នាំ

ព្រះអង្គទី ៦ ព្រះជន្ម ២ ម៉ឺនឆ្នាំ

ព្រះអង្គទី ៧ ព្រះជន្មក្នុងសម័យមនុស្សអាយុ ១០០ ឆ្នាំ ។

## ព្រះពោធិព្រឹក្សព្រះពុទ្ធ ៧ អង្គ

១- បាដលិព្រឹក្ស ដើមជ្រនៀង

២- បុណ្ឌរីកព្រឹក្ស ដើមស្វាយស (សេតម្ពព្រឹក្ស)

៣- សាលព្រឹក្ស ដើមសាលព្រឹក្ស

៤- សេរីសកព្រឹក្ស ដើមច្រេស

៥- ឧទុម្ពរព្រឹក្ស ដើមល្វា

៦- និគ្រោធព្រឹក្ស ដើមជ្រៃ

៧- អស្សត្ថព្រឹក្ស ព្រះពោធិព្រឹក្សសព្វថ្ងៃ ។

## គូសាវ័កដ៏ប្រសើរតាមលំដាប់

១- ព្រះខណ្ឌៈ និង ព្រះតិស្សៈ

២- ព្រះអភិភូ និង ព្រះសម្ភវៈ

៣- ព្រះសោណៈ និង ព្រះឧត្តរៈ

៤- ព្រះវិធូរៈ និង ព្រះសញ្ជីវៈ

៥- ព្រះភិយ្យោសៈ និង ព្រះឧត្តរៈ

៦- ព្រះតិស្សៈ និង ព្រះភារទ្វាជៈ

៧- ព្រះសារីបុត្ត និង ព្រះមោគ្គល្លាន ។

## សាវកសន្និបាតតាមលំដាប់

១- មានបីដង : លើកទីមួយ ៦ លាន ៨ សែនអង្គ, លើកទីពីរ ១ សែនអង្គ, លើកទីបី ៨ ម៉ឺនអង្គ ។

២- មានបីដង : លើកទីមួយ ១ សែនអង្គ, លើកទីពីរ ៨ ម៉ឺនអង្គ, លើកទីបី ៧ ម៉ឺនអង្គ ។

៣- មានបីដង : លើកទីមួយ ៨ ម៉ឺនអង្គ, លើកទីពីរ ៧ ម៉ឺនអង្គ, លើកទីបី ៦ ម៉ឺនអង្គ ។

៤- មានមួយដង ភិក្ខុ ៤ ម៉ឺនអង្គ ។

៥- មានមួយដង ភិក្ខុ ៣ ម៉ឺនអង្គ ។

៦- មានមួយដង ភិក្ខុ ២ ម៉ឺនអង្គ ។

៧- មានមួយដង ភិក្ខុ ១២៥០ អង្គ ។

គ្រប់ពេលនៃសាវកសន្និបាត សុទ្ធតែប្រកបដោយអង្គបួនគឺ ១- ព្រះអរហន្តគ្រប់អង្គជាឯហិភិក្ខុ, ២- ភិក្ខុទាំងអស់មានបាត្រនិងចីវរសម្រេចដោយឫទ្ធិ,៣- ភិក្ខុទាំងអស់មិនបានណាត់គ្នាប្រជុំ, ៤- ប្រជុំគ្នាក្នុងថ្ងៃឧបោសថពេញបូណ៌មី ។

## ពុទ្ធុបដ្ឋាកតាមលំដាប់

១- អសោកភិក្ខុ

២- ខេមង្ករភិក្ខុ

៣- ឧបសន្តភិក្ខុ

៤- វុឌ្ឍិជភិក្ខុ

៥- សោត្ថិជភិក្ខុ

៦- សព្វមិត្តភិក្ខុ

៧- អានន្ទភិក្ខុ ។

## ព្រះបិតា ព្រះមាតា ព្រះនគរ តាមលំដាប់

១- ព្រះបាទពន្ធុមៈ និង ព្រះពន្ធុមតីទេវី ក្នុងព្រះនគរ

ពន្ធុមតី ជារាជធានីនៃព្រះពន្ធុមៈ ។

២- ព្រះបាទអរុណៈ និង ព្រះបភាវតីទេវី ក្នុងព្រះនគរ អរុណវតី ជារាជធានីនៃព្រះបាទអរុណៈ ។

៣- ព្រះបាទសុប្បតីតៈ និង ព្រះយសវតីទេវី ក្នុងព្រះនគរ អនោមៈ ជារាជធានីនៃព្រះបាទសុប្បតីតៈ ។

៤- អគ្គិទត្តព្រាហ្មណ៍ និង វិសាខាព្រាហ្មណី ក្នុងព្រះនគរ ខេមវតី ជារាជធានីនៃព្រះបាទខេមៈ ។

៥- យញ្ញទត្តព្រាហ្មណ៍ និង ឧត្តរាព្រាហ្មណី ក្នុងព្រះនគរ សោភវតី ជារាជធានីនៃព្រះបាទសោភៈ ។

៦- ព្រហ្មទត្តព្រាហ្មណ៍ និង ធនវតីព្រាហ្មណី ក្នុងព្រះនគរ ពារាណសី ជារាជធានីនៃព្រះបាទកឹកិ ។

៧- ព្រះបាទសិរីសុទ្ធោទនៈ និង ព្រះមាយាទេវី ក្នុងព្រះ-នគរ កបិលវត្ថុ ជារាជធានីនៃព្រះអង្គ ។

ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សម្តែង ៩ វារៈនៃព្រះពុទ្ធ ៧ អង្គ គឺកំណត់កប្ប ជាតិ ត្រកូល ព្រះជន្មាយុ ព្រះពោធិព្រឹក្ស គូសាវក័ សាវកសន្និបាត ឧបដ្ឋាក និងព្រះបិតាមាតាក្នុងព្រះនគរ។ ជាបន្តព្រះដ៏មានព្រះភាគទ្រង់ត្រាស់សម្តែងប្រវត្តិរបស់ព្រះវិបស្សី-សម្មាសម្ពុទ្ធ តាំងអំពីយាងចុះកាន់ព្រះគភ៌ ព្រមទាំងទំនៀមនៃ

ពុទ្ធមាតា ជាចុងក្រោយនៃព្រះសូត្រ ព្រះអង្គទ្រង់ត្រាស់សម្តែង អំពីសម័យមួយ ព្រះអង្គទ្រង់យាងទៅកាន់សុទ្ធាវាសព្រហ្ម ៥ ជាន់ ដែលមួយសង្សារវដ្តនៃព្រះអង្គរហូតមក ទ្រង់ពុំដែលបដិសន្ធិក្នុងទីនោះៗឡើយ ។ ព្រហ្មក្នុងទីនោះ បានថ្វាយបង្គំនិងក្រាបទូលព្រះអង្គ អំពីការប្រព្រឹត្តព្រហ្មចរិយធម៌របស់ខ្លួនក្នុងសម្នាក់ព្រះ-សម្មាសម្ពុទ្ធអង្គនោះៗ ហើយបានមកកើតក្នុងទីនេះ ។

វិបស្សិស្ស នមត្ថុ ចក្ខុមន្តស្ស សិរីមតោ
សិខិស្សបិ នមត្ថុ សព្វភូតានុកម្បិនោ
វេស្សភុស្ស នមត្ថុ ន្ហាតកស្ស តបស្សិនោ
នមត្ថុ កកុសន្ធស្ស មារសេនប្បមទ្ទិនោ
កោនាគមនស្ស នមត្ថុ ព្រាហ្មណស្ស វុសីមតោ
កស្សបស្ស នមត្ថុ វិប្បមុត្តស្ស សព្វធិ
អង្គីរសស្ស នមត្ថុ សក្យបុត្តស្ស សិរីមតោ
យោ ឥមំ ធម្មមទេសេសិ សព្វទុក្ខា បនូទនំ ។

**សូមអនុមោទនា !**

# ២. មហានិទានសូត្រ

ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅកម្មាសទម្មនិគម របស់អ្នកកុរុ ក្នុងកុរុជនបទ ។ ព្រះពុទ្ធអង្គទ្រង់ប្រារព្ធព្រះអានន្ទហើយសម្តែងព្រះធម៌ អំពីបដិច្ចសមុប្បាទធម៌ ។

ព្រោះមិនដឹងនូវបដិច្ចសមុប្បាទធម៌ ទើបបុគ្គលលុះក្នុងទិដ្ឋិបញ្ញត្តតួខ្លួន សូម្បីបានសម្រេចដល់រូបជ្ឈាន និងអរូបជ្ឈានហើយក៏ដោយ ។ ព្រះអរិយបុគ្គលទាំងអស់ និងអ្នកប្រារព្ធវិបស្សនារមែងមិនបញ្ញត្តតួខ្លួនឡើយ ។

បុគ្គលដែលលុះក្នុងទិដ្ឋិ តែងពិចារណានូវខ្លួនដែលមានវេទនាថា វេទនាជាខ្លួនរបស់អញ ក៏មាន ។ ថាវេទនាមិនមែនជាខ្លួនរបស់អញ ព្រោះថា ខ្លួនរបស់អញមិនបានទទួលអារម្មណ៍ ក៏មាន ។ ថាវេទនាមិនមែនជាខ្លួនរបស់អញ នឹងថាខ្លួនរបស់អញមិនទទួលវេទនាក៏មិនមែន អត្តារបស់អញមានការទទួលនូវវេទនាព្រោះអត្តារបស់អញមានវេទនាជាធម្មតា ក៏មាន ។

ក្នុងការប្រកាន់អត្តា ជាប់ទាក់ទងនឹងវេទនា មានការប្រកាន់ជាបីចំណែក គឺ

១- វេទនាជាខ្លួនយើង

២- វេទនាមិនមែនជាខ្លួន តែរូបជាខ្លួន

៣- វេទនាមិនមែនជាខ្លួន ទាំងរូបក៏មិនមែនខ្លួន ប៉ុន្តែ សញ្ញា សង្ខារ វិញ្ញាណ ជាខ្លួនយើង ខ្លួនយើងជាអ្នកទទួលនូវ វេទនា ។

គួរយល់ដឹងថា ជាការប្រកាន់ដូចម្តេច ក្នុងការលុះដោយ ទិដ្ឋិទាំង ៣ ពួកនេះ គឺ

១- **វេទនាជាខ្លួនយើង** ចំពោះវេទនាបីយ៉ាង គឺសុខវេទនា ១, ទុក្ខវេទនា ១, អទុក្ខមសុខវេទនា ១ តើវេទនាណាមួយជាខ្លួន យើង បើពេលណា វេទនាណាមួយកើតឡើង ពេលនោះ វេទនា ពីរទៀតមិនមានឡើយ ម្យ៉ាងទៀត វេទនាណាមួយក៏ដោយ សុទ្ធតែ អាស្រ័យបច្ច័យកើតឡើង ហើយប្រែប្រួលរលត់រលាយបាត់ទៅ វិញ អត់មានតាំងនៅជាតួខ្លួនបុគ្គលណានោះទេ ដូច្នេះទើបការ យល់ថា វេទនាជាខ្លួនយើង គឺជាទិដ្ឋិយល់ខុស ។

២- **វេទនាមិនមែនជាខ្លួន តែរូបជាខ្លួន** ជាការពិត រូបជា ធាតុមិនដឹង ដូច តុ ទូ គ្រែ តាំង ដូច្នោះឯង រូបមិនបានគិតថា វេទនាមិនមែនជាខ្លួន តែរូបជាខ្លួនដូច្នេះឡើយ អីចឹងហើយ ទើបការយល់ថា អាត្មាអញមិនសោយអារម្មណ៍ គឺជាទិដ្ឋិយល់ខុស

ព្រោះរូបមិនមានអហង្ការ ចេះគិតប្រកាន់ខ្លួនឯងអ្វីនោះទេ ។

៣- **ខ្លួនយើងជាអ្នកទទួលនូវវេទនា** ចំពោះធម៌ដែលប្រកបជាមួយនឹងវេទនា គឺសញ្ញា សង្ខារ និងវិញ្ញាណ នាមក្ខន្ធទាំង ៤ នេះ តែងកើតរលត់ជាមួយគ្នា មិនមែនកើតរលត់តែវេទនា ផ្លាស់ប្តូរវេនគ្នា ម្តងសុខ ម្តងទុក្ខ ម្តងមិនសុខមិនទុក្ខ ឯចំណែកសញ្ញា សង្ខារ វិញ្ញាណ ជាតួខ្លួន អ្នកទទួលនូវវេទនា នោះទេ កាលណាបើវេទនាទាំង ៣ រលត់អស់ នាមក្ខន្ធ ៣ ទៀតក៏រលត់ សេចក្តីដឹងខ្លួនថាអញ ក៏មិនមានក្នុងរូបក្ខន្ធសុទ្ធគឺរូបក្ខន្ធដែលមិនមាននាមក្ខន្ធអាស្រ័យជាមួយ ដូចសាកសពជាដើម នោះឡើយ ដូច្នេះហើយទើបការយល់ថា វេទនាមិនមែនជាខ្លួន តែខ្លួនទទួលនូវវេទនា គឺជាទិដ្ឋិយល់ខុស ។

បុគ្គលមានប្រក្រតីចម្រើនសតិប្បដ្ឋាន មិនបានពិចារណានូវវេទនាថាជាខ្លួន ក៏មិនបានពិចារណានូវខ្លួនថាមិនបានទទួលអារម្មណ៍ ហើយក៏មិនបានពិចារណាថាខ្លួនទទួលវេទនា ព្រោះធម៌ដែលប្រកបជាមួយវេទនាជាខ្លួនរបស់អញ ដូច្នេះឡើយ គឺថាសតិប្បដ្ឋាន ប្រព្រឹត្តទៅរកការមិនប្រកាន់នូវធម្មជាតិណាមួយក្នុងលោក ។

នៅខាងចុងនៃព្រះសូត្រ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់

សម្តែងព្រះអរហន្តពីរពួក គឺបញ្ញាវិមុត្តបុគ្គល ១ ពួក និងឧភតោ-ភាគវិមុត្តបុគ្គល ១ ពួក ។

បញ្ញាវិមុត្តបុគ្គល ព្រះអង្គទ្រង់ត្រាស់សម្តែងអំពីការដឹងច្បាស់នូវសមុទយៈ អត្ថង្គមៈ អស្សាទៈ អាទីនវៈ និងនិស្សរណៈនូវវិញ្ញាណដ្ឋិតិ ៧ និងសត្តាវាស ២ ទៀត រួមជាសត្តាវាស ៩ ។

ឧភតោភាគវិមុត្តបុគ្គល ព្រះអង្គទ្រង់ត្រាស់សម្តែងអំពីវិមោក្ខ ៨ យ៉ាង ។

ព្រះអានន្ទដ៏មានអាយុ បានស្តាប់នូវព្រះសូត្រនេះចប់ហើយ ក៏មានចិត្តត្រេកអរ រីករាយ ចំពោះភាសិតរបស់ព្រះដ៏-មានព្រះភាគ ។

**សូមអនុមោទនា !**

# ៣. មហាបរិនិព្វានសូត្រ

ចាប់ផ្ដើមអំពីព្រះដ៏មានព្រះភាគ ទ្រង់គង់នៅនាព្រះគន្ធកុដិលើភ្នំគិជ្ឈកូដ ជិតក្រុងរាជគ្រឹះ រហូតដល់ទីបរិនិព្វានក្នុងសួនសាលព្រឹក្សរបស់ពួកមល្លក្សត្រ ជាទីចូលទៅក្នុងក្រុងកុសិនារា ។

នៅភ្នំគិជ្ឈកូដ ព្រះអង្គទ្រង់ត្រាស់សម្ដែង អបរិហានិយធម៌ គឺធម៌មិននាំឱ្យមានសេចក្ដីសាបសូន្យ ។ ព្រះដ៏មានព្រះភាគ ទ្រង់យាងចេញពីក្រុងរាជគ្រឹះ ចូលកាន់សួនអម្ពលដ្ឋិកា មួយអន្លើដោយភិក្ខុសង្ឃជាច្រើន ព្រះអង្គទ្រង់ធ្វើធម្មីកថាជាច្រើនដល់ភិក្ខុទាំង-ឡាយយ៉ាងនេះថា សីលដូច្នេះ សមាធិដូច្នេះ បញ្ញាដូច្នេះ សមាធិដែលអប់រំដោយសីល រមែងមានផលច្រើន មានអានិសង្សច្រើន បញ្ញាដែលអប់រំដោយសមាធិរមែងមានផលច្រើន មានអានិសង្សច្រើន ចិត្តដែលអប់រំដោយបញ្ញារមែងរួចស្រឡះចាកអាសវៈទាំង-ឡាយ ដោយប្រពៃពិត គឺកាមាសវៈ ភវាសវៈ អវិជ្ជាសវៈ ។

ព្រះដ៏មានព្រះភាគ ទ្រង់យាងចេញពីសួនអម្ពលដ្ឋិកា ចូលកាន់ស្រុកនាឡន្ទា គង់ប្រថាប់នៅបាវារិកម្ពវន័ ព្រះសារីបុត្តចូលថ្វាយបង្គំសម្ដែងសេចក្ដីជ្រះថ្លាចំពោះព្រះដ៏មានព្រះភាគ ។ ទ្រង់

យាងចេញពីស្រុកនាឡន្ទា ចូលកាន់បាដលិគ្រាម ព្រះអង្គត្រាស់សម្ដែងអំពីទោសនៃការទ្រុស្តសីល និងអានិសង្សនៃសីលសម្បទា ទាំងបានត្រាស់សម្ដែងគាថាអនុមោទនា ដែលមានសេចក្ដីថា

បុគ្គលជាបណ្ឌិត សម្រេចទីនៅក្នុងប្រទេសណា បានញ៉ាំងបុគ្គលអ្នកមានសីលទាំងឡាយ អ្នកសង្រួម អ្នកប្រព្រឹត្តធម៌ដ៏ប្រសើរ ឱ្យបរិភោគភោជនាហារក្នុងប្រទេសនោះ ។ បណ្ឌិតបានឧទ្ទិសទក្ខិណាទាន ដល់ពួកទេវតាដែលឋិតនៅក្នុងប្រទេសនោះ ពួកទេវតាទាំងនោះដែលបណ្ឌិតបានបូជាហើយ ក៏តែងបូជាតបវិញ ដែលបណ្ឌិតរាប់អានហើយ ក៏តែងរាប់អានបណ្ឌិតនោះវិញ ។ ទេវតាតែងអនុគ្រោះបណ្ឌិតនោះ ព្រោះទក្ខិណានុប្បទាននោះ ដូចជាមាតាអនុគ្រោះកូន ដែលកើតអំពីទ្រូង បុរសដែលទេវតាអនុគ្រោះហើយ រមែងជួបប្រទះនូវសេចក្ដីចម្រើនសព្វកាល ។

ពុទ្ធបរិស័ទយើង ដែលធ្លាប់បានចូលរួមក្នុងដំណើរធម្ម-យាត្រា នឹករលឹកឃើញអសោការាម ជាទីដែលសង្ឃធ្វើតតិយ-សង្គាយនា ជិតក្រុងបាដលិបុត្ត នៅរវាងក្រុងរាជគ្រឹះនិងក្រុងវេសាលី ។ ពុទ្ធបរិស័ទយើង ប្រាកដជាចាំបានថា ក្នុងដំណើរចេញពីអសោការាមទៅក្រុងវេសាលី ត្រូវឆ្លងទន្លេដោយស្ពានវែងប្រមាណ ៦ គីឡូម៉ែត្រ ទន្លេនោះគឺទន្លេគង្គា ។ ក្នុងកាលនោះ

លុះព្រះដ៏មានព្រះភាគ ទ្រង់អនុមោទនាដោយគាថាទាំងឡាយហើយ ទ្រង់យាងទៅដល់មាត់ទន្លេគង្គានោះឯង ដែលទឹកកំពុងតែពេញប្រៀបមាត់ច្រាំង ស្រាប់តែបាត់ព្រះអង្គអំពីត្រើយខាងអាយទៅប្រាកដព្រះអង្គក្នុងត្រើយខាងនាយ ព្រមដោយភិក្ខុសង្ឃ ទ្រង់បានបន្លឺឧទានក្នុងវេលានោះ មានសេចក្តីថា

ជនទាំងឡាយណា ឆ្លងទន្លេគឺតណ្ហាដែលជ្រាលជ្រៅធំទូលាយបាន ជនទាំងឡាយនោះ រមែងធ្វើស្ពានគឺអរិយមគ្គ លះបង់នូវអន្លង់ទឹកជ្រៅ ឆ្លងផុតទៅបាន ចំណែកជនធម្មតាលុះតែចងក្បូន ទើបឆ្លងទៅបាន ឯពួកជនជាអ្នកប្រាជ្ញ មិនបាច់ក្បូនក៏ឆ្លងទៅបាន ។

ព្រះដ៏មានព្រះភាគ ទ្រង់ចូលកាន់កោដិគ្រាម ក្នុងទីនោះព្រះអង្គទ្រង់ត្រាស់ព្រះគាថា ដោយសេចក្តីថា

ការត្រាច់រង្គាត់ទៅអស់កាលជាអង្វែង ក្នុងជាតិនោះៗឯងក៏ព្រោះតែមិនបានឃើញតាមពិតនូវអរិយសច្ចទាំង ៤ ។ អរិយសច្ចទាំង ៤ នោះ តថាគតបានឃើញហើយ ខ្សែគឺតណ្ហាដែលនាំសត្វអំពីភពមួយទៅភពមួយ តថាគតបានកាត់ដាច់ហើយ ឫសគល់នៃទុក្ខក៏ពុករលួយអស់ហើយ ឥឡូវនេះ តថាគតមិនមានភពថ្មីទៀតទេ ។

ព្រះពុទ្ធអង្គទ្រង់ចេញពីកោដិគ្រាម ចូលកាន់នាទិកគ្រាម ព្រះអង្គត្រាស់សម្ដែងអំពីគតិនៃអ្នកដែលធ្វើមរណកាល ហើយ ទ្រង់ត្រាស់សម្ដែងធម្មបរិយាយឈ្មោះធម្មាទាសៈ គឺធម៌ដូចកញ្ចក់ឆ្លុះ សម្រាប់ព្យាករខ្លួនឯង ។ ជាមួយនឹងធម៌ផ្សេងៗ ព្រះដ៏មាន-ព្រះភាគទ្រង់ត្រាស់សម្ដែងសីល សមាធិ បញ្ញា និងការអប់រំចិត្ត រួចពីអាសវៈទាំងឡាយ ។ ចាប់តាំងពីក្រុងរាជគ្រឹះដល់វេសាលី គឺទ្រង់ត្រាស់សម្ដែងនូវអនុបុព្វសិក្ខានេះជាប់ជានិច្ច ។

ដល់ក្រុងវេសាលី ព្រះអង្គទ្រង់គង់ប្រថាប់ក្នុងអម្ពបាលិវ័ន ត្រាស់សម្ដែងអំពីសតិនិងសម្បជញ្ញៈជាឱវាទានុសាសនី ។ នាងអម្ពបាលីបានអារាធនាព្រះអង្គ និងភិក្ខុសង្ឃថ្វាយចង្ហាន់ ព្រមទាំងថ្វាយអារាម ។ ព្រះដ៏មានព្រះភាគ បានណែនាំឱ្យភិក្ខុទាំងឡាយមើលលិច្ឆវិបរិស័ទ ប្រៀបទៅនឹងទេវតាក្នុងឋានតាវត្តិង្ស ជាប្រយោជន៍ដើម្បីឱ្យភិក្ខុទាំងឡាយបាននូវអនិច្ចសញ្ញា រួចហើយសម្រេចព្រះអរហត្តព្រមដោយបដិសម្ភិទា គឺនៅពេលដែលពួកលិច្ឆវិបរិស័ទទាំងនោះ បានដល់នូវសេចក្ដីវិនាសដោយអំណាចនៃព្រះបាទអជាតសត្តុ ក្នុងពេលឆាប់ៗនោះឯង ។

ព្រះដ៏មានព្រះភាគ ទ្រង់សម្រេចព្រះឥរិយាបថក្នុងវស្សាទី ៤៥ នៅវេឡុវគ្រាមជិតក្រុងវេសាលី ។ ក្នុងវស្សានោះឯង

ព្រះអង្គទ្រង់មានអាពាធដ៏ខ្លាំងក្លា ព្រះអង្គទ្រង់គ្របសង្កត់នូវទុក្ខ-វេទនាដោយផលសមាបត្តិ អធិដ្ឋានរក្សាជីវិត គង់ព្រះជន្មនៅ ១០ ខែទៀត ។ ព្រះអង្គទ្រង់ត្រាស់បញ្ជាក់អំពីធម៌ដែលព្រះអង្គសម្ដែងហើយ មិនមានក្នុង មិនមានក្រៅ គឺមិនមានចែកធម៌សម្រាប់បុគ្គលជាទីស្រឡាញ់ផ្សេង មិនជាទីស្រឡាញ់ផ្សេង ដូច្នេះឡើយ ម្យ៉ាងទៀត ព្រះអង្គមិនមានបិទបាំងលាក់ធម៌ទុក ដូចជាចំណេះវិជ្ជានៅក្នុងកណ្ដាប់ដៃនៃអាចារ្យដទៃ ទុកដល់ពេលជិតស្លាប់ទើបឱ្យដល់សិស្សជាទីស្រឡាញ់នោះឡើយ ដូច្នេះហើយ ទើបព្រះអង្គទ្រង់ត្រាស់ថា ម្នាលអានន្ទ ភិក្ខុសង្ឃនៅនឹកប៉ុនប៉ងអ្វីក្នុងតថាគតទៀត ។ ព្រះអង្គទ្រង់រំលឹកដាស់តឿន ឱ្យភិក្ខុទាំងឡាយយកធម៌ជាទីពឹង គឺចម្រើនសតិប្បដ្ឋាន ៤ ។

ចេញវស្សា ព្រះបរមសាស្ដាទ្រង់យាងចេញពីវេឡុវគ្រាមទៅកាន់ក្រុងសាវត្ថី ព្រះអង្គទ្រង់គង់ប្រថាប់នៅនាមហាវិហារព្រះជេតពន ។ ក្នុងកាលនោះ ព្រះសារីបុត្តបានក្រាបថ្វាយបង្គំលាព្រះអង្គ ដើម្បីចូលកាន់ព្រះនិព្វាន ។ ១ អសង្ខេយ្យ កម្រៃ ១ សែនកប្ប ចាប់តាំងអំពីទៀបបាទមូលនៃព្រះសម្មាសម្ពុទ្ធអនោមទស្សី ព្រះសារីបុត្តធ្លាប់អន្ទោលយោលយកកំណើត បំពេញបុណ្យបារមីជាមួយនឹងអង្គព្រះជិនស្រីបរមពោធិសត្វ ឆ្លងកាត់សុខទុក្ខដ៏សែន

វែងឆ្ងាយ ទីបំផុត ភពជាតិកំណើតក៏ត្រូវអស់ ការជួបជុំក៏ត្រូវរសាយ នេះជាការឃើញចុងក្រោយ នឹងមិនមានការឃើញព្រះអង្គទៀតឡើយ ។

ព្រះពុទ្ធអង្គទ្រង់គង់នៅវត្តជេតពន ព្រះសារីបុត្តថ្វាយបង្គំលាចេញទៅ ញាប់ញ័រផែនប្រឹថពី ។ នៅថ្ងៃ ១៥ កើតខែកត្តិក ព្រះសារីបុត្តបានប្រតិស្ឋានមាតា ឱ្យតាំងនៅក្នុងសោតាបត្តិផល ហើយបរិនិព្វានក្នុងបន្ទប់ដែលលោកប្រសូត ក្នុងស្រុកនាឡន្ទា ។ ព្រះចុន្ទៈ បាននាំយកព្រះអដ្ឋិធាតុ បាត្រនិងចីវរ មកកាន់ព្រះជេតពន និមន្តនាំព្រះអានន្ទត្ថេរចូលគាល់ព្រះបរមសាស្តា ។ ព្រះដ៏មានព្រះភាគទ្រង់ខ្ចប់ព្រះអដ្ឋិធាតុនឹងសំពត់តម្រងទឹក សម្តែងគុណព្រះសារីបុត្ត ៥០០ ព្រះគាថា ទ្រង់ត្រាស់ឱ្យសាងនូវព្រះចេតិយបញ្ចុះព្រះធាតុព្រះសារីបុត្ត រួចហើយទើបទ្រង់យាងទៅកាន់ក្រុងរាជគ្រឹះ ។

ព្រះអង្គទ្រង់គង់ប្រថាប់នៅវេឡុវន័មហាវិហារ ព្រះមហាមោគ្គល្លានត្ថេរ ថ្វាយបង្គំលាព្រះអង្គបរិនិព្វាននៅកាឡសិលារាម នាភ្នំឥសិគិលិ ខាងទិសនិរតីក្រុងរាជគ្រឹះ បញ្ចុះព្រះធាតុនៅវត្តវេឡុវន័ ហើយព្រះអង្គទ្រង់យាងចេញចាកក្រុងរាជគ្រឹះ បែរព្រះភក្ត្រត្រង់ទិសទៅកាន់ទន្លេគង្គា ដល់ឧក្កវេលគ្រាមជាលំដាប់។

ព្រះអង្គទ្រង់គង់នៅមាត់ទន្លេ ត្រាស់សម្តែងព្រះធម៌ទាក់ទងនឹងការបរិនិព្វាននៃគូអគ្គសាវក័ រួចហើយចាកឧក្កវេលគ្រាម ដល់វេសាលី ។

ព្រះដ៏មានព្រះភាគ ទ្រង់បិណ្ឌបាតក្នុងក្រុងវេសាលី ថ្ងៃពេញបូណ៌មី ១៥ កើតខែមាឃ ព្រះអង្គដាក់ព្រះជន្មាយុសង្ខារចំពោះមុខមារព្ទដ៏បាវាលចេតិយ កក្រើកផែនដី ទាំងផ្គរក៏លាន់ឮឡើង ។ ព្រះពុទ្ធទ្រង់ឧទានក្នុងពេលនោះមានសេចក្តីថា

ព្រះពុទ្ធជាអ្នកប្រាជ្ញ ទ្រង់ពិចារណាឃើញនូវព្រះនិព្វានដែលមានគុណថ្លឹងមិនបានផង ពិចារណាឃើញទោសនៃភពផង ទ្រង់លះបង់នូវអភិសង្ខារគឺកម្មដែលនាំសត្វទៅកាន់ភពផង ទ្រង់ត្រេកអរខាងក្នុងដោយអំណាចវិបស្សនា និង មានព្រះហឫទ័យតាំងមាំហើយដោយអំណាចសមថៈផង ទើបទ្រង់បានទម្លាយនូវបណ្តាញគឺកិលេសដែលកើតមាន នៅក្នុងអត្តភាព ដូចជាការទម្លាយនូវអាវក្រោះរបស់សត្រូវក្នុងសមរភូមិ ដូច្នោះឯង ។

ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ចំពោះព្រះអានន្ទត្ថេរ អំពីហេតុ អំពីបច្ច័យ ៨ យ៉ាងដែលនាំឱ្យកក្រើកផែនដី ទ្រង់សម្តែងអំពីបរិស័ទ ៨ ពួក ទ្រង់សម្តែងអំពីអភិភាយតនៈគឺហេតុជាគ្រឿងគ្របសង្កត់នូវធម៌ជាសត្រូវ ៨ ប្រការ ទ្រង់សម្តែងអំពីវិមោក្ខគឺធម៌

ជាគ្រឿងរួចចាកអាសវៈ ៨ ប្រការ ទ្រង់សម្តែងអំពីមារអារាធនាព្រះអង្គឱ្យបរិនិព្វាន ទ្រង់សម្តែងអំពីឥទ្ធិបាទ ៤ ដែលព្រះអង្គធ្លាប់បានប្រកាសនៅកន្លែងផ្សេងៗ ។

ព្រះដ៏មានព្រះភាគ ទ្រង់ឱ្យប្រជុំសង្ឃនៅកូដាគារសាលា នាមហាវ័នជិតក្រុងវេសាលី ព្រះអង្គទ្រង់ប្រកាសអំពីសាសន-ព្រហ្មចរិយៈនេះគប្បីតាំងនៅអស់កាលយូរអង្វែង ប្រព្រឹត្តទៅដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ចម្រើន ដល់មនុស្សនិងទេវតាទាំងឡាយ ជាបន្តព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយឥឡូវនេះ តថាគតដាស់តឿនអ្នកទាំងឡាយ សង្ខារទាំងឡាយមានសេចក្តីវិនាសទៅជាធម្មតា អ្នកទាំងឡាយចូរញុំាងកិច្ចទាំង-ពួងឱ្យសម្រេចដោយសេចក្តីមិនប្រមាទចុះ បរិនិព្វាននឹងមានដល់តថាគតមិនយូរឡើយ កន្លង ៣ ខែអំពីថ្ងៃនេះទៅ តថាគតនឹងបរិនិព្វានហើយ ។ ព្រះអង្គទ្រង់ត្រាស់ព្រះគាថាជាបន្តដោយសេចក្តីថា

ពួកជនណាៗ ទោះបីក្មេងក្តី ចាស់ក្តី ពាលក្តី បណ្ឌិតក្តី អ្នកមានក្តី អ្នកក្រក្តី ជនទាំងអស់នោះ តែងមានសេចក្តីស្លាប់នៅពីខាងមុខ ។ ភាជនៈដីដែលស្មូនផ្ទាំងធ្វើហើយ ទោះបីតូចក្តី ធំក្តី ឆ្អិនក្តី ឆៅក្តី ភាជនៈទាំងអស់នោះ មានកិរិយាបែកធ្លាយជាទីបំផុត

យ៉ាងណា ជីវិតរបស់សត្វទាំងឡាយ ក៏យ៉ាងនោះដែរ ។

វ័យរបស់តថាគត ចាស់ហើយ ជីវិតរបស់តថាគតមានប្រមាណតិច តថាគតនឹងលះបង់អ្នកទាំងឡាយ ហើយទៅ ឯទីពឹងរបស់ខ្លួន តថាគតបានធ្វើទុកហើយ ។

ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរកុំប្រមាទ ត្រូវមានស្មារតី មានសីលល្អ មានសេចក្តីត្រិះរិះតម្កល់ស្មើល្អ ចូររក្សាចិត្តរបស់ខ្លួនឱ្យរឿយៗចុះ ។ ភិក្ខុណា មិនប្រមាទ ហើយនៅក្នុងធម្មវិន័យនេះ ភិក្ខុនោះ នឹងលះបង់ជាតិសង្សារ ហើយធ្វើនូវព្រះនិព្វាន ជាទីបំផុតនៃកងទុក្ខបាន មិនខានឡើយ ។

ព្រះដ៏មានព្រះភាគ ទ្រង់យាងចេញពីក្រុងវេសាលីមកដល់ខ្លោងទ្វារ ទ្រង់បែរព្រះវរកាយទតក្រុងវេសាលីជាចុងក្រោយ ។ ព្រះអង្គទ្រង់ជ្រាបថា ពួកស្តេចលិច្ឆវីក្រុងវេសាលី នឹងមានសេចក្តីវិនាសក្នុងវេលា ៣ ឆ្នាំទៀត ប៉ុន្តែអាចស្រោចស្រង់បាន ។ កាលដែលបានឃើញព្រះអង្គទ្រង់បែរព្រះវរកាយ ទតក្រុងចុងក្រោយ ពួកស្តេចលិច្ឆវី នាំគ្នាកសាងព្រះចេតិយអនុស្សាវរីយ៍ ឈ្មោះថា **នាគាបលោកិតចេតិយ** ជិតខ្លោងទ្វារនគរ នឹងបូជាចេតិយនោះដោយគ្រឿងសក្ការៈផ្សេងៗ មានគ្រឿងក្រអូបនិងផ្កាឈើជាដើម ប្រព្រឹត្តដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខចម្រើន អស់កាល

យូរ ព្រោះហេតុនោះ ទើបព្រះដ៏មានព្រះភាគ ទ្រង់បែរព្រះវរកាយ ទតក្រុងចុងក្រោយ ដើម្បីអនុគ្រោះពួកស្តេចលិច្ឆវីទាំងនោះឯង ។

ព្រះពុទ្ធអង្គទ្រង់ចេញពីក្រុងវេសាលី ចូលកាន់ភណ្ឌគ្រាមក្នុងព្រះពុទ្ធដំណើរទៅកាន់កុសិនារា ជាលំដាប់ៗ គឺហត្ថិគ្រាម អម្ពគ្រាម ជម្ពុគ្រាម ភោគនគរ ក្រុងបាវា ។ ព្រះអង្គទ្រង់យាងចូលដល់ក្រុងបាវា គង់ប្រថាប់ក្នុងអម្ពវ័នរបស់នាយចុន្ទកម្មារបុត្ត ជិតក្រុងបាវានោះ ក្នុងថ្ងៃ ១៤ កើតខែពិសាខ ដោយក្នុងព្រះពុទ្ធ-ដំណើរតាមផ្លូវ ព្រះអង្គទ្រង់យាងនិងគង់ប្រថាប់ ត្រាស់សម្តែងព្រះធម៌ជាហូរហែរហូត ។

ពុទ្ធបរិស័ទបច្ចុប្បន្ន នឹករលឹកដល់គណៈធម្មយាត្រាដែលបានចេញដំណើរពីវេសាលីទៅកុសិនារា ហើយក៏បានចូលថ្វាយ-បង្គំនៅនឹងក្រុងបាវានោះផងដែរ ដោយក្នុងកាលនោះ នាយចុន្ទកម្មារបុត្ត បានដឹងថា ព្រះដ៏មានព្រះភាគ ព្រមទាំងភិក្ខុសង្ឃដ៏ច្រើន គង់នៅអម្ពវ័នរបស់ខ្លួន ទើបចូលទៅថ្វាយបង្គំ ស្តាប់ព្រះធម៌ទេសនា ហើយក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះដ៏មានព្រះភាគ មួយអន្លើដោយភិក្ខុសង្ឃ ទទួលភត្តរបស់ខ្ញុំព្រះអង្គដើម្បីឆាន់ក្នុងថ្ងៃស្អែក ។

១០ ខែកន្លងទៅ អាពាធរបស់ព្រះអង្គ ក៏ត្រឡប់មកសាថ្មី ជាអាពាធដែលមានជោគជ័យលើជីវិតនៃព្រះពុទ្ធអង្គ ដែលទ្រង់ជាបរមគ្រូរបស់មនុស្សនិងទេវតា ។ នៅក្រោមម្លប់ឈើមួយដើម ព្រះអង្គទ្រង់ត្រាស់ថា ម្នាលអានន្ទ អ្នកចូរក្រាលសង្ឃាដីមានជាន់ ៤ ឱ្យតថាគតដោយឆាប់ ម្នាលអានន្ទ តថាគតល្ហិតល្ហៃណាស់ តថាគតអង្គុយសិន ។ ព្រះអង្គត្រាស់ឱ្យព្រះអានន្ទទៅដងទឹក ព្រះអង្គសន្ទនាជាមួយនឹងបុក្កុសមល្លបុត្ត ព្រះអង្គទ្រង់ចុះស្រង់ទឹកស្ទឹងកកុធៈ ហើយទ្រង់យាងត្រឡប់មកផ្ទំសម្រាកនៅអម្ពវន័វិញ ។ ព្រះដ៏មានព្រះភាគ ទ្រង់បានប្រារព្ធចង្ហាន់របស់នាយចុន្ទកម្មារបុត្ត ហើយទ្រង់ព្រះពុទ្ធឧទាន ដែលមានសេចក្តីថា

បុណ្យរមែងចម្រើនដល់អ្នកឱ្យទាន ពៀរវេរាមិនចម្រើនដល់បុគ្គលអ្នកសង្រួម បុគ្គលអ្នកឈ្លាស បរិបូណ៌ដោយញាណរមែងលះបង់នូវអំពើអាក្រក់លាមកបាន បុគ្គលនោះក៏បរិនិព្វានព្រោះអស់រាគៈ ទោសៈ មោហៈ ។

គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ហៅព្រះអានន្ទ-ដ៏មានអាយុមកថា ម្នាលអានន្ទ មកយើងនឹងទៅកាន់ត្រើយខាងនាយនៃស្ទឹងហិរញ្ញវតី នឹងចូលទៅកាន់សាលវន័ នៃពួកមល្លក្សត្រ ដែលជាទីចូលទៅក្នុងក្រុងកុសិនារា ។ ព្រះអង្គទ្រង់យាងអំពី

អម្ពវ័ន៍ជិតក្រុងបាវា ទៅដល់ឧទ្យានសាលវ័ន៍ ទីបរិនិព្វានជិតក្រុងកុសិនារា ទ្រង់ឈប់សម្រាក ២៥ ដង ក្នុងចម្ងាយផ្លូវ ១២ គីឡូម៉ែត្រ ដល់ហើយព្រះអង្គត្រាស់ថា ម្នាលអានន្ទ អ្នកចូររៀបចំគ្រែឱ្យមានក្បាលដំណេកបែរទៅទិសខាងជើង ក្នុងចន្លោះនៃដើមសាលព្រឹក្សទាំងគូ ឱ្យតថាគតដោយឆាប់ ម្នាលអានន្ទ តថាគតមានកាយល្ហិតល្ហៃណាស់ តថាគតនឹងសិង ។

នៅពេលដែលព្រះពុទ្ធបរមគ្រូ ទ្រង់សម្រេចសីហសេយ្យាជាចុងក្រោយ ដោយអនុដ្ឋានសេយ្យា គឺថាព្រះអង្គលែងក្រោកទៀតហើយ ពេលនោះក៏ជាពេលដែលព្រះអាទិត្យអស្តង្គតផងដែរ។

ពិតមែនតែព្រះដ៏មានព្រះភាគ ទ្រង់ពុំបានក្រោកដោយព្រះវរកាយ ប៉ុន្តែព្រះអង្គពុំមានឱកាសផ្ទំលក់ឡើយ ពេញមួយរាត្រី គឺក្នុងបឋមយាម ព្រះអង្គសម្តែងធម៌ប្រោសពួកមល្លក្សត្រ ក្នុងមជ្ឈិមយាម ប្រោសសុភទ្ទ ក្នុងបច្ឆិមយាមទ្រង់ប្រទានឱវាទដល់ភិក្ខុសង្ឃ លុះដល់វេលាជិតភ្លឺស្តេចទ្រង់បរិនិព្វាន ។

## នឹកព្រះសាស្តា

| | |
|---|---|
| មហាបរិនិព្វានសូត្រ | ស្តាប់ហើយស្រងូតស្រងាត់ក្នុងចិត្ត |
| នឹកព្រះសាស្តាប្រាថ្នាក្បៀកកិត | ទ្រង់និព្វានពិតចិត្តគិតទៅតាម ។ |

នឹកសង្ឃសាវ័កជាអ្នកមានបុណ្យ បរិសុទ្ធដោយគុណនិមន្តតាមស្នាម
ដង្ហែព្រះអង្គឆ្លងអន្លង់កាម តាមអង្គព្រះពុទ្ធចេញផុតអស់ហើយ ។
ក្នុងលោកវវឹកសន្ធឹកកាមគុណ សេពសោយហើយស៊ុនខ្វះបុណ្យឆ្ងាយត្រើយ
ហាក់ដូចសង្ឃឹមតែពុំមែនឡើយ ខកចិត្តឥតស្បើយហ្នឹងហើយលោកិយ ។
ឥឡូវនៅធមិអប់រំគំនិត នាមពិតរូបពិតពុំមែនប្រុសស្រី
សតិប្បដ្ឋានបានចាកលោកិយ តាមព្រះជិនស្រីដូចក្តីប្រាថ្នា ។
ចូរកុំប្រមាទគឺមានស្មារតី សីលកល្យាណីបណ្តាំសាស្តា
តម្កល់ស្មើល្អនូវសង្កប្បា ចូរតាមរក្សាថែចិត្តខ្លួនឯង ។
ភិក្ខុណានៅក្នុងសាស្នានេះ ព្យាយាមត្រិះរិះគោរពកោតក្រែង
ដោយមិនប្រមាទភិក្ខុនោះឯង ផុតទុក្ខចំបែងលះបង់សង្សារ ។
នឹកដល់មហាសុទស្សនសូត្រ ព្រះអង្គទ្រង់ស្រូតដល់កុសិនារា
ដើម្បីសម្តែងព្រះសូត្រនេះណា ចម្រើនកុសលាឱ្យដល់មហាជន ។
ម្យ៉ាងទៀតដើម្បីប្រោសសុភទ្ទៈ គ្រងកាសាវៈទទួលគុណធ្ងន់
សាវ័កចុងក្រោយប្រសើរពេកពន់ ជាព្រះអរហន្តទាន់ព្រះសាស្តា ។
នៅរឿងមួយទៀតគឺចែកព្រះធាតុ កុំឱ្យវិវាទដល់ថ្នាក់ប្រហារ
គឺបានទោណព្រាហ្មណ៍ធ្លាប់ជាគ្រូបា ខំប្រឹងផ្សះផ្សាខន្តីធមិល្អ ។
ឱកុសិនារាសាលព្រឹក្សឧទ្យាន ឋានព្រះទ្រង់ញាណនិព្វានពិតហ្ន៎
នៅតែព្រះធមិឱ្យសត្តនិករ ដើរតាមផ្លូវល្អតាមស្នាមព្រះបាទ ។

# ព្រះសុត្តន្តបិដកខ្មែរលេខ ១៧

## ទីឃនិកាយ មហាវគ្គ មាន ៧ ព្រះសូត្រ គឺ

១- មហាសុទស្សនសូត្រ
២- ជនវសភសូត្រ
៣- មហាគោវិន្ទសូត្រ
៤- មហាសមយសូត្រ
៥- សក្កបញ្ហសូត្រ
៦- មហាសតិប្បដ្ឋានសូត្រ
៧- បាយាសិរាជញ្ញសូត្រ ។

## ពាក្យគួរយល់ដឹង

≈≈≈≈≈≈≈≈≈≈≈≈≈≈≈

ហេតុនៃការសម្តែងនូវព្រះសូត្រ មាន ៤ យ៉ាងគឺ

១- **អត្តជ្ឈាសយ** តាមអធ្យាស្រ័យនៃព្រះពុទ្ធអង្គ

២- **បរជ្ឈាសយ** តាមអធ្យាស្រ័យនៃអ្នកស្តាប់

៣- **បុច្ឆាវសិក** តាមអំណាចនៃការសួរ

៤- **អត្ថុប្បត្តិក** តាមហេតុដែលកើតឡើង ។

# ១~ មហាសុទស្សនសូត្រ

ព្រះដ៏មានព្រះភាគ ទ្រង់សម្រេចសីហសេយ្យាដោយអនុដ្ឋានសញ្ញា ក្នុងសាលវ័ន ដែលជាផ្លូវបត់ចូលទៅកាន់ក្រុងកុសិនារា ក្នុងពេលជិតនឹងបរិនិព្វាន ។ ព្រះបរមសាស្តា ទ្រង់យាងមកបរិនិព្វាននៅនគរកុសិនារានេះ ដោយហេតុបីប្រការគឺ

១- អត្ថុប្បត្តិ ហេតុដែលនាំឱ្យកើតមាននូវមហាសុទស្សនសូត្រ

២- ដើម្បីប្រោសសុភទ្ទដែលជាពុទ្ធវេនេយ្យបុគ្គល

៣- ដើម្បីទោណព្រាហ្មណ៍ រំងាប់វិវាទក្នុងការចែកព្រះបរមធាតុ ។

ក្នុងអដ្ឋកថា មហាបរិនិព្វានសូត្រ បានសម្តែងថា ពិតណាស់ ព្រះដ៏មានព្រះភាគ ទ្រង់ជ្រាបសេចក្តីនេះថា កាលបើតថាគតបរិនិព្វានក្នុងទីដទៃ អត្ថុប្បត្តិ ហេតុកើតរឿងនៃមហាសុទស្សនសូត្រនឹងមិនមាន តែកាលបើបរិនិព្វានក្នុងនគរកុសិនារានឹងមាននូវអត្ថុប្បត្តិ ។ មហាជនស្តាប់មហាសុទស្សនសូត្រ ដែលតថាគតសម្តែងអំពីសម្បត្តិ ដែលតថាគតគប្បីសោយក្នុងទេវលោក

ប៉ុន្តែតថាគតបានសោយហើយក្នុងមនុស្សលោកនេះ ប្រដាប់ដោយភាណវារ ២ មហាជនទាំងនោះ បានស្តាប់ហើយនឹងសម្គាល់នូវកុសលថាគួរធ្វើ ។ ឯចំណែកអត្ថុប្បត្តិ មានដូចតទៅ

គ្រានោះឯង ព្រះអានន្ទដ៏មានអាយុបានចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយក៏ក្រាបថ្វាយបង្គំព្រះ-ដ៏មានព្រះភាគ រួចគង់ក្នុងទីដ៏សមគួរ ។ លុះព្រះអានន្ទដ៏មានអាយុគង់ស៊ប់ក្នុងទីដ៏សមគួរហើយ បានក្រាបបង្គំទូលចំពោះព្រះដ៏-មានព្រះភាគ យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះដ៏-មានព្រះភាគ កុំបរិនិព្វានក្នុងនគរកុសិនារានេះ ដែលជានគរតូចនគរទូល ជាសាខានគរឡើយ ។ បពិត្រព្រះអង្គដ៏ចម្រើន នគរធំៗឯទៀតក៏មាន ដូចយ៉ាងនគរចម្ប៉ា រាជគ្រឹះ សាវត្ថី សាកេតកោសម្ពី និងពារាណសី សូមព្រះដ៏មានព្រះភាគ ទ្រង់បរិនិព្វានក្នុងនគរទាំងនោះវិញ ព្រោះក្នុងនគរទាំងនោះ មានខត្តិយមហា-សាល ព្រាហ្មណមហាសាល និងគហបតិមហាសាល ជាច្រើននាក់ ដែលជ្រះថ្លាស៊ប់ក្នុងព្រះតថាគត ពួកជនទាំងនោះ នឹងធ្វើការបូជាព្រះសរីរៈរបស់ព្រះតថាគត ។ ព្រះអង្គទ្រង់ត្រាស់ថាម្នាលអានន្ទ អ្នកកុំពោលថា នគរនេះជានគរតូច នគរទូល ជាសាខានគរ យ៉ាងនេះឡើយ ។ ម្នាលអានន្ទ កាលពីមុន នគរ

កុសិនារានេះ ជារាជធានីឈ្មោះកុសាវតី របស់ព្រះបាទមហាសុទស្សនៈ ...។ នេះជាអត្ថុប្បត្តិ ហេតុកើតនៃមហាសុទស្សនសូត្រ ជាព្រះសូត្រដែលមហាជនស្តាប់ហើយ កើតមានសេចក្តីសម្គាល់នូវកុសលថាគួរធ្វើហ្នឹងឯង ។

## បុណ្យតែងចម្រើនដល់អ្នកឱ្យទាន

បុណ្យតែងចម្រើនដល់អ្នកឱ្យទាន ទោះទ្រព្យធនធានឬធមិទេស្នា
អបរាបរកុសលចេតនា ជ្រះថ្លាតាមក្រោយនាំឱ្យចិត្តស្ងប់ ។
បុគ្គលសង្រួមព្រមដោយសីលា ទាំងមានមេត្តាមហាគុណគាប់
មិនសាងវេរាពៀរក៏មិនជាប់ ទានសីលគួគាប់សម្រាប់ទាយក ។
ទក្ខិណេយ្យៈអង្គអ្នកទទួល ស្មារតីស្រួលបួលមិនមែនលង់លក់
ឆ្លាតឈ្លាសលះបាបជាធមិគម្រក់ ប្រៀបដូចលាមកប្រឡាក់ត្រូវលាង ។
កំពូលបុគ្គលគួរដល់ទក្ខិណា គឺព្រះសាស្តាព្រះអង្គទ្រង់យាង
ទទួលបិណ្ឌបាតនៅក្នុងរវាង ធរមានរូបរាងព្រះជន្មគង់នៅ ។
សូម្បីបរិនិព្វានទៅហើយ មិនខុសគ្នាឡើយប្រៀបធៀបគ្នាទៅ
ព្រោះចិត្តជ្រះថ្លាដូចទ្រង់គង់នៅ បុណ្យជាសំពៅទៅដល់និព្វាន ។

**សូមអនុមោទនា !**

# ២. ជនវសភសូត្រ

ព្រះដ៏មានព្រះភាគ ទ្រង់យាងពីក្រុងរាជគ្រឹះទៅវេសាលី ដើម្បីគង់ចាំវស្សាទី ៤៥ របស់ព្រះអង្គនៅវេឡុវគ្រាម ក្នុងរវាងផ្លូវ ព្រះអង្គទ្រង់គង់ក្នុងលំនៅដែលធ្វើដោយឥដ្ឋ ជិតនាទិកគ្រាម ហើយក៏ជិតក្រុងវេសាលីផងដែរ ។ ក្នុងទីនោះ ពេលនោះឯង ព្រះដ៏មានព្រះភាគ ទ្រង់ព្យាករនូវគតិនៃពួកជនដែលជាអ្នកបម្រើព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃ ក្នុងដំណើរទៅកាន់ភពខាងមុខ ដែលជាអ្នកធ្វើមរណកាលកន្លងទៅហើយ ។ ពួកជនទាំងនោះ ដែលព្រះដ៏មានព្រះភាគទ្រង់ព្យាករ គឺជាព្រះអនាគាមី ព្រះសកទាគាមី និងព្រះសោតាបន្ន នៅក្នុងជនបទទាំងឡាយ គឺកាសី កោសល វជ្ជី មល្លៈ ចេតិ វំសៈ កុរុ បញ្ចាល មច្ឆៈ សុរសេន ។ ព្រះអង្គទ្រង់ព្យាករពួកជននៅនាទិកគ្រាម ជាព្រះអនាគាមិបុគ្គលជាង ៥០ នាក់ ជាព្រះសកទាគាមិបុគ្គលជាង ៩០ នាក់ ជាព្រះសោតាបន្នបុគ្គលជាង ៥០០ នាក់ ដែលធ្វើមរណកាលទៅយូរហើយ ។ ពួកជនក្នុងនាទិកគ្រាម បានស្តាប់ការព្យាករដូច្នេះហើយ ក៏មានចិត្តត្រេកអររីករាយ កើតបីតិសោមនស្សក្នុងដំណើរនៃព្រះ-

អនាគាមិបុគ្គលជាដើមនោះ ។

ក្នុងកាលនោះ ព្រះអានន្ទដ៏មានអាយុ បានគិតថា ហេតុអ្វី បានជាព្រះដ៏មានព្រះភាគមិនព្យាករនូវគតិ ក្នុងដំណើរទៅកាន់ភព ខាងមុខរបស់ពួកជនក្នុងដែនមគធៈ ដែលជាអ្នកបម្រើព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃផង មានព្រះបាទពិម្ពិសារដែលតែងតែសរសើរ ព្រះដ៏មានព្រះភាគជាដើម ។ ព្រះអានន្ទដ៏មានអាយុ បានចូល គាល់ព្រះដ៏មានព្រះភាគ ។ ព្រះបរមសាស្តា បានត្រាស់សម្តែង ប្រាប់ព្រះអានន្ទអំពី **ជនវសភយក្ស** បានមកបន្លឺសំឡេងពីរដងថា បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គ ឈ្មោះពិម្ពិសារ បពិត្រព្រះ-សុគត ខ្ញុំព្រះអង្គ ឈ្មោះពិម្ពិសារ ។

ព្រះបាទពិម្ពិសារ កាលដែលព្រះអង្គនៅជាស្តេចក្នុងនគរ មគធៈ ព្រះអង្គបានស្តាប់ព្រះធម៌ដែលព្រះដ៏មានព្រះភាគទ្រង់ ត្រាស់សម្តែងនៅសួនលដ្ឋិវន័ ទ្រង់ជាធំលើពពួកជន ១១ ម៉ឺននាក់ ក្នុងការបានសម្រេចនូវសោតាបត្តិផល ព្រោះហេតុដូច្នោះ ព្រះអង្គ ទើបមានព្រះនាមថា **ជនវសភៈ** ។ ព្រះបាទពិម្ពិសារ ធ្លាប់កើត ក្នុងទេវលោក ជាសម្លាញ់នៃស្តេចវេស្សវណ្ណ ៧ ដង ជាស្តេចក្នុង មនុស្សលោក ៧ ដង បើតាមតែបុណ្យច្រើនរបស់ព្រះអង្គជាព្រះ-សោតាបន្នបុគ្គល ត្រូវឱ្យព្រះអង្គកើតក្នុងទេវលោកជាន់ខ្ពស់ ប៉ុន្តែ

ព្រោះកម្លាំងនៃសេចក្ដីប្រាថ្នាក្នុងស្ថានទីដែលធ្លាប់អាស្រ័យនៅ អស់កាលយូរ ទើបបានជាបដិសន្ធិទៀតក្នុងទេវលោកដដែល ។

ជនវសភយក្ស មានបំណងចង់ក្រាបទូលព្រះដ៏មានព្រះ-ភាគនូវពាក្យដែលបានស្ដាប់អំពីស្ដេចវេស្សវណ៌ ម៉្លោះហើយ តែងតែនឹករលឹកដល់ព្រះបរមសាស្ដាជារឿយៗ ស្រាប់តែពេលនេះ មានកិច្ចទៅរកស្ដេចវិរុឡ្ហកៈជាទេវរាជនៅទិសខាងត្បូង ក៏បានជួប ព្រះដ៏មានព្រះភាគក្នុងរវាងផ្លូវ ។ ពាក្យដែលបានស្ដាប់ពីស្ដេច វេស្សវណ៌ គឺជាពាក្យដែលស្ដេចវេស្សវណ៌បានទៅប្រជុំនៅឋាន តាវត្តិង្ស សភាពនៃអង្គប្រជុំនោះយ៉ាងណា គាថារបស់ព្រះឥន្ទ្រ យ៉ាងម៉េចខ្លះ ទាំងដែលតាវត្តិង្សទេវតានិងព្រះឥន្ទ្រ នាំគ្នានមស្ការ ព្រះតថាគត ហើយពាក្យដែលវែងឆ្ងាយប្រកបដោយធម៌ គឺពាក្យ របស់សនង្កុមារព្រហ្ម ចុះមកឋានតាវត្តិង្សសម្ដែងព្រះធម៌ ។ សនង្កុមារព្រហ្ម បានជ្រាបថា ពួកទេវតានិងព្រះឥន្ទ្រ ស្រឡាញ់ ចូលចិត្តចំពោះបញ្ចសិខគន្ធព្វបុត្រ ក៏និម្មិតខ្លួនឱ្យដូចជាបញ្ចសិខ-គន្ធព្វបុត្រ អង្គុយពែនភ្នែនក្នុងអាកាស ។

សនង្កុមារព្រហ្ម សម្ដែងធម៌អំពីឥទ្ធិបាទ ៤ ដែលព្រះដ៏-មានព្រះភាគ ជាព្រះអរហន្តសម្មាសម្ពុទ្ធ ទ្រង់ជ្រាបច្បាស់ ឃើញ ច្បាស់ ទ្រង់ត្រាស់បញ្ញត្តហើយដោយល្អ ... ភិក្ខុក្នុងសាសនានេះ

ចម្រើននូវឥទ្ធិបាទប្រកបដោយឆន្ទសមាធិ និងបធានសង្ខារ ... វីរិយសមាធិ និងបធានសង្ខារ ... ចិត្តសមាធិ និងបធានសង្ខារ ... វីមំសាសមាធិ និងបធានសង្ខារ ។ អដ្ឋកថា លើកឧទាហរណ៍អំពីព្រះរដ្ឋបាលត្ថេរ ធ្វើឆន្ទៈជាធុរៈ ញ៉ាំងលោកុត្តរធម៌ឱ្យកើតឡើង ព្រះសោណត្ថេរ ធ្វើវីរិយជាធុរៈ ព្រះសម្ភូតត្ថេរ ធ្វើចិត្តជាធុរៈ ព្រះមោឃរាជដ៏មានអាយុ ធ្វើវិមំសាជាធុរៈ ញ៉ាំងលោកុត្តរធម៌ឱ្យកើតឡើង ។ បធានសង្ខារគឺជាឈ្មោះនៃសម្មប្បធាន ៤ បានដល់វីរិយៈដែលញ៉ាំងកិច្ច ៤ ប្រការឱ្យសម្រេច ។

សនង្កុមារព្រហ្ម សម្តែងអំពីឱកាស ៣ យ៉ាង ដើម្បីបានដល់នូវសេចក្តីសុខ គឺឈានសុខ មគ្គសុខ ផលសុខ ។ ឱកាស ៣ យ៉ាង បើពោលតាមសាមញ្ញផលសូត្រ គឺឱកាសទី ១ ចាប់ពីចូឡសីលដល់បឋមជ្ឈាន ឱកាសទី ២ ចាប់ពីទុតិយជ្ឈាន ដល់អរូបជ្ឈានទី ៤ និងឱកាសទី ៣ ចាប់ពីវិបស្សនាដល់អរហត្ត ។

សនង្កុមារព្រហ្ម សម្តែងអំពីសតិប្បដ្ឋាន ៤ ដើម្បីបាននូវកុសលដោយអត្ថថា មិនមានទោស និងដោយអត្ថថាក្សេម ។ សម្តែងអំពីអរិយមគ្គអង្គ ៨ ដែលសម្មាសមាធិមានអរិយមគ្គ ៧ ខាងដើមជាបរិវារ ដោយសេចក្តីថា មានអង្គមគ្គខាងដើមជាឧបនិស្ស័យ ត១គ្នា រហូតដល់លោកុត្តរមគ្គអង្គ ៨ កើតព្រមគ្នា

ដូច្នេះ សម្មាសមាធិ មានអង្គមគ្គ ៧ ជាបរិវារ ។

សនង្កុមារព្រហ្ម សម្តែងអំពីធម្មគុណ ទាំងសម្តែងអំពីព្រះសេក្ខបុគ្គលនៅក្នុងដែនមគធៈច្រើនជាង ២ លាន ៤ សែននាក់ ជាអ្នកបម្រើព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ហើយបានធ្វើមរណកាលទៅយូរហើយ ។

ស្តេចវេស្សវណ៌ បានសម្តែងធម៌ដែលទ្រង់បានស្តាប់មកដល់បរិស័ទរបស់ខ្លួន ជនវសភយក្ស បានស្តាប់ហើយ ក៏នាំយកមកទូលព្រះដ៏មានព្រះភាគ ។ ព្រះបរមសាស្តាបានត្រាស់សម្តែងប្រាប់ព្រះអានន្ទត្ថេរ ចំណែកព្រះអានន្ទត្ថេរ ក៏បានសម្តែងប្រាប់ដល់ពួកភិក្ខុ ភិក្ខុនី ឧបាសក និងឧបាសិកា ។ សាសនព្រហ្មចរិយ-ធម៌នេះមាំមួន ដល់នូវសេចក្តីចម្រើន ផ្សាយទៅសព្វទិស អ្នកផងបានដឹងច្រើនគ្នា កើតមានក្រាស់ក្រែល រហូតដល់ទេវតានិងមនុស្សទាំងឡាយ ប្រកាសសម្តែងបានដោយល្អ ។

ព្រះបាទពិម្ពិសារ តាំងពីបានសម្រេចសោតាបត្តិផល នៅលដ្ឋិវ័នមក ព្រះអង្គមិនមានសេចក្តីប្រមាទក្នុងកុសលធម៌ឡើយ មានប្រក្រតីចម្រើនវិបស្សនា ដើម្បីជាប្រយោជន៍ដល់មគ្គជាន់លើ រស់នៅដោយសេចក្តីសង្ឃឹមថានឹងបានសម្រេចជាពិតប្រាកដ ។

# ៣~ មហាគោវិន្ទសូត្រ

ព្រះដ៏មានព្រះភាគ ទ្រង់គង់ប្រថាប់នៅលើភ្នំគិជ្ឈកូដ ជិតក្រុងរាជគ្រឹះ ។ គ្រានោះឯង បញ្ចសិខគន្ធព្វបុត្រ បានចូលគាល់ព្រះដ៏មានព្រះភាគ ក្រាបទូលព្រះអង្គអំពីពួកទេវតាប្រជុំគ្នានៅឋានតាវត្តិង្ស ក្នុងទេវសភា ឈ្មោះសុធម្មា ។ សក្កទេវរាជ បានសម្ដែងគុណ ជារបស់ពិត ៨ ប្រការ របស់ព្រះដ៏មានព្រះភាគ មានសេចក្ដីជាគោល១គឺ

១- ព្រះអង្គទ្រង់ប្រតិបត្តិដើម្បីប្រយោជន៍ដល់ជនច្រើន ... មិនមានសាស្ដាណា ដែលប្រកបដោយគុណនេះ ឱ្យដូចជាព្រះ-ពុទ្ធអង្គឡើយ ក្នុងកាលកន្លងទៅហើយក្ដី ក្នុងកាលឥឡូវនេះក្ដី ។

២- ព្រះអង្គទ្រង់ត្រាស់សម្ដែងធម៌ដោយល្អ ... មិនមានសាស្ដាណា ដែលសម្ដែងនូវធម៌គួរបង្អោនចូលមកទុកក្នុងចិត្តបាន ដែលប្រកបដោយគុណនេះ ឱ្យដូចជាព្រះពុទ្ធអង្គឡើយ ... ។

៣- ព្រះអង្គទ្រង់បញ្ញត្តដោយប្រពៃហើយថា នេះជាកុសល នេះជាអកុសល នេះប្រកបដោយទោស នេះមិនប្រកបដោយទោស នេះគួរសេព នេះមិនគួរសេព ... មិនមានសាស្ដាណា

ដែលប្រកបដោយគុណនេះ ឱ្យដូចជាព្រះពុទ្ធអង្គឡើយ ... ។

៤- ព្រះអង្គទ្រង់បញ្ញត្តល្អហើយ ដល់សាវក័ទាំងឡាយ នូវបដិបទាជាទីទៅកាន់ព្រះនិព្វាន ទាំងព្រះនិព្វាន ទាំងបដិបទា គឺប្រៀបផ្ទៀបគ្នាបាន ... ។

៥- ព្រះអង្គទ្រង់មិនជាប់ព្រះហឫទ័យជាមួយនឹងបរិស័ទជាសេក្ខាសេក្ខបុគ្គលឡើយ ព្រះអង្គត្រេកអរតែមួយព្រះអង្គឯង ...។

៦- ព្រះអង្គទ្រង់ប្រាសចាកសេចក្ដីស្រវឹង ក្នុងលាភសក្ការៈនិងសេចក្ដីសរសើរ ដែលសម្រេចហើយដល់ព្រះអង្គ ទ្រង់សោយចង្ហាន់តាមធម្មតា ... ។

៧- ព្រះអង្គទ្រង់ត្រាស់យ៉ាងណា ព្រះអង្គទ្រង់ធ្វើយ៉ាងនោះ ព្រះអង្គទ្រង់ធ្វើយ៉ាងណា ព្រះអង្គក៏ត្រាស់យ៉ាងនោះ ដោយប្រការដូច្នេះឯង ... ។

៨- ព្រះអង្គទ្រង់ឆ្លងផុតសេចក្ដីសង្ស័យអស់ហើយ ទ្រង់មានព្រះតម្រិះដល់ទីបំផុតគឺសព្វញ្ញុតញ្ញាណ ... ។

បញ្ចសិខគន្ធព្វបុត្រ ក្រាបទូលព្រះដ៏មានព្រះភាគជាបន្តទៀត អំពីសនង្កុមារព្រហ្ម បានស្ដាប់គុណកថា ៨ ប្រការ ជារបស់ពិត ដែលមានក្នុងព្រះដ៏មានព្រះភាគហើយ ក៏មានចិត្តត្រេកអររីករាយជ្រះថ្លា បានសម្ដែងនូវមហាគោវិន្ទចរិយា គឺការបំពេញ

បារមីនៃព្រះបរមពោធិសត្វ ដែលទ្រង់ជាមហាគោវិន្ទព្រាហ្មណ៍ ដោយបានប្រារព្ធនូវពាក្យសរសើរថា ព្រះដ៏មានព្រះភាគអង្គនោះ ជាបុគ្គលមានបញ្ញាច្រើន អស់កាលជាយូរអង្វែងមកហើយ ។

មហាគោវិន្ទព្រាហ្មណ៍ បានជាបុរោហិតនៃស្ដេច ៧ អង្គ ជាបុរោហិតដែលមនុស្សនិងទេវតាបូជាហើយ ។ សួយសារអាករណាដែលកើតមានដល់មហាគោវិន្ទព្រាហ្មណ៍ ក្នុងរាជ្យនៃស្ដេចទាំង ៧ អង្គ ក្នុងកាលនោះ មហាគោវិន្ទព្រាហ្មណ៍ បានឱ្យនូវមហាទាន ជាទានមិនកម្រើក ដូចជាសាគរ ដោយសួយសារអាករនោះ ។ ស្រូវនិងទ្រព្យសម្បត្តិដ៏ច្រើននោះ មិនមែនជាទីស្អប់ខ្ពើមនៃមហាគោវិន្ទព្រាហ្មណ៍ទេ ទាំងការសន្សំទ្រព្យនៃមហាគោវិន្ទ-ព្រាហ្មណ៍ ក៏មិនមែនជាមិនមានដែរ តែសព្វញ្ញុតញ្ញាណ ជាទីស្រឡាញ់របស់មហាគោវិន្ទព្រាហ្មណ៍ដ៏ក្រៃលែង ព្រោះហេតុនោះ បានជាមហាគោវិន្ទព្រាហ្មណ៍ឱ្យទ្រព្យដ៏ប្រសើរ ។

មហាគោវិន្ទព្រាហ្មណ៍ តែងប្រៀនប្រដៅពួកក្សត្រទាំង ៧ ព្រះអង្គ ដោយអនុសាសនី ព្រមទាំងប្រៀនប្រដៅដល់អ្នកដទៃទៀតដ៏ច្រើន ។ មហាគោវិន្ទព្រាហ្មណ៍បានជួបឆ្លើយឆ្លងជាមួយ-នឹងសនង្កុមារព្រហ្ម បានសួរប្រស្នាចំពោះសនង្កុមារព្រហ្មថា

ខ្ញុំមានសេចក្ដីសង្ស័យ សូមសួរសនង្កុមារព្រហ្មដែលជាអ្នក

មិនមានសេចក្តីសង្ស័យ ក្នុងប្រស្នាទាំងឡាយដែលប្រាកដដល់អ្នកដទៃ គឺអ្នកដទៃបានសាងបញ្ហាឡើងមកថា សត្វឋិតនៅក្នុងធម៌អ្វី សិក្សាក្នុងធម៌អ្វី ទើបដល់នូវព្រហ្មលោកដែលមិនស្លាប់ ?

សនង្កុមារព្រហ្មតបថា ម្នាលព្រាហ្មណ៍ដ៏ប្រសើរ បុគ្គលលះបង់នូវសេចក្តីប្រកាន់ថារបស់អញក្នុងសត្វទាំងឡាយ ជាបុគ្គលប្រព្រឹត្តតែម្នាក់ឯង មានចិត្តឱនទៅរកករុណាឈាន ប្រាសចាកក្លិនឆ្អាប វៀរចាកមេថុនធម្ម ឋិតនៅក្នុងធម៌ទាំងនេះ និងសិក្សាក្នុងធម៌ទាំងនេះ ទើបដល់នូវព្រហ្មលោកដែលមិនស្លាប់[១] ។

កាលដែលព្រះបរមពោធិសត្វ សាកសួរបញ្ជាក់អំពីក្លិនឆ្អាបបានជ្រាបច្បាស់ហើយ ទើបបានពោលថា ចំពោះក្លិនឆ្អាបទាំងនេះ បុគ្គលដែលនៅគ្រប់គ្រងផ្ទះ មិនងាយនឹងលះបង់បានឡើយ ។ សនង្កុមារព្រហ្មពោលថា ល្អហើយ មហាបុរស ចូរបួសចុះ កាលបើយ៉ាងនេះ ដំណើររបស់យើងមករកលោក គឺជាដំណើរមកដោយល្អពិត លោកគឺជាអគ្គបុរសក្នុងជម្ពូទ្វីប តាំងនៅក្នុងបឋមវ័យ ដែលបានលះបង់សម្បត្តិ និងភាពជាធំដោយយសយ៉ាងនេះ ហើយចេញបួស គឺជាការល្អប្រសើរដ៏ក្រៃលែង ដូចជាគន្ធហត្ថី

---

១- ពាក្យថាព្រហ្មលោកដែលមិនស្លាប់ ជាពាក្យសន្មតដែលអ្នកដទៃសាងមកតាមលទ្ធិសាសនាព្រាហ្មណ៍ ។

ទម្លាយនូវចំណងដែក ហើយត្រឡប់ទៅព្រៃវិញដូច្នោះឯង នេះឈ្មោះថាជាពូជពង្សរបស់ព្រះសម្មាសម្ពុទ្ធ ។

ព្រះមហាបុរស ហែហមដោយបរិស័ទគគ្រឹកគគ្រេងជាច្រើនយោជន៍មានក្សត្រិយ៍ ៧ អង្គជាដើម ចេញបួសទាំងអស់តាមព្រះបរមពោធិសត្វ ធ្វើដំណើរតាមស្រុកនិគមជនបទ និងរាជធានី ញុំាងមហាជនឱ្យតាំងនៅក្នុងបុណ្យកុសល ប្រាកដដូចពុទ្ធកោលាហល ។ ព្រះមហាបុរស បរមពោធិសត្វ ញុំាងមហាជនឱ្យតាំងនៅក្នុងបុណ្យកុសល គឺតាំងនៅក្នុងសីលសម្បទាឥន្ទ្រិយសំវរៈ ការស្គាល់ប្រមាណក្នុងការបរិភោគ ការប្រកបដោយសេចក្ដីព្យាយាម បរិកម្មកសិណ អភិញ្ញា សមាបត្តិ ៨ និងព្រហ្មវិហារ ប្រាកដដូចពេលដែលព្រះសម្មាសម្ពុទ្ធកើតឡើងក្នុងលោក (គ្រាន់តែមិនទាន់មានអរិយមគ្គក្នុងពេលនោះប៉ុណ្ណោះ) ។

មហាគោវិន្ទព្រាហ្មណ៍ បរមពោធិសត្វ មហាបុរសរ័ត្ន បានបំពេញនូវពោធិសម្ភារដោយមហាករុណា ដែលឱ្យសម្រេចក្នុងទីទាំងពួង មានជាអាទិគឺ បុញ្ញសម្ភារនិងញាណសម្ភារ សុចរិត ៣ អធិដ្ឋាន ៤ ពុទ្ធភូមិ ៤ ធម៌ដែលជាគ្រឿងអប់រំបន្ទុំមហាពោធិញ្ញាណ ៥ អធ្យាស្រ័យ ៦ មហាបុរិសវិតក្ក ៨ ធម៌មានយោនិសោមនសិការជាមូល ៩ និងបុញ្ញកិរិយាវត្ថុ ១០ ។

មហាគោវិន្ទព្រាហ្មណ៍ បរមពោធិសត្វ បំពេញបារមីដរាបដល់អស់អាយុ ញុំាងពេលវេលាឱ្យកន្លងទៅដោយសុខដែលកើតពីសមាបត្តិ កាលដែលអស់អាយុក៏ទៅកាន់ព្រហ្មលោក ។ ការប្រព្រឹត្តព្រហ្មចរិយធម៌របស់ព្រះបរមពោធិសត្វនោះមាំទាំ ផ្សព្វ-ផ្សាយទូលំទូលាយ ជាដំណឹងដឹងគ្នាជាទូទៅ រហូតដល់ទេវតានិងមនុស្សទាំងឡាយប្រកាសថាល្អហើយ ប្រព្រឹត្តទៅអស់កាលជាអង្វែង ។ បុគ្គលដែលប្រព្រឹត្តតាមព្រះបរមពោធិសត្វ បានឈានទៅកាន់ព្រហ្មលោកដោយបដិសន្ធិ អ្នកដែលបានត្រឹមមហាកុសលក៏កើតក្នុងទេវលោក ម្ល៉ោះហើយ ព្រហ្មលោកនិងទេវលោកពេញទៅដោយព្រហ្មនិងទេវតា ចំណែកអបាយ ៤ ប្រាកដដូចជាស្ងាត់សូន្យ ។

ព្រះរាជា ៧ ព្រះអង្គ ក្នុងកាលនោះ បានមកជាមហាថេរៈទាំងឡាយ បរិស័ទដទៃ បានមកជាពុទ្ធបរិស័ទ ចំណែកមហា-គោវិន្ទ គឺព្រះលោកនាថ ព្រះសមណគោតម បរមគ្រូ[១] ។

បញ្ចសិខគន្ធព្វបុត្រ ក្រាបទូលសួរព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន តើព្រះអង្គទ្រង់រលឹកឃើញដំណើរនោះដែរឬ? ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលបញ្ចសិខៈ តថាគត

១- អដ្ឋកថា ចរិយាបិដក មហាគោវិន្ទចរិយា ។

រលឹកឃើញ គឺសម័យនោះ តថាគតបានកើតជាមហាគោវិន្ទ-ព្រាហ្មណ៍ តថាគតសម្ដែងប្រាប់ផ្លូវ ដើម្បីឱ្យកើតជាព្រហ្ម នាព្រហ្មលោកនោះ ដល់ពួកសាវក័ទាំងឡាយ ។

ជាបន្តនៃព្រះសូត្រ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់អំពីព្រហ្មចរិយធម៌ ដើម្បីទៅកាន់ព្រហ្មលោកនោះ មិនមែនប្រព្រឹត្តទៅដើម្បីវិបស្សនា មិនមែនប្រព្រឹត្តទៅដើម្បីអរិយមគ្គ និងមិនប្រព្រឹត្តទៅដើម្បីព្រះនិព្វានឡើយ ព្រោះនៅក្នុងការបំពេញបារមីព្រះអង្គមិនទាន់បានត្រាស់ជាព្រះពុទ្ធនៅឡើយ ។ លុះព្រះអង្គបានត្រាស់ដឹងជាព្រះសម្មាសម្ពុទ្ធ អាស្រ័យការបំពេញនូវព្រះបារមីទាំងនោះហើយ ទើបបានព្រះអង្គទ្រង់ប្រកាសនូវព្រហ្មចរិយធម៌ប្រព្រឹត្តទៅដើម្បីវិបស្សនា ដើម្បីអរិយមគ្គ និងប្រព្រឹត្តទៅដើម្បីព្រះនិព្វាន ។ ព្រហ្មចរិយធម៌គឺអរិយមគ្គប្រកបដោយអង្គ ៨ ប្រការមានសតិប្បដ្ឋាន ជាបុព្វភាគប្បដិបទា កំណត់ដឹងនូវទុក្ខ សម្រេចការអស់ទៅនៃតណ្ហា តាមលំដាប់នៃមគ្គទាំង ៤ ។

ជាទីបញ្ចប់នៃមហាគោវិន្ទសូត្រ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់អំពី បញ្ញារបស់កុលបុត្រដែលជាអ្នកប្រព្រឹត្តព្រហ្មចរិយធម៌កំណត់ដឹងនូវទុក្ខ ទាំងអស់គ្នានោះ បញ្ញានោះ មិនសោះសូន្យមិនប្រកបដោយទោសឡើយ មានតែប្រកបដោយផល ប្រកប

ដោយសេចក្ដីចម្រើន ដោយប្រការដូច្នេះឯង ។

បញ្ចសិខគន្ធព្វបុត្រ ត្រេកអរទទួលព្រះធម៌ទេសនារបស់ព្រះដ៏មានព្រះភាគដោយចិត្ត អនុមោទនា ពោលសរសើរដោយវាចា និងប្រណម្យអញ្ជលីដាក់លើសិរសា ចូលទៅក្នុងឆព្វណ្ណរង្សីនៃព្រះដ៏មានព្រះភាគ ធ្វើប្រទក្សិណ ៣ ជុំហើយ ក៏បាត់ភ្លឹបចាកព្រះភក្ត្ររបស់ព្រះទសពល បានទៅកាន់ទេវលោករបស់ខ្លួន មានសភាពគួរឱ្យនឹករលឹក និងជ្រះថ្លាក្នុងការបំពេញបុណ្យជាមួយនឹងព្រះរតនត្រ័យដ៏ក្រៃលែង ។

## ឱព្រះសាស្ដា

ឱព្រះសាស្ដាអស្ចារ្យអ៊ីម្លេះ រុងរឿងវិសេសវិសាលលោកា
ក្នុងលោកគ្មានពីរប្រៀបដូចសុរិយា ពួកមនុស្សទេវតាជ្រះថ្លាបូជា ។
ទ្រង់ឫទ្ធិទ្រង់ញាណប្រទានទេស្នា បំភ្លឺលោកាទេវតាព្រហ្មា
ប្រកាសសច្ចៈចរណវិជ្ជា អង្គព្រះភគវាទ្រង់មារវិជ័យ ។

**សូមអនុមោទនា !**

# ៤. មហាសមយសូត្រ

ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងមហាវន័ ជិតក្រុងកបិលវត្ថុ ក្នុងសក្កជនបទ ព្រមដោយភិក្ខុសង្ឃ ៥០០ អង្គ សុទ្ធតែជាព្រះអរហន្តទាំងអស់ ។

ភិក្ខុសង្ឃ ៥០០ អង្គនេះ ទើបតែបានសម្រេចនូវព្រះ-អរហត្ត ក្នុងថ្ងៃដែលព្រះដ៏មានព្រះភាគព្រះអង្គទ្រង់ត្រាស់សម្តែងនូវព្រះសូត្រនេះឯង ។ បន្ទាប់អំពីប្រោសពួកព្រះញាតិ អ្នកសក្យៈនិងកោលិយៈ ក្នុងរឿងទឹកស្ទឹងរោហិណី ឱ្យព្រមព្រៀងគ្នាហើយព្រះរាជាទាំងឡាយទ្រង់ជ្រះថ្លា ត្រាស់ថា ប្រសិនបើព្រះសាស្តាស្តេចពុំបានយាងមកទេ ពួកយើងនឹងសម្លាប់គ្នាឯង ធ្វើឱ្យស្ទឹងពេញទៅដោយឈាមហើយហូរទៅ ។ ក្សត្រិយ៍ទាំងពីរព្រះនគរបានថ្វាយព្រះកុមារ ២៥០ អង្គ ក្នុងមួយនគរ រួមបានជា ៥០០ អង្គដល់ព្រះបរមសាស្តា ។ ព្រះដ៏មានព្រះភាគ ទ្រង់ឱ្យព្រះកុមារទាំងនោះបួសហើយ នាំទៅកាន់ព្រៃហិមពាន្តដោយឫទ្ធិរបស់ព្រះ-អង្គ សម្តែង **កុណាលជាតក** ប្រដាប់ដោយគាថាបីរយ ដើម្បីកម្ចាត់បង់នូវសេចក្តីអផ្សុកដល់ភិក្ខុបួសថ្មីទាំង ៥០០ ព្រះអង្គនោះ

ចប់ព្រះធម៌ទេសនា បានតាំងនៅក្នុងសោតាបត្តិផល ព្រមដោយឫទ្ធិ ហើយហោះតាមព្រះដ៏មានព្រះភាគត្រឡប់មកវិញ ដោយឫទ្ធិរបស់ខ្លួន រៀងៗព្រះអង្គ គង់នៅនាមហាវន៍នោះឯង ។

នៅនឹងមហាវន៍នោះ បានទទួលព្រះកម្មដ្ឋានអំពីព្រះបរមសាស្តា អប់រំវិបស្សនាបានសម្រេចព្រះអរហត្តទាំង ៥០០ អង្គនិមន្តមកគាល់ព្រះបរមសាស្តាជុំគ្នាក្នុងវេលាព្រះចន្ទពេញបូណ៌មីដែលកំពុងតែរះនៅទិសបូព៌ ។ រាត្រីនោះ ទេវតានិងព្រហ្ម បានមកប្រជុំគ្នាដើម្បីឃើញព្រះដ៏មានព្រះភាគផង ដើម្បីបានស្តាប់ព្រះធម៌ផង និងដើម្បីបានឃើញព្រះសង្ឃផង មានចំនួនច្រើន ក្នុងសែនចក្កវាឡ លើកលែងតែអសញ្ញសត្តាព្រហ្ម អរូបព្រហ្ម និងអ្នកចូលសមាបត្តិ ដែលមិនបានមកប្រជុំក្នុងពេលនោះ ។ ក្នុងចក្កវាឡនេះ ទេវតានិងព្រហ្មជុំគ្នាតាំងពីផែនដី រហូតដល់កណ្តាប់ចក្កវាឡ ទៅលើដល់ព្រហ្មលោក ពេញណែនទាំងអស់ មិនមានទីចន្លោះឡើយ ។ ចំពោះមហាសមយសូត្រនេះ គឺព្រះដ៏មានព្រះភាគទ្រង់ត្រាស់សម្តែងឱ្យភិក្ខុ ៥០០ អង្គ ក្នុងពេលហ្នឹង បានដឹងអំពីការប្រជុំធំនៃពួកទេវតា ព្រមទាំងពួកព្រហ្ម ទោះជាសម័យនៃព្រះសម្មាសម្ពុទ្ធអតីតនិងអនាគត ក៏មានប្រមាណប៉ុណ្ណោះដែរ មកប្រជុំដើម្បីឃើញព្រះដ៏មានព្រះភាគអង្គនោះៗ ។

ព្រះដ៏មានព្រះភាគ ទ្រង់មានព្រះញាណដោយមិនមានអ្វីមករារាំងបានឡើយ ព្រះអង្គបានចែកពួកទេវតានិងព្រហ្មទាំងនោះជាពីរពួក ដោយអំណាចជាអ្នកមានភ័ព្វ និងមិនមានភ័ព្វ ។ ព្រះទ្រង់ញាណ បានរួបរួមពួកអ្នកមានភ័ព្វហើយចែកជា ៦ ពួក ដោយអំណាចនៃចរិត ហើយព្រះអង្គទ្រង់ពិចារណាធម៌ឱ្យជាទីសប្បាយតាមចរិតនោះៗ ។ ព្រះអង្គនឹងត្រាស់សម្តែងព្រះធម៌តទៅ នៅក្នុងព្រះសូត្រដោយអំណាចនៃការសួរឆ្លើយ ព្រះអង្គទ្រង់ពិចារណារកមើលអ្នកសួរ គឺភិក្ខុ ៥០០ អង្គដែលនៅក្នុងមហាវន័នោះ ក៏មិនអាច មហាសាវក័ ក៏មិនអាច ព្រះអគ្គសាវក័ ក៏មិនអាច ប្រសិនបើមានព្រះបច្ចេកពុទ្ធ ក៏មិនអាចនឹងសួរដើម្បីឱ្យជាទីសប្បាយបានឡើយ ម៉្លោះហើយ ព្រះសូត្រក្នុងមហាសម័យនេះ គឺមិនមានអ្នកដែលអាចមកសាកសួរក្រៅអំពីព្រះពុទ្ធអង្គបានឡើយ ។ ព្រះដ៏មានព្រះភាគទ្រង់ផ្សាយព្រះញាណដែលមិនមានទីបំផុត ទៅក្នុងលោកធាតុដែលមិនមានទីបំផុត ព្រះអង្គទ្រង់ត្រួតមើល ក៏មិនបានទតឃើញព្រះសម្មាសម្ពុទ្ធដទៃ សូម្បីមួយព្រះអង្គឡើយ ។ បន្តទៀត ព្រះអង្គទ្រង់ជ្រាបថា បើព្រះអង្គទ្រង់សួរហើយឆ្លើយដោយព្រះអង្គឯង ទេវតានិងព្រហ្មទាំងនេះ ក៏មិនអាចនឹងចាក់ធ្លុះបានដែរ ដូច្នេះហើយ ព្រះដ៏មានព្រះភាគបាននិម្មិត

ព្រះសម្មាសម្ពុទ្ធមួយព្រះអង្គ យាងមកប្រកបដោយពន្លឺភ្លឺស្វាងពីទិសបូព៌ា កាលដែលនៅឆ្ងាយ ហាក់ដូចជាដួងចន្ទមួយដួងទៀតដូច្នោះឯង ។

ព្រះពុទ្ធនិម្មិតទ្រង់សួរ ព្រះពុទ្ធអង្គទ្រង់ឆ្លើយ នៅក្នុងព្រះសូត្រ ៦ គឺសម្មាបរិព្វាជនីយសូត្រ សម្រាប់ពួករាគចរិត កលហវិវាទសូត្រ សម្រាប់ពួកទោសចរិត មហាវិយូហសូត្រ សម្រាប់ពួកមោហចរិត ចូឡវិយូហសូត្រ សម្រាប់ពួកវិតក្កចរិត តុវដកបដិបទាសូត្រ សម្រាប់ពួកសទ្ធាចរិត បុរាភេទសូត្រ សម្រាប់ពួកពុទ្ធិចរិត ។

ក្នុងពេលសម្តែងព្រះធម៌នារាត្រីនោះ ពន្លឺចេញអំពីព្រះវរ-កាយនៃព្រះពុទ្ធអង្គនិងព្រះពុទ្ធនិម្មិត ប៉ះខ្ទប់គ្នាហើយបាញ់ទៅលើដល់អកនិដ្ឋកព្រហ្ម ត្រឡប់ចុះមកត្រូវសីសៈទេវតានិងព្រហ្មគ្រប់អង្គ ហើយតាំងនៅត្រឹមក្របមាត់ចក្កវាឡ ពួកទេវតានិងព្រហ្មទាំងអស់គឺឋិតនៅក្នុងពន្លឺរស្មីនៃព្រះសម្មាសម្ពុទ្ធ ។ មារាធិរាជបានជ្រាបអំពីសមាគមធំដូច្នេះ បំណងនឹងធ្វើសេចក្តីអន្តរាយដល់ការសម្រេចមគ្គផល ទើបបញ្ជូនកងទ័ពមារឱ្យមកសម្តែងអ្វីៗដែលគួរខ្លាច ដូចមានក្នុងព្រះសូត្រស្រាប់ ។ ជាប្រក្រតីនៃព្រះដ៏មាន-ព្រះភាគ គឺថា ក្នុងទីណា ដែលមិនមានការសម្រេចមគ្គផលដល់

អ្នកស្តាប់ ក្នុងទីនោះ ព្រះអង្គទ្រង់មិនហាមនូវមារដែលមកសម្តែងអ្វីៗដែលគួរខ្លាចនោះឡើយ ប៉ុន្តែ ក្នុងទីណា នឹងមានការសម្រេចមគ្គផលដល់អ្នកស្តាប់ ដូចជាក្នុងមហាសម័យនេះ ក្នុងទីនោះព្រះអង្គទ្រង់ហាម ។ ក្នុងមហាសម័យនេះ នឹងមានការសម្រេចមគ្គផលក្រៃលែងណាស់ ដូច្នេះហើយ ព្រះពុទ្ធអង្គទ្រង់អធិដ្ឋានមិនឱ្យបរិស័ទឃើញរូប មិនឱ្យឮសំឡេងដែលមារឬសេនាមារបណ្តាល មកនោះឡើយ ពួកមារមានតែក្តៅក្រហាយចិត្ត ចេញបាត់អស់ទៅ ។

កាលដែលព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ព្រះសូត្រទាំង ៦ (នៅក្នុងសុត្តនិបាត បិដកលេខ ៥៤) នេះចប់ហើយ អ្នកស្តាប់ក្នុងពេលនោះចំនួន ១ សែនកោដិ បានសម្រេចព្រះអរហត្ត ចំណែកទេវតានិងព្រហ្មបានសម្រេចសោតាបត្តិផលជាដើម មិនមានការរាប់ឡើយ ។ មារាធិរាជ បានពោលប្រារព្ធចំពោះព្រះភិក្ខុទាំង ៥០០ អង្គថា ពួកសាវក័ទាំងនេះ លោកឈ្នះសឹកសង្គ្រាមហើយ កន្លងបង់នូវសេចក្តីភ័យខ្លាចបានហើយ មានយសល្បីខ្ទរខ្ទារទៅក្នុងប្រជុំជន តែងរីករាយជាមួយនឹងព្រះអរិយៈដែលកើតហើយក្នុងសាសនាព្រះទសពល ។

# ៥. សក្កបញ្ហសូត្រ

ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងឥន្ទសាលគុហា ជិតភ្នំវេទិយកៈ ខាងកើតក្រុងរាជគ្រឹះ ។ ក្នុងកាលនោះ សក្កទេវរាជនៅជាបុថុជ្ជន ត្រូវមរណភ័យគ្របសង្កត់ ព្រោះឃើញបុព្វនិមិត្ត ៥ ប្រការ ទ្រង់នឹកអាល័យសម្បត្តិសព្វគ្រប់បែបយ៉ាងក្នុងទេវលោក ត្រូវសរគឺសេចក្តីសោកមុតហើយ ក៏នឹករកគាល់ព្រះបរមសាស្តា-សម្មាសម្ពុទ្ធ កាលដែលជ្រាបថា ព្រះពុទ្ធអង្គទ្រង់គង់សំងំនៅក្នុងឥន្ទសាលគុហា ក៏បាននាំទេវតាទាំងពីរឋានចុះមក ។

សក្កទេវរាជ បានជាព្រះអង្គនាំទេវតាដ៏ច្រើនចុះមកជាមួយ ព្រោះទ្រង់ធ្លាប់ចុះគាល់ព្រះដ៏មានព្រះភាគតែមួយព្រះអង្គឯង នៅសឡលគន្ធកុដិក្នុងវត្តជេតពន ក្នុងកាលនោះ ព្រះបរមសាស្តាទ្រង់ជ្រាបថា ញាណរបស់ព្រះឥន្ទមិនទាន់ចាស់ក្លា ទើបមិនទាន់ប្រទានឱកាស ។ ពេលនេះ សក្កទេវរាជទ្រង់ព្រះតម្រិះថា យើងមិនទាន់មានឧបនិស្ស័យគ្រប់គ្រាន់ដើម្បីសម្រេចមគ្គផល ជាពិតប្រាកដ ក៏ប៉ុន្តែ ក្នុងបណ្តាទេវតាទាំងពីរឋាន គង់មានអង្គណាមានឧបនិស្ស័យគ្រប់គ្រាន់មិនខាន កាលបើដូច្នេះ ព្រះសុគតសាស្តា

មុខតែត្រាស់សម្ដែងព្រះធម៌ប្រារព្ធអង្គនោះ ចំណែកយើងក៏បាន ស្ដាប់ហើយបន្ទោបង់នូវទោមនស្សក្នុងចិត្តបាន ទើបព្រះឥន្ទត្រាស់ ហៅទេវតាថា ម្នាលគ្នាយើងទាំងឡាយ ... ។

សក្កទេវរាជ ទ្រង់ព្រះតម្រិះទៀតថា បញ្ចសិខគន្ធព្វបុត្រ ជាឧបដ្ឋាកដែលព្រះទសពលទ្រង់ប្រោសប្រាណ បញ្ចសិខៈទៅទូល សួរបញ្ហាហើយស្ដាប់ធម៌បានរាល់ពេលដែលត្រូវការ ដូច្នេះយើង គប្បីបញ្ជូនឱ្យបញ្ចសិខៈនេះទៅមុន ដើម្បីសូមឱកាសចូលគាល់ ព្រះដ៏មានព្រះភាគ ។ ពេលនោះ នៅក្នុងបឋមយាមនៃរាត្រី នៅឡើយ ដោយការរួតរះរបស់ព្រះឥន្ទ ព្រោះត្រូវមរណភ័យគ្រប សង្កត់ ទើបប្រញាប់ចុះគាល់ព្រះបរមសាស្ដា ប្រាថ្នាទីពឹង ។ ពួក មនុស្សក្នុងស្រុកជិតខាង ឃើញពន្លឺភ្លឺស្វាងនៅក្នុងព្រៃភ្នំវេទិយកៈ ច្រាលវន្ទាល ដូច្នេះ ក៏មានសេចក្ដីតក់ស្លុត ព្រឺរោម ។

បញ្ចសិខគន្ធព្វបុត្រ ឋិតនៅក្នុងទីដ៏សមគួរហើយ ក៏បាន ដេញពិណ និងច្រៀងនូវគាថាដែលប្រកបដោយព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ព្រះអរហន្ត ព្រមទាំងប្រកបដោយកាម ។ គាថា ចម្រៀងទាំងនេះ គឺបញ្ចសិខៈបានចងក្រង និងបានច្រៀងរួចម្ដង ហើយ ព្រោះហេតុតែមានសេចក្ដីស្រឡាញ់ ប្រាថ្នាចង់បាននាង សុរិយវច្ឆសាដ៏ល្អស្អាត ដែលនាងជាធីតានៃគន្ធព្វរាជ ។ ក្នុងកាល

នោះ សុរិយវច្ឆសាទេពធីតា បានមានចិត្តស្រឡាញ់បុត្ររបស់ព្រះមាតលី ជាទេវបុត្រនៅឋានតាវត្តិង្ស ឈ្មោះសិខណ្ឌិទេវបុត្ររួចទៅហើយ ប៉ុន្តែ កាលដែលបានស្តាប់នូវគាថាចម្រៀងរួច នាងសុរិយវច្ឆសា ធីតានៃគន្ធព្វរាជ បានពោលទៅរកបញ្ចសិខៈថា ម្នាលអ្នកនិរទុក្ខ ខ្ញុំមិនដែលបានឃើញព្រះដ៏មានព្រះភាគអង្គនោះក្នុងទីចំពោះព្រះភក្ត្រសោះឡើយ ប៉ុន្តែមានពេលមួយ ដែលខ្ញុំបានចូលទៅរាំក្នុងឋានតាវត្តិង្ស ក៏បានស្តាប់ឮព្រះកិត្តិគុណរបស់ព្រះ-ដ៏មានព្រះភាគ ដែលសក្កទេវរាជទ្រង់ប្រកាសសម្តែងក្នុងទេវសភាឈ្មោះសុធម្មា ។ ម្នាលអ្នកនិរទុក្ខ កាលបើអ្នកបានពោលសរសើរព្រះដ៏មានព្រះភាគអង្គនោះ ដូច្នេះ ការជួបគ្នាក្នុងថ្ងៃនេះ ចូរមានដល់យើងទាំងពីរនាក់ ។ តាំងអំពីបញ្ចសិខៈបានទទួលសេចក្តីស្រឡាញ់អំពីធីតានៃគន្ធព្វរាជហើយ ក៏មិនដែលបានច្រៀងនូវគាថានេះទៀតឡើយ ទើបតែពេលនេះឯងដែលបញ្ចសិខៈច្រៀងជាលើកទីពីរ ។ បន្ទាប់អំពីព្រះដ៏មានព្រះភាគទ្រង់សំណេះ-សំណាលជាមួយបញ្ចសិខៈហើយ ព្រះអង្គទ្រង់អនុញ្ញាតឱ្យសក្ក-ទេវរាជ ព្រមទាំងពួកទេវតាចូលគាល់ ។

សក្កទេវរាជនិងពួកទេវតា បានចូលកាន់ឥន្ទសាលគុហាក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ក្នុងសម័យនោះ ឥន្ទសាលគុហា

ដែលមានផ្ទៃមិនរាបស្មើ ក៏ប្រែជាមានផ្ទៃរាបស្មើវិញ មានទីចង្អៀត ក៏ប្រែជាមានទីធំទូលាយវិញ ។ កាលដែលព្រះដ៏មានព្រះ-ភាគ ទ្រង់មានព្រះពុទ្ធដីកាបដិសណ្ឋារៈហើយ សក្កទេវរាជ ក៏បានក្រាបទូលអំពីការងារនៅឋានតាវត្តិង្ស ហើយបានក្រាបទូលអំពីការដែលព្រះអង្គឯងធ្លាប់បានចូលគាល់នៅសឡលគន្ធកុដិ នាវត្តជេតពន ដោយពុំបានជួបនឹងព្រះអង្គផ្ទាល់ ក៏បានផ្តាំផ្ញើការថ្វាយបង្គំរបស់ព្រះអង្គ ជាមួយនឹងនាងទេពធីតាឈ្មោះភុជគី ជាបរិចារិការបស់វេស្សវណមហារាជ ដែលកំពុងតែឈរប្រណម្យអញ្ជលី នមស្ការគោរពព្រះដ៏មានព្រះភាគ ។ សក្កទេវរាជបានទូលសួរព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន តើទេពធីតានោះ បានក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ តាមពាក្យរបស់ខ្ញុំព្រះអង្គដែរឬ ? ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា បពិត្រទេវានមិន្ទ ទេពធីតានោះបានថ្វាយបង្គំតថាគតហើយ ។

អដ្ឋកថា សម្តែងថា ភុជគីទេពធីតាជាប្រពន្ធរបស់ស្តេចវេស្សវណ៌ ប៉ុន្តែដោយសារទេពធីតានេះ បានសម្រេចសកទាគា-មិផល ហើយក៏មិនបានត្រេកអរនៅក្នុងទេវលោក ទើបនាងចុះមកបម្រើព្រះដ៏មានព្រះភាគ ។

ព្រះឥន្ទ្រ បានក្រាបទូលព្រះដ៏មានព្រះភាគអំពីឧបាសិកាម្នាក់

ជាសក្យធីតា ឈ្មោះគោបិកា ជាស្ត្រីជ្រះថ្លាក្នុងព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ បានអស់ជីវិតពីមនុស្សលោក មកកើតជាទេវបុត្រ ជាឱរសរបស់ព្រះអង្គ ។ កាលដែលសូមឱកាសអំពីព្រះដ៏មានព្រះភាគ ដើម្បីទូលសួរប្រស្នា ព្រះបរមសាស្តាទ្រង់ត្រាស់ថា

បពិត្រ វាសវៈ មហារាជមានព្រះហឫទ័យប្រាថ្នានឹងសួរនូវប្រស្នាណា ចូរសួរនូវប្រស្នានោះចំពោះតថាគតចុះ តថាគតនឹងធ្វើនូវទីបំផុតនៃប្រស្នាទាំងនោះ ថ្វាយមហាបពិត្របាន ។

បញ្ហាមាន ១៤ មុខ ក្នុងសក្កបញ្ហសូត្រគឺ

១- **ឥស្សាមច្ឆរិយៈ** នាំឱ្យសត្វលោកឈ្លោះគ្នា មានពៀរ

២- **បិយាប្បិយៈ** ស្រឡាញ់ស្អប់ ជាហេតុនៃឥស្សាមច្ឆរិយៈ

៣- **ឆន្ទៈ** ពេញចិត្តក្នុងកាមគុណ ជាហេតុនៃបិយាប្បិយៈ

៤- **វិតក្ក** ត្រិះរិះដោយតណ្ហានិងទិដ្ឋិ ជាហេតុនៃ ឆន្ទៈ

៥- **បបញ្ចធម៌** តណ្ហា មានះ ទិដ្ឋិ ជាហេតុនៃវិតក្ក

៦- **សោមនស្ស** គួរសេព និង មិនគួរសេព

៧- **ទោមនស្ស** គួរសេព និង មិនគួរសេព

៨- **ឧបេក្ខា** គួរសេព និង មិនគួរសេព

៩- **កាយសមាចារ** មារយាទផ្លូវកាយ គួរសេព និង

មិនគួរសេព

១០- **វចីសមាចារ** មារយាទផ្លូវវាចា គួរសេព និង មិនគួរសេព

១១- **បរិយេសនា** ការស្វែងរក គួរសេព និង មិនគួរសេព

១២- **ឥន្ទ្រិយសំវរៈ** ការសង្រួមឥន្ទ្រិយ ៦

១៣- **អនេកធាតុ** ធាតុគឺអធ្យាស្រ័យផ្សេងៗគ្នាច្រើន

១៤- **អច្ចន្តនិដ្ឋា** សម្រេចព្រះនិព្វាន ជាទីបំផុតទុក្ខ ។

នៅពេលព្រះដ៏មានព្រះភាគដោះស្រាយបញ្ហាទី ៨ រួច សក្កទេវរាជ បានតាំងនៅក្នុងសោតាបត្តិផល ។ នៅពេលដែលបានសម្រេចជាព្រះសោតាបន្នហើយ ព្រះឥន្ទទ្រង់ចុតិចំពោះព្រះ-ភក្ត្រនៃព្រះដ៏មានព្រះភាគ ភ្លាមនោះឯង ក៏កើតជាព្រះឥន្ទកំលោះវិញមួយរំពេច ។ នៅពេលដែលបដិសន្ធិជាព្រះឥន្ទក្នុងជាតិមួយទៀតហើយ ទើបបានសួរបញ្ហាព្រះដ៏មានព្រះភាគជាបន្ត អំពីបុព្វភាគប្បដិបទានៃអរិយមគ្គជាន់លើ ហួរហែ រហូតដល់ភិក្ខុមានចិត្តបង្អោនទៅកាន់ព្រះនិព្វានជាទីអស់ទៅនៃតណ្ហា ។

សក្កទេវរាជ សម្ដែងសេចក្ដីជ្រះថ្លា ហើយបាននមស្ការព្រះសម្មាសម្ពុទ្ធ ដូច្នេះថា

ខ្ញុំព្រះអង្គ បានឃើញនូវព្រះសម្ពុទ្ធ ទ្រង់ឆ្លងផុតចាកសេចក្ដី

សង្ស័យហើយ ក្នុងថ្ងៃនេះ ខ្ញុំព្រះអង្គជាអ្នករួចចាកភ័យហើយ បានចូលមកអង្គុយជិតព្រះសម្ពុទ្ធ ។ ខ្ញុំព្រះអង្គសូមថ្វាយបង្គំនូវព្រះ-សម្ពុទ្ធ ទ្រង់ដកចោលនូវសរគឺតណ្ហាចេញបានហើយ រកបុគ្គលប្រៀបផ្ទឹមគ្មាន ទ្រង់មានព្យាយាមច្រើន ទ្រង់ត្រាស់ដឹងនូវចតុរា-រិយសច្ច ព្រះអង្គជាពូជពង្សនៃព្រះអាទិត្យ ។ បពិត្រព្រះអង្គទ្រង់និរទុក្ខ ក្នុងកាលមុន ខ្ញុំព្រះអង្គព្រមទាំងទេវតា បានធ្វើកិច្ចនមស្ការណា ចំពោះព្រហ្ម ក្នុងថ្ងៃនេះ ខ្ញុំព្រះអង្គសូមថ្វាយនមស្ការនោះចំពោះព្រះអង្គវិញ ខ្ញុំព្រះអង្គ សូមធ្វើនូវការថ្វាយបង្គំចំពោះព្រះអង្គដោយខ្លួនឯង ។ ព្រះអង្គជាព្រះសម្ពុទ្ធពិតមែន ព្រះអង្គជាសាស្តាដ៏ប្រសើរក្នុងលោកនេះ ព្រមទាំងទេវលោក នឹងរកបុគ្គលណាមួយ មកប្រៀបផ្ទឹមនឹងព្រះអង្គគ្មានឡើយ ។

សក្កទេវរាជ ជាធំជាងពួកទេវតា សម្តែងពាក្យនមស្ការព្រះដ៏មានព្រះភាគរួចហើយ ទើបត្រាស់ហៅ បញ្ចសិខគន្ធព្វបុត្រថា នែបញ្ចសិខៈ អ្នកជាបុគ្គលមានឧបការៈច្រើនដល់យើងដោយពិត ដោយហេតុអ្នកបានធ្វើឱ្យព្រះដ៏មានព្រះភាគ ប្រោសប្រាណជាមុន ម្នាលអ្នក លុះអ្នកបានធ្វើឱ្យព្រះដ៏មានព្រះភាគ ប្រោស-ប្រាណជាមុនហើយ ទើបយើងបានចូលគាល់ព្រះដ៏មានព្រះភាគជាព្រះអរហន្តសម្មាសម្ពុទ្ធអង្គនោះ ក្នុងកាលជាខាងក្រោយ ។ នែ

បញ្ញសិខៈ យើងនឹងតាំងអ្នកទុកក្នុងឋានៈជាបិតា អ្នកនឹងបានជាស្តេចនៃពួកគន្ធព្វ ម្យ៉ាងទៀត យើងលើកនាងសុរិយវច្ឆសាដ៏ចម្រើនឱ្យដល់អ្នក ព្រោះថា នាងសុរិយវច្ឆសាដ៏ចម្រើននោះ អ្នកក៏ចង់បានមកជាយូរដែរហើយ ។

ស្រេចបាច់ហើយ សក្កទេវរាជ យកព្រះហស្តទះផែនដីទុកជាសាក្សីបញ្ជាក់ថា យើងក៏មិនញាប់ញ័រដូចអ្នកដែរ ហើយបន្លឺនូវឧទានអស់វារៈ ៣ ដង ក្នុងបទ នមោ តស្ស ហ្នឹងឯង ។

ព្រមជាមួយនឹងសក្កទេវរាជ ដែលបានសម្រេចមគ្គផលនោះដែរ ធម្មចក្ខុគឺសោតាបត្តិមគ្គ បានកើតឡើងដល់ពួកទេវតា ៨ ម៉ឺនអង្គ ក្នុងឥន្ទសាលគុហានោះឯង។

**សូមអនុមោទនា !**

# ៦. មហាសតិប្បដ្ឋានសូត្រ

ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងកម្មាសទម្មនិគម ក្នុងដែនកុរុ ។ នៅក្នុងព្រះសូត្រនេះ មានព្រះពុទ្ធដីកា មានអដ្ឋកថាដោយសព្វគ្រប់ហើយ ពុទ្ធបរិស័ទគួរយល់សេចក្តីនៃព្រះសូត្រនេះ ដូចតទៅ :

១- គ្រប់បព្វៈ គ្រប់ធម៌ទាំងអស់ ក្នុងមហាសតិប្បដ្ឋាន-សូត្រ គឺជាទីតាំងនៃសតិរលឹកសិក្សា ឬថាជាអារម្មណ៍របស់សតិ ។

២- មិនមែននៅក្នុងគំនិតមានខ្លួនយើង រៀបចំបព្វៈនេះ ឬកន្លែងនេះ ពេលនេះ ដើម្បីចម្រើនសតិប្បដ្ឋាននោះទេ គឺគ្រប់ព្រះអង្គ គ្រប់គ្នា គ្រប់កន្លែង គ្រប់ពេលវេលា សុទ្ធតែមានធម៌ជាទីតាំងនៃសតិរលឹកបានទាំងអស់ ធម៌ជាប្រក្រតី មិនមែនជាអត្តាតួខ្លួនយើងហើយស្រេច ។ កាលណា បើធម៌ជាប្រក្រតីប្រាកដលក្ខណៈមិនមែនជាអត្តាតួខ្លួនយើងហើយ ពុទ្ធបរិស័ទនឹងបានចេះដឹងច្បាស់ក្នុងចំណុចទី ២ នេះ បានដឹងការមានសតិថ្នាក់សតិប្បដ្ឋាន ខុសអំពីការដែលអត់មានសតិថ្នាក់សតិប្បដ្ឋាននោះឯង និងបានយល់ច្បាស់ថាអ្វីដែលជាទីតាំងនៃសតិរលឹកសិក្សា

ព្រមទាំងបានយល់អំពីវិបស្សនា ដែលជាតួដឹងច្បាស់ចំពោះអ្វីៗនោះ ។

៣- សតិថ្នាក់សតិប្បដ្ឋាន មានបច្ច័យទើបកើតឡើងបាន សតិនេះឯងជាសង្ខារក្ខន្ធ សត្វបុគ្គលតួខ្លួនអ្នកឱ្យសតិកើតអត់មានទេ ប៉ុន្តែអាស្រ័យការបានស្តាប់យល់តួធម៌ដែលព្រះពុទ្ធអង្គទ្រង់ត្រាស់សម្តែងប្រាប់ ក៏ជាបច្ច័យឱ្យមានការសិក្សាសង្កេតពិនិត្យរឿយៗ នូវតួធម៌នោះ រហូតដល់ឱ្យសតិថ្នាក់សតិប្បដ្ឋាននេះកើតឡើង សូម្បីអារម្មណ៏របស់សតិ ក៏ជាអារម្មណប្បច្ច័យនៃសតិផងដែរ ។

៤- ពាក្យថាបុគ្គលអ្នកព្យាយាមចម្រើនសតិប្បដ្ឋាន ជាវោហារដោយសម្មតិកថា តែបើដោយបរមត្ថកថា គឺវីរិយចេតសិកប្រព្រឹត្តទៅជាមួយនឹងសតិប្បដ្ឋានហ្នឹងឯង ។

៥- ស្តាប់ធម៌ គឺស្តាប់ឱ្យយល់ធម៌ដែលព្រះដ៏មានព្រះភាគទ្រង់ត្រាស់សម្តែងប្រាប់ អ្វីជាធម៌ ។ ធម៌ជាកុសល ធម៌ជាអកុសល ធម៌ជាអព្យាក្រឹត ។ បើស្តាប់អំពីអកុសលធម៌ មានលោភៈ ទោសៈ មោហៈ ឬកាមច្ឆន្ទៈជាដើម ហើយក្នុងគំនិតប្រកាន់ថា ជាកិលេសរបស់ខ្លួន ដូច្នេះ សតិប្បដ្ឋាន (សតិ ) រមែងមិនមានឡើយ សូម្បីមានគំនិតគិតថា ត្រូវចម្រើនសតិប្បដ្ឋានដើម្បីលះកិលេសនោះៗ

ក៏ដោយ មានតែចិត្តចង្អៀតចង្អល់ ទាស់នឹងកិលេស ខ្វល់នឹងឱ្យខ្លួនឯងអស់កិលេស គិតចង់បដិបត្តិធម៌ តើត្រូវបដិបត្តិយ៉ាងដូចម្តេចជាដើម ប៉ុន្តែ បើស្តាប់យល់អំពីអកុសលធម៌ កិលេសមានលោភៈជាដើម ជាប្រក្រតីក្នុងជីវិត ជាធម៌មានពិត កុសលក៏ជាតួធម៌ពិត រូបពិត វិបាកពិត ដូច្នេះ សតិប្បដ្ឋានរមែងមាន ដោយអត់ខ្វល់នឹងឱ្យខ្លួនឯងចម្រើនសតិប្បដ្ឋាន ដើម្បីនឹងបានលះបង់នូវកិលេសនោះៗឡើយ ហើយក៏អត់មានអ្នកដទៃណា មកបង្គាប់ឱ្យចម្រើនសតិប្បដ្ឋានដែរ ។

៦- កិលេសទាំងអស់ ជាធម៌ដែលត្រូវលះបង់ ប៉ុន្តែត្រូវលះបង់ដោយអរិយមគ្គ មានសតិប្បដ្ឋានជាបុព្វភាគ មិនមែននៅក្នុងគំនិតប្រកាន់កិលេសរបស់យើង ហើយទោមនស្ស ប្រទូស្តទាស់ចំពោះកិលេសនោះៗទេ ។

៧- សេចក្តីស្ងប់ក្នុងចិត្ត មិនមែននៅត្រង់ចង់បានសេចក្តីស្ងប់ទេ តែនៅត្រង់រលឹកដឹងចិត្ត ដែលកំពុងមាន កំពុងប្រាកដ ។ កាលដែលមិនប្រកាន់ចិត្តជាបច្ចុប្បន្ន ឃើញចិត្តបច្ចុប្បន្នជាធម៌ត្រូវលះបង់ទៅហើយ ដូច្នេះ មានត្រូវការប្រាថ្នាចង់បានចិត្តស្ងប់យកមកឱ្យអ្នកណា នេះឯងជាសេចក្តីស្ងប់ពិត ស្ងប់ក្នុងវិបស្សនា ។

៨- បើពុទ្ធបរិស័ទប្រាថ្នាតាមព្រះពុទ្ធអង្គ ក្នុងដំណើរចេញ

ពីលោកនេះ ទៅព្រះនិព្វាន គឺមានតែផ្លូវសតិប្បដ្ឋាននេះឯង ។ កំណត់នាមរូបជាប្រក្រតី មិនមែនជាយើង ទុកដាក់នាមរូបជាធម៌ក្នុងលោក ដូច្នេះពុទ្ធបរិស័ទពិតជាមិននៅក្នុងលោកនេះឡើយ ឈ្មោះថា បានដង្ហែព្រះពុទ្ធអង្គទៅកាន់ព្រះនិព្វាន ។

៩- សតិប្បដ្ឋាន មិនប្រព្រឹត្តទៅដើម្បីបានអ្វីពីក្នុងលោកនេះឡើយ ហើយក៏អត់ទោមនស្សជាមួយនឹងអ្វីៗដែរ ប៉ុន្តែលះបង់ការមិនដឹងនូវសភាវធម៌តាមសេចក្តីពិត ។

១០- ពុទ្ធបរិស័ទ ច្រើនតែចង់ឱ្យខ្លួនឯងអស់កិលេស ឃើញទោសនៃការខឹងក្រោធ ឃើញទោសនៃការប្រកាន់តួខ្លួនជាដើម ប៉ុន្តែមិនឃើញទោសនៃអវិជ្ជាគឺការមិនដឹងធម៌ទាំងពួងតាមសេចក្តីពិត ។ សតិប្បដ្ឋានបដិបក្ខដោយត្រង់ចំពោះអវិជ្ជានេះឯង ។

១១- សតិប្បដ្ឋានរលឹកដឹងធម៌តាមសេចក្តីពិត រមែងប្រព្រឹត្តទៅជាផ្លូវកណ្តាលអភិជ្ឈានិងទោមនស្ស ហើយក៏ជាការលះបង់នូវអភិជ្ឈានិងទោមនស្សក្នុងលោកហ្នឹងឯង ។

**សូមអនុមោទនា !**

# ៧. បាយាសិរាជញ្ញសូត្រ

ព្រះកុមារកស្សបៈដ៏មានអាយុ មួយអន្លើដោយភិក្ខុសង្ឃ ៥០០ អង្គ បាននិមន្តទៅដល់សេតព្យនគរ គង់នៅក្នុងព្រៃធ្នង់ ។ គ្រានោះ ព្រះបាទបាយាសិរាជញ្ញៈ គ្រប់គ្រងសេតព្យនគរ កើតមានទិដ្ឋិអាក្រក់យ៉ាងនេះថា លោកដទៃមិនមាន ពួកសត្វជាឱបបាតិកៈមិនមាន ផលវិបាករបស់កម្មទាំងឡាយ ដែលសត្វធ្វើល្អ ធ្វើអាក្រក់មិនមាន ។

ព្រះកុមារកស្សបៈ ជាបុត្ររបស់ភិក្ខុនីមាតា ពេលប្រសូតមក ត្រូវបានព្រះបាទបសេនទិកោសលយកទៅចិញ្ចឹម ព្រះរាជទាននាមថាកស្សបៈ កាលចម្រើនវ័យហើយ ព្រះរាជាក៏ឱ្យបព្វជ្ជាក្នុងសម្នាក់ព្រះបរមសាស្ដា បានប្រាកដព្រះនាមថា ព្រះកុមារកស្សបៈ ព្រោះជាបុត្រចិញ្ចឹមនៃព្រះរាជា ម្យ៉ាងទៀត កុំឱ្យច្រឡំនឹងភិក្ខុដទៃដែលមានព្រះនាម កស្សបៈដែរនោះ ។ ព្រះកុមារកស្សបៈ មានប្រវត្តិតស៊ូ ជាអ្នកបួសក្នុងសាសនាព្រះសម្មាសម្ពុទ្ធកស្សបទសពល សព្រហ្មចារីរបស់លោកក្នុងកាលនោះ បានកើតជាព្រហ្មសុទ្ធាវាស បានចុះមកកាន់ព្រៃអន្ធវន័ និមន្តឱ្យព្រះកុមារកស្សបៈរៀននូវបញ្ហា

១៥ ចំណុច ហើយទូលសួរព្រះដ៏មានព្រះភាគនៅមហាវិហារព្រះ-ជេតពន ។ បញ្ហា ១៥ ចំណុចនេះ មានក្នុងវម្មិកសូត្រ បិដកលេខ ២១ នៅពេលចប់ការវិសជ្ជនារបស់ព្រះដ៏មានព្រះភាគ ព្រះកុមារ-កស្សបៈក៏បានសម្រេចព្រះអរហត្ត ។

សេតព្យនគរ ឋិតនៅក្នុងដែនកោសល ដែលព្រះរាជាព្រះបាទបសេនទិកោសល ទ្រង់ប្រទានឱ្យជារង្វាន់ដល់ព្រះបាទបាយាសិរាជញ្ញៈ ។ ក្នុងកាលដែលព្រះបាទបាយាសិរាជញ្ញៈ យាងមកជួបព្រះកុមារកស្សបៈ រួចបានប្រកាសអំពីការយល់ឃើញរបស់ព្រះអង្គក្នុងពេលនោះហើយ ព្រះកុមារកស្សបៈបានសម្តែងធម៌ពន្យល់ ព្រមដោយការប្រៀបធៀបយ៉ាងច្រើន (ចាប់ពីទំព័រ ៣១០ ដល់ ៣៧០ ) ទីបំផុត ព្រះបាទបាយាសិរាជញ្ញៈ បានប្រកាសអំពីសេចក្តីត្រេកអរជ្រះថ្លារបស់ព្រះអង្គ ទ្រង់សរសើរព្រះធម៌ និងសូមដល់ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជាសរណៈ ហើយបានបំពេញនូវយញ្ញវិធីគឺការឱ្យទាន ។

ដោយការធ្វើទានរបស់ព្រះបាទបាយាសិរាជញ្ញៈ ខ្វះការគោរព មិនបានឱ្យដោយព្រះហស្តនៃព្រះអង្គផង ឱ្យដោយមិនបានផ្ចិតផ្ចង់ផង បោះឱ្យនោះផង លុះដល់អស់ព្រះជន្មទៅ ក៏បានចូលទៅកើតជាមួយនឹងពួកទេវតាជាន់ចាតុម្មហារាជិកៈ ក្នុងសេរីសក-

វិមាន ជាវិមានស្ងាត់ស្ងួន្យតែឯង ។

សេរីសកវិមាន ជាវិមានប្រាក់ មានដើមច្រេសមួយដើមធំនៅជិតខ្លោងទ្វារវិមាននោះ ព្រោះហេតុនោះ វិមាននោះទើបហៅថា សេរីសកវិមាន ។ សេរីសកព្រឹក្ស គឺដើមច្រេស ។ វិមានប្រាក់ឈ្មោះសេរីសកវិមាននេះ កើតឡើងដោយសារបុណ្យរបស់ព្រះគវម្បតិពីជាតិមុន ។ ព្រះគវម្បតិ កាលពីជាតិមុន ក្នុងសាសនាព្រះពុទ្ធកស្សបៈ ជាមនុស្សអ្នកឃ្វាលគោ បានរៀបចំទីដីក្រោមដើមច្រេសមួយដើមធំបានស្អាតស្មើល្អ ហើយនិមន្តព្រះថេរៈមួយអង្គ ជាព្រះខីណាស្រព ដែលប្រព្រឹត្តបិណ្ឌបាតិកធុតង្គ ឱ្យគង់ក្រោមដើមច្រេសនោះ ថ្វាយចង្ហាន់ដែលខ្លួនបានយកមកពីផ្ទះ ។ ដោយអានុភាពនៃបុណ្យនេះឯង កាលដែលចុតិពីមនុស្សលោកហើយ ក៏បានកើតជាទេវបុត្រក្នុងវិមានប្រាក់ ហើយមានដើមច្រេសមួយដើមធំនៅជិតខ្លោងទ្វារវិមាន ព្រមទាំងដើមច្រេសទាំងឡាយទៀត ជាសេរីសកវ័ន សម្រាប់លម្អវិមានប្រាក់នោះ ។ ទេវបុត្រនោះ ត្រាច់ទៅក្នុងទេវលោកនិងមនុស្សលោកអស់មួយចន្លោះព្រះពុទ្ធ ជាតិចុងក្រោយនេះ ជាសម្លាញ់របស់ព្រះយសត្ថេរចេញបួសតាមព្រះយសត្ថេរនៅព្រៃឥសិបតនមិគទាយវ័ន ស្តាប់ធម៌ទេសនារបស់ព្រះដ៏មានព្រះភាគចប់ បានសម្រេចព្រះអរហត្ត-

ផល គឺព្រះគវម្បតិហ្នឹងឯង ។ ព្រះគវម្បតិ មានប្រវត្តិថ្វាយផ្កាអញ្ចាំនដល់ព្រះសម្មាសម្ពុទ្ធសិខីដោយសេចក្ដីជ្រះថ្លា សូម្បីកំណើតលោកក្នុងជាតិនោះជាព្រានព្រៃក៏ដោយ ប៉ុន្តែដោយបុណ្យនោះលោកមិនដែលស្គាល់ទុគ្គតិអស់ ៣១ កប្ប លោកបានកសាងឆត្រនៅលើព្រះចេតិយរបស់ព្រះសម្មាសម្ពុទ្ធកោនាគមនោទៀតផង ។ ព្រះគវម្បតិ បានជាព្រះអរហន្តហើយ សោយវិមុត្តិសុខនៅនឹងព្រៃអញ្ចាំនជិតក្រុងសាកេត ក្នុងសម័យមួយនោះ ព្រះដ៏មានព្រះភាគនិងភិក្ខុសង្ឃជាច្រើនអង្គ គង់ក្នុងទីនោះដែរ ដោយសេនាសនៈមិនគ្រប់គ្រាន់ ភិក្ខុសាមណេរមួយចំនួនធំបានសិងនៅលើពំនូកខ្សាច់មាត់ទន្លេសរភូជិតវិហារ ដល់ពេលកណ្ដាលយប់ស្រាប់តែមានទឹកជំនន់ធំមកដល់ ធ្វើឱ្យភិក្ខុសាមណេរប្រញាប់ប្រញាល់ហៅគ្នាដោយសំឡេងខ្លាំងៗ ព្រះដ៏មានព្រះភាគ ទ្រង់ជ្រាបហេតុនោះហើយ បានត្រាស់ឱ្យព្រះគវម្បតិ ទប់ទឹកជំនន់នោះ ដើម្បីឱ្យភិក្ខុសាមណេរទាំងឡាយគង់នៅតាមសប្បាយ ។ ព្រះគវម្បតិទទួលតាមព្រះពុទ្ធដីកា ទប់ទឹកជំនន់ក្នុងទន្លេសរភូដោយឫទ្ធិរបស់លោកធ្វើទឹកឱ្យឡើងប៉ោងដូចជាភ្នំ មិនអាចហូរមកបានឡើយ ។ ចាប់តាំងពីពេលនោះមក អានុភាពព្រះគវម្បតិ បានប្រាកដឡើងក្នុងលោក ពេលមួយនោះ ព្រះដ៏មានព្រះភាគទ្រង់ទតព្រះនេត្រឃើញ

ព្រះគវម្បតិ គង់កណ្ដាលទេវបរិស័ទយ៉ាងច្រើន កំពុងសម្ដែងធម៌ឱ្យទេវតាទាំងនោះស្ដាប់ ។ ដើម្បីជាការសរសើរព្រះគវម្បតិផង និងដើម្បីអនុគ្រោះដល់សត្វលោកផង ទើបព្រះដ៏មានព្រះភាគទ្រង់ត្រាស់ប្រកាសដូច្នេះថា

ទេវតាទាំងឡាយ នាំគ្នានមស្ការ គវម្បតិភិក្ខុ ដែលជាអ្នកទប់ទឹកទន្លេសរភូ ឱ្យឈប់ហូរដោយឫទ្ធិ ជាអ្នកមិនជាប់នៅក្នុងកិលេសនិងតណ្ហាណាៗ មិនញាប់ញ័រចំពោះអ្វីៗទាំងអស់ ជាបុគ្គលកន្លងផុតគ្រឿងជាប់ជំពាក់ទាំងពួង ជាមហាមុនី និងជាបុគ្គលបានដល់ត្រើយនៃភព ។

ព្រះគវម្បតិ ដោយអំណាចធ្លាប់អាស្រ័យនៅក្នុងសេរីសកវិមានក្នុងភាពជាទេវបុត្រម្ចាស់វិមាន ព្រះថេរៈក៏បាននិមន្តទៅសម្រាកពេលថ្ងៃជារឿយៗក្នុងវិមានឋានទេវលោកនោះ ហើយក៏បានជួបនឹងទេវបុត្របាយាសិហ្នឹងឯង ។ បាយាសិទេវបុត្របានថ្វាយបង្គំព្រះគវម្បតិ ព្រមទាំងបានផ្ដាំផ្ញើតាមព្រះថេរៈមកឋានមនុស្ស ឱ្យពួកមនុស្សទាំងឡាយធ្វើទានដោយគោរពផង ដូចសេចក្ដីក្នុងព្រះសូត្រមានស្រាប់ហើយ ។

ព្រះកុមារកស្សបៈ បានទទួលការតែងតាំងអំពីព្រះដ៏មានព្រះភាគ ជាឯតទគ្គៈលើភិក្ខុទាំងឡាយផ្នែកខាងការសម្ដែងធម៌ដ៏

វិចិត្រ ដោយអត្ថុប្បត្តិ គឺការដែលព្រះកុមារកស្សបៈបានសម្តែងព្រះសូត្រ ប្រដាប់ដោយឧបមានិងហេតុទាំងឡាយយ៉ាងវិចិត្រ ថ្វាយដល់ព្រះបាទបាយាសិរាជញ្ញៈនោះឯង ម្យ៉ាងទៀត ស្របទៅតាមសេចក្តីប្រាថ្នា ១ សែនកប្បមកហើយផង ។

## សូមអនុមោទនា !

ព្រះសូត្រភាគមួយជួយឱ្យជ្រះថ្លា　រកការសិក្សាប្រាថ្នាចងចាំ
ព្រះត្រៃបិដកនិកាយមានប្រាំ　សិក្សាចំណាំជំនួយបញ្ញា ។
បើបុណ្យនៅមានឈានដល់ភាគពីរ　កិច្ចការសំភីប្រយោជន៏លោកា
ជីវិតលោកិយចំណើមរណា　ប្រយោជន៏ខ្លឹមសារអស់ការប្រកាន់ ។



# បុណ្យកឋិនទាន

ចិត្តបុណ្យចូលដល់កុសលកើន ទានសីលចម្រើនកើនសុខស្ងប់
តទៅថ្ងៃមុខមិនអភ័ព្វ មានបុណ្យជាទ្រព្យជាប់ហប្ញទ័យ ។
បីខែក្នុងវត្តពទ្ធសីមា គង់ចាំវស្សារាល់រាត្រី
ដល់ខែអស្សុជពេញបូណ៌មី ព្រះសង្ឃដល់ថ្ងៃចេញវស្សា ។
អស្សុជមួយរោចដូចរាល់ឆ្នាំ បរិស័ទចងចាំចិត្តជ្រះថ្លា
កឋិនកាលដល់ហើយណា រៀបបរិក្ខារតាមវិន័យ ។
តម្កល់អង្គត្រៃមួយកន្លែង រៀបចំតុបតែងផ្កាស្បង់ស្បៃ
ទេសនារៀបរាប់ភ្ជាប់និស្ស័យ ដង្ហែអង្គត្រៃវេរថ្វាយសង្ឃ ។
កំណត់វត្តមួយបានតែម្តង មួយឆ្នាំកន្លងមិនបង្អង់
បើខុសកាលហើយវេរថ្វាយសង្ឃ មិនឡើងជាអង្គកឋិនទេ ។
ផលានិសង្សកឋិនទាន សម្រេចកើតមានប្លែកលើសគេ
មិនមែនបានតែម្ចាស់ទានទេ បានទាំងអ្នកវេរទាំងព្រះសង្ឃ ។
ដែលបានក្រាលគ្រងត្រូវវេលា អនុមោទនាជាពាក្យត្រង់
សម្រេចបុណ្យបានទាំងអស់អង្គ បានអានិសង្សប្រាំប្រការ ។
ទីមួយបើចេញពុំបានលា ភិក្ខុផងគ្នាទៅទីណា
មិនត្រូវអាបត្តិក្នុងបទថា ចារិត្តសិក្ខាបទនោះអី ។

ទីពីរទៅណាទោះថ្ងៃយប់ មិនបាច់យកគ្រប់ចីវរបី
គឺស្បង់ចីពរសង្ឃាដី ខ្វះមួយណាក្តីមិនថ្វីឡើយ ។
ទីបីអាចឆាន់គណភោជន ដែលគេនិមន្តចំឆ្លងឆ្លើយ
ភោជនប្រាំយ៉ាងមួយណាហើយ ពុំទាស់អ្វីឡើយតាមប្រាថ្នា ។
ទីបួនរក្សាទុកបន្ត អតិរេកចីវរតាមត្រូវការ
មិនបានវិកប្បឬយ៉ាងណា នៅតែឈ្មោះថាការប្រពៃ ។
ទីប្រាំលាភកើតក្នុងអាវាស ស្បង់ស្បៃអ្វីខ្លះសង្ឃលកលៃ
ត្រូវបានចំណែកតាមវិន័យ ដូចអង្គដទៃដោយខ្ពង់ខ្ពស់ ។
នេះអានិសង្សប្រាំប្រការ សម្រួលបញ្ហាការរួមរស់
សង្ឃទទួលហើយមានកិត្តិយស រួចអាបត្តិព្រោះកឋិនទាន ។
ចំណែកទាយកទាយិកា មានចិត្តជ្រះថ្លាលះធនធាន
ចំណាយធ្វើបុណ្យកឋិនទាន អានិសង្សមានហួសបរិយាយ ។
ពុំអាចរៀបរាប់សព្វគ្រប់បាន សូមស្វែងរកអានក្បួនទាំងឡាយ
មានអានិសង្សផ្សេងវែងឆ្ងាយ បានសុខសប្បាយរស់មានន័យ ។
សូមបុណ្យដែលបានតែងរៀបរាប់ និងអ្នកអានចប់សព្វសេចក្តី
កើតជាតិ ណាៗ មានសិរី រហូតដល់ថ្ងៃបរិនិព្វាន ។

**សូមអនុមោទនា !**

ដោយឧបាសក **គុយ សុធន**

# នាមពុទ្ធបរិស័ទអ្នកមានឧបការៈ
# ក្នុងការងារធម្មទាន

| | |
|---|---|
| ១. លោកគ្រូ រស់ សុផាត | ២. ឧបាសក យន្ត សួន |
| ៣. ឧបាសក គួង លាងផេង | ៤. ឧបាសក មួង យេន |
| ៥. ឧបាសក សោម រតនៈ | ៦. ឧបាសក អ៊ិត ប្រាំង |
| ៧. ឧបាសិកា ជា សុណារី | ៨. ឧបាសិកា ប៊ុត ម៉ាលី |
| ៩. ឧបាសក គុយ សុធន | ១០. ឧបាសក វ៉ាន់ ខុនណា |
| ១១. ឧបាសក ជឹម ជំនិត | ១២. ឧបាសក ជឹង វ៉េងអ៊ាវ |
| ១៣. ឧបាសក ង៉ូវ គា | ១៤. ឧបាសក ហាយ ចំរើន |
| ១៥. ឧបាសក ច័ន្ទ សុខុម | ១៦. ឧបាសក ទូច គីមស្រ៊ាង |
| ១៧. ឧបាសក ម៉ៅ ម៉ន | ១៨. ឧបាសក ម៉ៅ ផុន |
| ១៩. ឧបាសិកា ហួនចាន់បូជា | ២០. ឧបាសិកា ហាយច័ន្ទធរី |
| ២១. ឧបាសក អ៊ឹម វ៉ៃយ៉ា | ២២. ឧបាសក ហង់ វណ្ណៈ |

**សព្វទានំ ធម្មទានំ ជិនាតិ**

ធម្មទានឈ្នះអស់ទានទាំងពួង ។

# រាយនាមពុទ្ធបរិស័ទក្នុងសហគមន៍ធម្មទាន
# ឧបត្ថម្ភប្រាក់ផ្សព្វផ្សាយព្រះធម៌ប្រចាំឆ្នាំ

១- លោក កេត សេរីភ័ត្រ និង អ្នកស្រី ប៉ុល ហត្ថា +បុត្រ ..... ស.រ.អ.
២- ឧ.សិ.កេតុ ថូរ និង ឧ.សិ.ស្វាយ សិត ព្រមទាំងបុត្រធីតា ... ស.រ.អ.
៣- ឧ.ស.កៅ សេក និង ឧ.សិ.យី សាគុណ ព្រមទាំងបុត្រ+ចៅ ស.រ.អ.
៤- ឧ.សិ.គុជ ឡាំងអេង និង អ្នកស្រី សេង យុវផា + កូនចៅ .. ស.រ.អ.
៥- ឧ.ស.គៀង សេរីគង់ និង ឧ.សិ.តាន់ រ៉ានី ព្រមទាំងកូនចៅ . ស.រ.អ.
៦- ឧ.សិ.ង៉ែត លេន ព្រមទាំងបុត្រ និងចៅ ...................... ស.រ.អ.
៧- ឧ.សិ.ចាន់ នារីសុខ និងក្រុមគ្រួសារ .......................... ស.រ.អ.
៨- ឧ.សិ.ឆាន់ ហៃកឹង ព្រមទាំងបុត្រ និង ចៅ .................... ស.រ.អ.
៩- ឧ.ស.ឆាយ អ៊ីវស៊ាង និង ឧ.សិ.ហុង គឹមសែ + បុត្រ ......... ស.រ.អ.
១០- ភិក្ខុ ឆុំសារឿន+ភិក្ខុឈួមសម្បូរ+ពុទ្ធបរិស័ទវត្តពន្លឺពុទ្ធចក្រ ស.រ.អ.
១១- ឧ.ស.ជា ស៊ុវត្ថានា និង ឧ.សិ.ឃុន សូនីម៉ា ព្រមទាំងបុត្រ .. ស.រ.អ.
១២- ឧ.ស.ជិម អេងស្រ៊ន និង ភរិយា ព្រមទាំងបុត្រ +ចៅ ..... ស.រ.អ.
១៣- ឧ.សិ.ជុំ ឆដា ( ហៅ លាភ )....................................... ស.រ.អ.
១៤- ឧ.សិ.ឈ គឹមហោ ព្រមទាំងបុត្រ និងចៅ ..................... ស.រ.អ.
១៥- ឧ.ស.ឈូ គឹមសួ និង ឧ.សិ.ឌឿ សុភា ព្រមទាំងបុត្រ ......... ស.រ.អ.
១៦- ឧ.ស.ឈួន ផារិន និង ឧ.សិ.ព្រំ ប្រណីត ...................... ស.រ.អ.
១៧- ឧ.សិ.តាន់ ភិចជូ ព្រមទាំងបុត្រធីតា និងចៅៗ ............. ស.រ.អ.
១៨- ឧ.ស.តាន់ តារាវង្ស និង ឧ.សិ.ជួប វុឌ្ឍី ព្រមទាំងកូនចៅ ... ស.រ.អ.
១៩- ឧ.សិ.តូច ចានយ៉ា ................................................... ស.រ.អ.
២០- ឧ.សិ.តាំង លេខគៀវ ( ហៅ តាំងប៉ាង ) ព្រមទាំងកូនចៅ . ស.រ.អ.

២១- ឧ.ស.តែ ប៊ុនគង់ និង ឧ.សិ.ថោង បូនី ព្រមទាំងបុត្រ+ចៅ ស.រ.អ.

២២- ឧ.សិ.តែ សាយជូ ព្រមទាំងបុត្រ និងចៅ ..................... ស.រ.អ.

២៣- ឧ.សិ.ទីន ឈីវ ព្រមទាំងបុត្រ និងចៅ ......................... ស.រ.អ.

២៤- ឧ.សិ.ទី គឹមជឹង ព្រមទាំងកូនចៅ ................................... ស.រ.អ.

២៥- ឧ.សិ.ទូច ផានី និង ស្វាមី Leslie Mael ព្រមទាំងបុត្រ . ស.រ.អ.

២៦- ឧ.ស.ប៊ន់ ហោម៉េង និង ឧ.សិ.ប៊ន់ ស៊ុនអាន+កូនចៅ ...... ស.រ.អ.

២៧- ឧ.សិ.ប៉ាន់ ពិណ្ណារី និង ស្វាមី ព្រមទាំងបុត្រ និងចៅ ........ ស.រ.អ.

២៨- ឧ.សិ.ប៉ាន សារិទ្ធ ហៅង៉ា ព្រមទាំងកូនចៅ ................... ស.រ.អ.

២៩- ឧ.សិ.ប៊ិត ចងខាំ និង ឧ.សិ.សាន ផល្លីនព្រមទាំងបុត្រ+ចៅ. ស.រ.អ.

៣០- ឧ.ស.ប៉ូ ហោនាង និង ឧ.សិ.អ៊ឹង វិទ្ធារី ព្រមទាំងបុត្រ ...... ស.រ.អ.

៣១- ឧ.សិ.ពិន សាត ព្រមទាំងបុត្រ និង ចៅ ............................ ស.រ.អ.

៣២- ឧ.ស.ពឹង សេងគី និង ឧ.សិ.អ៊ឹង ធឿម ព្រមទាំងបុត្រ+ចៅ ស.រ.អ.

៣៣- លោក ពេជ្រ សីហា និង អ្នកស្រី ថាប់ សុរត្ន័ ................. ស.រ.អ.

៣៤- ឧ.ស.ភឿក វ៉ាន និង ឧ.សិ.ហ៊ូ អាត់ ព្រមទាំងកូនចៅ ...... ស.រ.អ.

៣៥- ឧ.ស.ម៉ៃ គួលអេង និង ឧ.សិ.រស់ កល្យាណ ................... ស.រ.អ.

៣៦- ឧ.ស.យូស៊ាង ងួនលី និង ឧ.សិ. លីម ឃីម + បុត្រ .......... ស.រ.អ.

៣៧- ឧ.សិ.រស់ លីណា និង ឧ.សិ.នីម វណ្ណី ព្រមទាំងកូនចៅ .... ស.រ.អ.

៣៨- ឧ.សិ.រស់ សុផល .................................................... ស.រ.អ.

៣៩- ឧ.សិ.លី ប៉ូលីនស៊ីមប៉ូ .............................................. ស.រ.អ.

៤០- ឧ.សិ.លឹម ស៊ាងអ៊ុម និង ឧ.សិ.អេង គីមតិច .................. ស.រ.អ.

៤១- ឧ.ស.វង់ ម៉ៅ និង ឧ.សិ.ឆាន់ កាន់ជួង ព្រមទាំងបុត្រ+ចៅ . ស.រ.អ.

៤២- ឧ.ស.វ៉ាង សាវុធ និង ឧ.សិ.គង់ ស៊ីណាត ព្រមទាំងបុត្រ .. ស.រ.អ.

៤៣- ឧ.សិ.ស៊ីវ យក់លុយ ព្រមទាំងបុត្រ និងចៅ .................. ស.រ.អ.

៤៤- ឧ.សិ.សុខ យ៉ាន ...................................................... ស.រ.អ.

| | | |
|---|---|---|
| ៤៥- | ឧ.ស.ស៊ុន ដារិន និង ឧ.សិ.ទូច ចន្ទី ព្រមទាំងបុត្រ .......... | ស.រ.អ. |
| ៤៦- | ឧ.ស.ស៊ូ ហុកឡុង និង ឧ.សិ.តាន់ ឈីវហា ព្រមទាំងបុត្រ. | ស.រ.អ. |
| ៤៧- | ឧ.សិ.សេក ឆវី និងម្ដាយ យន់ ល្យេងស៊ីប ព្រមទាំងកូនចៅ ... | ស.រ.អ. |
| ៤៨- | ឧ.ស.សៅ ហ៊ាន និង ឧ.សិ.មាស ម៉ូនីកា ព្រមទាំងបុត្រ ... | ស.រ.អ. |
| ៤៩- | ឧ.ស.សំណាង យឹម និង ឧ.សិ.ឡូរ៉ា យឹម ព្រមទាំងបុត្រ ... | ស.រ.អ. |
| ៥០- | ឧ.សិ.ស្រង់ អែ និង ឧ.សិ.ស្រង់ ឡេង ព្រមទាំងបុត្រ+ចៅ | ស.រ.អ. |
| ៥១- | ឧ.ស.ហាក់ ច័ន្ទសុផល និង ឧ.សិ.វ៉ាង ស៊ីណា ព្រមទាំងបុត្រ | ស.រ.អ. |
| ៥២- | ឧ.សិ.ហេង លាភ ព្រមទាំងបុត្រ និង ចៅ ...................... | ស.រ.អ. |
| ៥៣- | ឧ.ស.ហោ លាន និង ភរិយា ...................................... | ស.រ.អ. |
| ៥៤- | ឧ.សិ.ហ្វាន់ នី និង ស្វាមី ព្រមទាំងបុត្រ ......................... | ស.រ.អ. |
| ៥៥- | ឧ.ស.ឡឹម ក្រហម និង ឧ.សិ.តាំង ធីយន ព្រមទាំងបុត្រ ... | ស.រ.អ. |
| ៥៦- | ឧ.សិ.ឡុង អ៊ឹម ព្រមទាំងបុត្រ និងចៅ ....................... | ស.រ.អ. |
| ៥៧- | ឧ.ស.ឡេង កុយ និង ឧ.សិ.ឈឹម សេន ......................... | ស.រ.អ. |
| ៥៨- | ឧ.សិ.ឡាំង គឹមឆេង ព្រមទាំងបុត្រ ........................... | ស.រ.អ. |
| ៥៩- | ឧ.ស.អ៊ាប ហៃសាន+ឧ.សិ.ឡឹកពេញចិត្ត+ឧ.ស.ឡឹកច័ន្ទដេត | ស.រ.អ. |
| ៦០- | ឧ.សិ.អ៊ឹង ស៊ីវន ព្រមទាំងបុត្រ និងចៅ ........................ | ស.រ.អ. |
| ៦១- | ឧ.ស.អ៊ុក សាមឿន និង ឧ.សិ.រ៉ូច អ៊ុម ព្រមទាំងកូនចៅ .. | ស.រ.អ. |
| ៦២- | ឧ.ស.អ៊ុន ផៃត្រី និង ភរិយា ព្រមទាំងបុត្រ .................. | ស.រ.អ. |
| ៦៣- | ឧ.សិ.អ៊ួន ញ៉ូ .......................................................... | ស.រ.អ. |
| ៦៤- | ឧ.សិ.អ៊ួន សាម៉ន ព្រមទាំងកូនចៅ .............................. | ស.រ.អ. |
| ៦៥- | លោកគ្រូធម្មបណ្ឌិត អឿ សៅ .................................. | ស.រ.អ. |
| ៦៦- | ឧ.ស.អៀង ឆាយ និង ឧ.សិ. អៀ កេសរ ព្រមទាំងបុត្រ . | ស.រ.អ. |
| ៦៧- | ឧ.សិ.អ៊ុំ ស៊ុននី និង កូនចៅ ...................................... | ស.រ.អ. |
| ៦៨- | ឧ.ស.គង់ វុធ និង ឧ.សិ.ជ័យ សារីម ព្រមទាំងកូនចៅ ....... | អូស្ត្រាលី |

៦៩- កញ្ញា គា ដារ៉ា ( ហៅ ស្រីណេ ) .............................. អូស្ត្រាលី

៧០- ឧ.ស.ង៉ូវ ឈីវ និង ឧ.សិ.ហេង ពាស៊ីម ព្រមទាំងបុត្រ+ចៅ អូស្ត្រាលី

៧១- ឧ.សិ.ឆេង លុន ព្រមទាំងបុត្រ និងចៅ ........................ អូស្ត្រាលី

៧២- ឧ.សិ.ជូ រ៉េន ........................................................ អូស្ត្រាលី

៧៣- ឧ.សិ.ឈ គីមស៊ីន និង ក្រុមគ្រួសារកូនចៅ .................. អូស្ត្រាលី

៧៤- ឧ.ស.ឈិត ទ្រី និង ឧ.សិ.បាន់ ណៃហ៊ាង ព្រមទាំងបុត្រ.... អូស្ត្រាលី

៧៥- លោក ញាន ហេងម៉ូវ និង អ្នកស្រី ស៊ា ចន្ថា ព្រមទាំងបុត្រ អូស្ត្រាលី

៧៦- ឧ.ស.ដែន គង់ហួត និង ឧ.សិ.កាំង គឹមស៊ុន ព្រមទាំងបុត្រ អូស្ត្រាលី

៧៧- ឧ.ស.ឌុច ផ្លែក និង ឧ.សិ.ហ៊ុន ណួក ............................ អូស្ត្រាលី

៧៨- ឧ.ស.តូ សាវឿន និង ឧ.សិ.មាន សុវត្ថិ ព្រមទាំងបុត្រ ........ អូស្ត្រាលី

៧៩- ឧ.សិ.តាំង សៀកហៀង ព្រមទាំងកូនចៅ ..................... អូស្ត្រាលី

៨០- ឧ.ស.ទា សុង និង ឧ.សិ.ង៉ោ ចាន់ខេង ព្រមទាំងកូនចៅ .. អូស្ត្រាលី

៨១- ឧ.សិ.បាក់ លីឡេងហ៊ាង ព្រមទាំងកូនចៅ ..................... អូស្ត្រាលី

៨២- ឧ.ស.ប៊ុន ហេង និង ឧ.សិ.ជុំ សុខុម ព្រមទាំងបុត្រ .......... អូស្ត្រាលី

៨៣- ឧ.សិ.ប៉ុក យ៉ារ៉ាត និង ស្វាមី+បុត្រ+លឹម ស៊ុនហេង+បុត្រ.. អូស្ត្រាលី

៨៤- ឧ.ស.ប៉ុច វឿត និង ឧ.សិ.ញូង ស៊ាងម៉េង ព្រមទាំងបុត្រ.. អូស្ត្រាលី

៨៥- លោកយាយ ប្រាក់ខាត់+ឧ.ស.ស៊ិន សាន+ឧ.សិ.សម្បត្តិ គង់ អូស្ត្រាលី

៨៦- ឧ.សិ.ពុធ សុខង៉ោ+ឧ.សិ.លី វណ្ណា និង ឧ.ស.ខួយ ចេង ... អូស្ត្រាលី

៨៧- ឧ.សិ.ម៉េង ប៊ុន្នារី ( ហៅស្រីពៅ ) និងស្វាមី ព្រមទាំងបុត្រ. អូស្ត្រាលី

៨៨- ឧ.ស.យ៉ង់ សិន និង ឧ.សិ.នន់ ហេង ព្រមទាំងបុត្រ+ចៅ. អូស្ត្រាលី

៨៩- ឧ.សិ.យិន មួយឡាង និង ស្វាមី ព្រមទាំងបុត្រ .............. អូស្ត្រាលី

៩០- លោក យឹម ឡេង និង អ្នកស្រី ប៉ុល និច្ចសីល +បុត្រ........ អូស្ត្រាលី

៩១- ឧ.សិ.រត្ន័ គីមសាន .................................................. អូស្ត្រាលី

៩២- ឧ.ស.រស់ សារ៉េន និង ឧ.សិ.គង់ សារឿង ព្រមទាំងបុត្រ . អូស្ត្រាលី

| | | |
|---|---|---|
| ៩៣- | ឧ.ស.រស់ ធារុន និង ឧ.សិ.ហេង សុមានធា .................... | អូស្ត្រាលី |
| ៩៤- | ឧ.ស.រាជ ស៊ាង និង ឧ.សិ.វង់រិទ្ធ ព្រមទាំងបុត្រ ............ | អូស្ត្រាលី |
| ៩៥- | ឧ.សិ.លឹម ស៊ូឆេង ព្រមទាំងកូនចៅ ........................... | អូស្ត្រាលី |
| ៩៦- | ឧ.ស.លឹម ហុងលី និង ឧ.សិ.ស៊ឹម តេងគី ព្រមទាំងបុត្រ... | អូស្ត្រាលី |
| ៩៧- | ឧ.ស.ស ឈុនតឹក និង ឧ.សិ.អាំង អ៊ានយ៉ុក ................. | អូស្ត្រាលី |
| ៩៨- | ឧ.សិ.ស៊ន លន់អេង ................................................ | អូស្ត្រាលី |
| ៩៩- | ឧ.ស.សរ ប៊ុនធៀង ព្រមទាំងបុត្រ និងចៅ................... | អូស្ត្រាលី |
| ១០០- | ឧ.ស.ស៊ីវ សៀងថៃ និង ឧ.សិ.ឯក សុកហាក់ +បុត្រ ...... | អូស្ត្រាលី |
| ១០១- | ឧ.ស.ស៊ីវ មាស និង ឧ.សិ.លាង ណាំសួរ ព្រមទាំងកូនចៅ.. | អូស្ត្រាលី |
| ១០២- | ឧ.សិ.សុខ ណារី និង ស្វាមី ព្រមទាំងបុត្រ ..................... | អូស្ត្រាលី |
| ១០៣- | ឧ.សិ.សុខ លាភ ព្រមទាំងបុត្រ ....................................... | អូស្ត្រាលី |
| ១០៤- | ឧ.សិ.ស៊ុយ គឹមស៊ាន និងកូនស្រី សេង ផល្លា ................ | អូស្ត្រាលី |
| ១០៥- | កញ្ញា ស៊ុយ ដាំណែត .............................................. | អូស្ត្រាលី |
| ១០៦- | ឧ.ស.ស៊ូ ឃីម និង ឧ.សិ.សៀង តិច ព្រមទាំងបុត្រ+ចៅ.. | អូស្ត្រាលី |
| ១០៧- | ឧ.សិ.សួយ មួយ ...................................................... | អូស្ត្រាលី |
| ១០៨- | ឧ.សិ.សៀ ចន្ថា ..................................................... | អូស្ត្រាលី |
| ១០៩- | ឧ.សិ.សៀង វួច ព្រមទាំងកូនចៅ ............................... | អូស្ត្រាលី |
| ១១០- | ឧ.សិ.សេង សៀងឈុន ព្រមទាំងបុត្រ និងចៅ ............. | អូស្ត្រាលី |
| ១១១- | ព្រឹទ្ធាចារ្យ សេង ទូច ព្រមទាំងបុត្រ និងចៅ ................. | អូស្ត្រាលី |
| ១១២- | ឧ.សិ.សិរិត ស៊ីវន ព្រមទាំងបុត្រ និងចៅ ..................... | អូស្ត្រាលី |
| ១១៣- | ឧ.ស.សំ សុខគុណ និង ឧ.សិ.លី សៀមហៀង + បុត្រ ... | អូស្ត្រាលី |
| ១១៤- | ឧ.ស.ហ៊ាង ពុធដានី និង ឧ.សិ.គាប ពុធធារី .................... | អូស្ត្រាលី |
| ១១៥- | កុង ហេង ឡេងថៃ និង ម៉ា អ៊ា គឹមទាង+ចៅថៃ ឃីអ៊ុយ | អូស្ត្រាលី |
| ១១៦- | ឧ.សិ.ហេង ពាអ៊ី និង ឧ.ស.អេង តាយ+កូនអេង ឡាយហួរ | អូស្ត្រាលី |

| | | |
|---|---|---|
| ១១៧- | ឧ.សិ.ហេង តាំងហុង ព្រមទាំងកូនចៅ .......................... | អូស្ត្រាលី |
| ១១៨- | ឧ.ស.ឡុង ហ៊ន និង ឧ.សិ.លិម យូអេង ...................... | អូស្ត្រាលី |
| ១១៩- | លោកម្ចាស់ សីលឋាវរោ ឡូញ ផល្លី ............................ | អូស្ត្រាលី |
| ១២០- | ឧ.ស.ឡៅ គីមងួន និង ឧ.សិ.ដួង លី ព្រមទាំងបុត្រ ........ | អូស្ត្រាលី |
| ១២១- | ឧ.សិ.អ៊ន ម៉ា ព្រមទាំងកូនចៅ .................................... | អូស្ត្រាលី |
| ១២២- | ឧ.ស.អ៊ា សេង និង ឧ.សិ.គីម ខេង ព្រមទាំងកូនចៅ ...... | អូស្ត្រាលី |
| ១២៣- | ឧ.ស.អ៊ុំង ឈាងហេង និង ឧ.សិ.សំ ពៅនារី +បុត្រ ......... | អូស្ត្រាលី |
| ១២៤- | ឧ.សិ. អ៊ុក ណារី ព្រមទាំងបុត្រ ................................. | អូស្ត្រាលី |
| ១២៥- | ឧ.សិ.អ៊ុច សុផល្លី ព្រមទាំងកូនចៅ .............................. | អូស្ត្រាលី |
| ១២៦- | ឧ.សិ.ឱម លក្ខណា ព្រមទាំងបុត្រធីតា ........................ | អូស្ត្រាលី |
| ១២៧- | HENG Srey Chea+HENG Srey Chan+H.Srey Neang. ... | អូស្ត្រាលី |
| ១២៨- | Mr BOON Leang Chaing+Mrs Nary SOK. ... | អូស្ត្រាលី |
| ១២៩- | ឧ.សិ.គី អ៊ុភីង .......................................................... | បារាំង |
| ១៣០- | ឧ.សិ.គីម ហួយ ព្រមទាំងបុត្រ និងចៅ ..................... | បារាំង |
| ១៣១- | ឧ.ស.ង៉ូវ ជួនណារេត ឧ.សិ.ង៉ូវ សោភ័ណ ព្រមទាំងបុត្រ... | បារាំង |
| ១៣២- | ឧ.សិ.ង៉ែត យ៉េន ព្រមទាំងបុត្រ និងចៅ ................... | បារាំង |
| ១៣៣- | ឧ.ស.ជីន ជុង និងភរិយា.......................................... | បារាំង |
| ១៣៤- | ឧ.ស.ឈឹម ហុកអ៊ាន ព្រមទាំងបុត្រ និងចៅ ............... | បារាំង |
| ១៣៥- | ឧ.សិ.ទាវ គឹមហ៊ួន ព្រមទាំងកូនចៅ ......................... | បារាំង |
| ១៣៦- | ឧ.ស.បាន ណារិន និង ឧ.សិ.ហោ ចន្ធូ ព្រមទាំងបុត្រ .... | បារាំង |
| ១៣៧- | ឧ.ស.ប៊ុន ឈឹម និង ឧ.សិ.គី គីមលាង ព្រមទាំងបុត្រ .. | បារាំង |
| ១៣៨- | ឧ.សិ.យិន មួយហួរ .................................................. | បារាំង |
| ១៣៩- | ឧ.សិ.យុក ជា ព្រមទាំងបុត្រ ..................................... | បារាំង |
| ១៤០- | លោក យូណូស អាស៊ីស និង អ្នកស្រី ហុក ណារី+បុត្រ ... | បារាំង |

| | | |
|---|---|---|
| ១៤១- | ឧ.សិ.ហែម ពៅ ព្រមទាំងបុត្រ .............................. | បារាំង |
| ១៤២- | ឧ.ស.ហ្វាន់ វ៉ាន់ហួ និង ឧ.សិ.ហ្វាន់ យូលាង ព្រមទាំងបុត្រ | បារាំង |
| ១៤៣- | ឧ.ស.ឡុក ប៊ុនអ៊ីវ និង ឧ.សិ.តាន់ ស៊ីវឡាង+បុត្រ........... | បារាំង |
| ១៤៤- | ឧ.ស.ឡោ សេងជ្រុន និង ឧ.សិ.ផាំង លី កូនចៅ .......... | បារាំង |
| ១៤៥- | ឧ.សិ.អ៊ឹង ហ្គេចតេង ព្រមទាំងបុត្រ ........................ | បារាំង |
| ១៤៦- | ឧ.សិ.អ៊ឹង យ៉េកសាង ព្រមទាំងបុត្រ ........................ | បារាំង |
| ១៤៧- | ឧ.ស.អេងឃី លាបឆាយ និង ឧ.សិ.ហែម ពៅ +បុត្រ ...... | បារាំង |
| ១៤៨- | Mme LAK KIM LEANG .............................. | បារាំង |
